សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាល
# សង្កាត់សាក់សំពៅ( ខណ្ឌដង្កោ រាជធានីភ្នំពេញ )

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

សមណនិស្សិត **វ៉ាន់ ថៃ**

**ឡាញ់ ដារិន**

ណែនាំដោយ

បណ្ឌិត **ឌឹត សំណាង**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាពព្រះនាម **ខាន់ ថៃ** និង**ឡាញ់ ដារិន** ជាសមណនិស្សិត ថ្នាក់បរិញ្ញាបត្រ ឯកទេសរដ្ឋបាលសាធារណៈ ក្រុម P4B02 ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២៤។

**សូមគោរពថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌ ការដឹងគុណជូនចំពោះ លោកឪពុក អ្នកម្តាយ** ទាំងពីរ ដែលលោកជាអ្នកមានគុណយ៉ាងធំធេងចំពោះកូនដែលមានតម្លៃពុំអាចកាត់ថ្លៃបានឡើយ ព្រោះលោកទាំងពីរបានផ្តល់កំណើតកើតជា ចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅ ដាស់តឿនក្រើនរំលឹកយប់ថ្ងៃល្ងាចព្រឹកផ្តល់ការស្រឡាញ់ ការថ្នាក់ថ្នម ភាពកក់ក្តៅ និងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ជាពិសេស លោកបានទំនុកបម្រុងការសិក្សាគ្រប់បែបយ៉ាងតាំងពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សានេះ។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់រូបដែលបានយកចិត្តទុកដាក់ដោយទំនួលខុសត្រូវខ្ពស់ចំពោះការសិក្សារបស់និស្សិតទាំងអស់ ដោយពុំគិតពីបញ្ហាការលំបាកអ្វីឡើយ ផ្ទុយទៅវិញនោះ លោកតែងតែខិតខំដាក់តឿនក្រើនរំលឹកអប់រំទូន្មានប្រៀនប្រដៅបំផុសស្មារតី និស្សិតគ្រប់រូបឱ្យខិតខំប្រឹងប្រែងយកចិត្តទុកដាក់សិក្សារៀនសូត្រស្វែងរកចំណេះវិជ្ជាមកដាក់ខ្លួន និងពង្រឹងខ្លួនឯងធ្វើយ៉ាងណាដើម្បីឱ្យក្លាយទៅជាមនុស្សម្នាក់ដែលមានសមត្ថភាពពេញលេញដែលសង្គមត្រូវការ។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌិត **ឌឹត សំណាង** ដែលបានចំណាយពេលវេលាដ៏មានតម្លៃលែលកមកដឹកនាំ និងសម្របសម្រួលដល់ដំណើរការនៃការសរសេរសារណានេះ តាំងពីការចាប់ផ្តើម រហូតដល់ទីបញ្ចប់សព្វគ្រប់ និងទទួលបានជោគជ័យ។

លោកចៅសង្កាត់ **សៅ ព្រហ្ម** សមាជិកក្រុមប្រឹក្សា និងស្មៀនសង្កាត់ដែលបានជួយសម្របសម្រួលក្នុងការផ្តល់ឯកសារ និងណែនាំពន្យល់ពីស្ថានភាពទូទៅជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ។

ជាចុងក្រោយ អាត្មាភាពទាំងពីរអង្គ សូមគោរពជូនពរ **លោកឪពុក អ្នកម្តាយ** ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងមិត្តនិស្សិតទាំងអស់ មានសុខភាពល្អ សំណាងល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ចការងារ និងសមប្រកបជួបប្រទះតែពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីក្លាយទៅជាបការៈដទៃឡើយ។

# អារម្ភកថា

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ “ការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ” គឺកើតឡើងដោយមានការសហការគ្នាជាផ្លូវមួយ និងការឯកភាពព្រមព្រៀងស្រុះស្រួលបបួលគ្នាខិតខំខ្នះខ្នែងប្រឹងប្រែងព្យាយាមរបស់អាត្មាភាពទាំងពីរអង្គយ៉ាងសស្រាក់សស្រាំឥតស្រាកស្រាន្ត របូតបានសម្រេចចេញជារូបរាងសៀវភៅសារណានេះឡើង ។

ជាការពិតណាស់ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មានសារៈសំខាន់ណាស់នៅក្នុងការចូលរួមចំណែក នៃការអភិវឌ្ឍសង្គមជាតិ ដោយបានលើកកម្ពស់នៃការផ្តល់សេវាសាធារណៈ បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងឆ្លើយតបទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ជាពិសេស ធ្វើឱ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និទ្ធនឹងគ្នាថែមទៀត ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលបានយល់ច្បាស់ពីប្រជាពលរដ្ឋ ថាតើពួកគាត់ចង់បានអ្វី និងមិនចង់បានអ្វី ដើម្បីងាយស្រួលដោះស្រាយបញ្ហាជូនពួកគាត់បានទាន់ពេលវេលាផងដែរ ។ វត្ថុបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើឡើងដើម្បីសិក្សាស្វែងយល់ពីដំណើរការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលសង្កាត់ សាក់សំពៅ តើមានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេច។ ក្រោយពីទទួលបាននូវបទពិសោធន៍ថ្មីៗនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះរួចមក ធ្វើឱ្យអាត្មាភាពបានយល់ដឹងកាន់តែស៊ីជម្រៅច្បាស់លាស់ជាងមុន ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលនៅឃុំ សង្កាត់ជាលក្ខណៈជាក់ស្តែងតែម្តង ដែលកន្លងមកនោះយើងធ្លាប់បានសិក្សាតែទ្រឹស្តីប៉ុណ្ណោះ។ សមិទ្ធផលមួយនេះ អាចសម្រេចជោគជ័យទៅបានអាស្រ័យដោយមានការសម្របសម្រួលជួយជ្រោមជ្រែងយិតយោងពីសាស្ត្រាចារ្យដឹកនាំ និងលោកគ្រូ អ្នកគ្រូ នៅក្នុងការផ្តល់ជាអនុសាសន៍ណែនាំត្រួសត្រាយបង្ហាញផ្លូវកែសម្រួលពាក្យពេចន៍រចនាបទ អត្ថន័យខ្លឹមសារអក្ខរាវិរុទ្ធ ធ្វើឱ្យអត្ថបទស្រាវជ្រាវមួយនេះសម្រេចចេញជាលទ្ធផលដែលអាចទទួលយកបាន។ ទោះបីជាអាត្មាភាព បានខិតខំព្យាយាមប្រឹងប្រែងពិនិត្យពិច័យយ៉ាងហ្មត់ចត់សារចុះសារឡើងម្តងហើយម្តងទៀតយ៉ាងណាក៏ដោយ ក៏គេចមិនផុតជៀសមិនរួចពីការខុសឆ្គាំឆ្គងល្មៀងសេចក្តីចន្លោះប្រហោងឆកល្វែងមិនទាន់គ្រប់ជ្រុងជ្រោយដោយមាននៅក្នុងទំព័រណាមួយជាក់ជាមិនខានឡើយ។ អាស្រ័យហេតុនេះ អាត្មាភាពទាំងពីរអង្គ រង់ចាំទទួលយកនូវរាល់ការរិះគន់ ការផ្តល់មតិយោបល់នៅក្នុងន័យស្ថាបនា និងការកែលម្អដោយក្តីសោមនស្សរីករាយពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិតមិត្តអ្នកអាន និងអ្នកស្រាវជ្រាវជាពិសេសពីសំណាក់គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃដើម្បីធ្វើការកែលម្អឱ្យមានភាពល្អប្រសើរឡើងថែមទៀត។

ជាចុងក្រោយ អាត្មាភាពទាំងពីរអង្គសង្ឃឹម និងជឿជាក់ថាកិច្ចការសារណាស្រាវជ្រាវមួយនេះនឹងអាចក្លាយជាការចូលរួមជាចំណែកមួយនៃចំណេះដឹងដល់មិត្តនិស្សិតទាំងឡាយ ជាពិសេសគឺអ្នកចង់សិក្សាស្រាវជ្រាវនូវ ប្រធានបទនេះបន្តទៅទៀត ព្រមទាំងជាទិន្នន័យជំនួយស្មារតីបន្ថែមសម្រាប់ការជួយបង្ហើបបើកបង្ហាញនូវផ្លូវដើរដល់មិត្តនិស្សិត និងសិស្សប្អូនជំនាន់ក្រោយៗទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**...................................................**១**
១. លំនាំបញ្ហានៃការស្រាវជ្រាវ...................................................១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ...................................................២
៣. គោលបំណងនៃការស្រាវជ្រាវ...................................................២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ...................................................២
៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ...................................................៣
៦.វិធីសាស្រ្តស្រាវជ្រាវ...................................................៣
៧.រចនាសម្ព័ន្ធនៃសារណា...................................................៣

## ជំពូកទី១

## ទ្រឹស្តីទូទៅស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

**១.១.និយមន័យ និងពាក្យគន្លឹះ** ...................................................៥
១.១.១.និយមន័យគ្រប់គ្រង...................................................៥
១.១.២. និយមន័យរដ្ឋបាល...................................................៥
១.១.៣.និយមន័យរដ្ឋបាលសាធារណៈ...................................................៦
**១.២.ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា**...................................................៨
១.២.១.ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា...................................................៨
១.២.២. វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា...................................................១៧
១.២.២. ក្របខ័ណ្ឌគោលនយោបាយសម្រាប់កំណែទម្រង់វិមជ្ឈការ  និងវិសហមជ្ឈការ...................................................១៩
១.២.៣. គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា...................................................២១
១.២.២.ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់...................................................២៨
១.២.៣.តួនាទី មុខងារ និងអំណាច...................................................២៨
**១.៣.គោលដៅនៃការផ្តល់សេវាសាធារណៈ**...................................................៣០

# ជំពូកទី ២
# ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់


**២.១.រចនាសម្ព័ន្ធ** ................................................ ៣១

**២.២.តួនាទី ភារកិច្ច** ................................................ ៣២

២.២.១.ក្រុមប្រឹក្សាឃុំ សង្កាត់ ................................................ ៣២

២.២.២ ប្រធានក្រុប្រឹក្សាឃុំ សង្កាត់ ................................................ ៣២

២.២.៣.សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ................................................ ៣២

២.២.៤. មេឃុំ ចៅសង្កាត់ ................................................ ៣៣

២.២.៥. ជំទប់ទី១ ចៅសង្កាត់រងទី១ ................................................ ៣៣

២.២.៦. ជំទប់ទី២ ចៅសង្កាត់រងទី២ ................................................ ៣៣

២.២.៧. ស្មៀន ................................................ ៣៤

២.២.៨.បុគ្គលិកឃុំ សង្កាត់ ................................................ ៣៤

២.២.៩.មេភូមិ និងជំនួយការភូមិ ................................................ ៣៥

**២.៣. កិច្ចការរដ្ឋបាល** ................................................ ៣៦

២.៣.១. លិខិតបទដ្ឋានគតិយុត្ត ................................................ ៣៦

២.៣.២. ដីកា ................................................ ៣៦

២.៣.៣. សេចក្តីសម្រេច ................................................ ៣៨

**២.៤. លិខិតរដ្ឋបាល** ................................................ ៣៨

២.៤.១. និយមន័យ ................................................ ៣៨

២.៤.២. ប្រភេទលិខិតរដ្ឋបាល ................................................ ៣៩

**២.៥. របៀបបែបបទការងារ** ................................................ ៤០

២.៥.១. ការចរាចរលិខិត ................................................ ៤០

២.៥.២. ការតាក់តែងលិខិត ................................................ ៤០

២.៥.៣. ការគ្រប់គ្រង និងការប្រើប្រាស់ត្រា ................................................ ៤១

**២.៦. ការគ្រប់គ្រងឯកសារ** ................................................ ៤១

២.៦.១. និយមន័យ ................................................ ៤២

២.៦.២. ផលប្រយោជន៍នៃការគ្រប់គ្រងឯកសារ ..... ៤២

២.៦.៣. ប្រភេទឯកសារ ..... ៤២

២.៦.៤. បច្ចេកទេសក្នុងការគ្រប់គ្រងឯកសារ ..... ៤៣

២.៦.៥. ការរក្សាទុកឯកសារ ..... ៤៣

**២.៧. ការគ្រប់គ្រងសម្ភារបរិក្ខារ** ..... ៤៣

**២.៨. គន្លឹះក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចប្រជុំ** ..... ៤៤

**២.៩.គណនេយ្យភាព** ..... ៤៤

**២.១០. ទំនាក់ទំនងអន្តររដ្ឋបាល** ..... ៤៥

២.១០.១. ទំនាក់ទំនងជាមួយក្រុមប្រឹក្សាប្រភេទដូចគ្នា ..... ៤៦

២.១០.២.ទំនាក់ទំនងជាមួយក្រុមប្រឹក្សាផ្សេងគ្នា ..... ៤៦

២.១០.៣. ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ និងភ្នាក់ងាររបស់រដ្ឋ ..... ៤៧

**ជំពូកទី៣**

**ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលសង្កាត់ សាក់សំពៅ**

**៣.១.ស្ថានភាពទូទៅ** ..... ៤៩

៣.១.១.ទីតាំងភូមិសាស្ត្រ ..... ៤៩

៣.១.២.ស្ថានភាពប្រជាសាស្ត្រ ..... ៤៩

**៣.២.លទ្ធផលដែលសម្រេចបាន(២០២១-២០២៣)** ..... ៥០

៣.២.១. វឌ្ឍនះភាព ..... ៥០

៣.២.២.បញ្ហាប្រឈម និងសំណូមពរ ..... ៥៥

**សេចក្តីសន្និដ្ឋាន** ..... ៦០

**អនុសាសន៍** ..... ៦១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមជាច្រើនលើកច្រើនសារ មិនត្រឹមតែបានបង្អាក់ដំណើរការអភិវឌ្ឍន៍នៅកម្ពុជាលើគ្រប់វិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ សង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ប្រព័ន្ធនយោបាយ និងផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរដ្ឋបាលជាបន្តបន្ទាប់។ ទោះបីយ៉ាងនេះក្តី រដ្ឋាភិបាលកម្ពុជាបានខិតខំរិះរកគ្រប់មធ្យោបាយដើម្បីស្តារ និងអភិវឌ្ឍប្រទេសជាតិឡើងវិញលើគ្រប់វិស័យក្នុងនោះរួមទាំងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមានសមត្ថភាពក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាពតាមមូលដ្ឋាន។

នៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានបង្កើត រដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាការបើកទំព័រថ្មីនៃប្រព័ន្ធគ្រប់គ្រងរដ្ឋ ទាំងរបបនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាលផងដែរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានធ្វើវិសោធនកម្មដើម្បីរៀបចំឡើងវិញនូវដែនដីរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។
- រាជធានីភ្នំពេញចែកជា ខណ្ឌ។ ខណ្ឌចែកជា សង្កាត់។
- ខេត្តចែកជា ក្រុង និងស្រុក។ ក្រុងចែកជា សង្កាត់។ ស្រុកចែកជា ឃុំ និងជា សង្កាត់។

ការរៀបចំ ដែនដីតាមការបែងចែកនេះ គឺសំដៅរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឱ្យបានជាក់លាក់រវាង តំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ដែលបានអនុវត្តរហូតមកទល់សព្វថ្ងៃ។

កម្ពុជាបានធ្វើការរៀបចំរដ្ឋបាលឱ្យមានភាពប្រសើរឡើងដោយបង្កើតឱ្យមានការបែងចែកអំណាច និងការផ្ទេរនូវសិទ្ធិអំណាចមួយចំនួនចាប់ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យ រដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីធ្វើការគ្រប់គ្រង និងផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋនៅមូលដ្ឋាននីមួយៗ ដែលរដ្ឋមិនអាចផ្តល់ជូនបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនោះ។ ជាគោលការណ៍ និងជាបទពិសោធន៍អន្តរជាតិ រដ្ឋបាលថ្នាក់ជាតិតែងតែផ្ទេរមុខងារ ទាំងមុខងារតាមប្រព័ន្ធ វិមជ្ឈការ(ការប្រគល់) និងមុខងារតាមប្រព័ន្ធវិសហមជ្ឈការ(ការធ្វើប្រតិភូកម្ម) កាន់តែច្រើនឡើងៗ ឱ្យទៅរដ្ឋបាលមូលដ្ឋាន ដើម្បីបង្កិតសេវា និងការអភិវឌ្ឍឱ្យកៀកជិតនឹងប្រជាជន ពីព្រោះតម្រូវការក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកាន់តែមានការកើនឡើងជារៀងរាល់ថ្ងៃ ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

មូលហេតុដែលជំរុញឱ្យអាត្មាភាពទាំងពីរអង្គស្រាវជ្រាវអំពី "ការគ្រប់គ្រងរដ្ឋបាលសង្កាត់សាក់សំពៅ" នេះដោយអាត្មាភាពបានសង្កេតឃើញថា រដ្ឋបាលឃុំ សង្កាត់គឺជារដ្ឋបាលស្ថិតក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនៅកៀកជិតប្រជាពលរដ្ឋបំផុត ហើយជាការបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានក្នុងការចូលរួមនឹងប្រាស្រ័យទាក់ទងការងារផ្សេងៗ។ ដើម្បីដឹងច្បាស់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់ត្រូវមានបញ្ហាចោទសួរ និងលើកឡើងនូវសំណួរជាច្រើនដូចជា៖

១.តើការគ្រប់គ្រងរដ្ឋបាលសង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានលក្ខណៈដូចម្ដេចខ្លះ?

២. តើរដ្ឋបាលសង្កាត់ សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទទួលបាននូវសិទ្ធអំណាចអ្វីខ្លះ នៅក្នុងការអនុវត្តការងារ?

៣.តើការរៀបគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ ខណ្ឌដង្កោរាជធានីភ្នំពេញ បានផ្ដល់នូវផលប្រយោជន៍អ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺមានគោលបំណងក្នុងការចូលរួមចំណែកបង្កើនចំណេះដឹងដល់ក្រុមរបស់អាត្មាភាពផ្ទាល់ដែលបានធ្វើការខិតខំស្រាវជ្រាវឡើង ព្រមទាំងបានយល់កាន់តែច្បាស់អំពីការគ្រប់គ្រងរដ្ឋបាលសង្កាត់ និងការអនុវត្តការងាររបស់មន្ត្រីរដ្ឋបាលសង្កាត់ សាក់សំពៅ ។ អាត្មាភាពសង្ឃឹមថាការស្រាវជ្រាវឯកសារមួយនេះអាចជាជំនួយដល់មិត្តនិស្សិតជំនាន់ក្រោយៗយកទៅសិក្សាបានបន្ថែមទៀត។ គោលបំណងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះគឺផ្ដោតទៅលើការស្វែងយល់ចំណុចមួយចំនួនដូចជា៖

- ដើម្បីសិក្សាស្វែងយល់ពីដំណើរការនៃការគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់ ជាពិសេសនៅក្នុងសង្កាត់សាក់សំពៅ។
- ស្វែងយល់ពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា សមាជិក រដ្ឋបាលឃុំ សង្កាត់។
- សិក្សាស្វែងយល់អំពីការយល់ដឹង និងការទទួលបានរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាសាធារណៈរបស់រដ្ឋបាលឃុំ សង្កាត់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំ និងដែនកំណត់នៃការស្រាវជ្រាវរបស់ក្រុមអាត្មាភាព គឺផ្ដោតសំខាន់ទៅលើការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រព្រឹត្តទៅនៅក្នុងសង្កាត់សាក់សំពៅ។ ការសិក្សាស្រាវជ្រាវនេះផ្ដោតទៅលើមុខងារ តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងសង្កាត់ក៏ដូចជាបញ្ហាប្រឈមនានា អមជាមួយនឹងដំណោះស្រាយដែលល្អបំផុត។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនូវប្រធានបទនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ នេះពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សាផ្នែករដ្ឋបាលសាធារណៈ ព្រោះថាការសិក្សាស្រាវជ្រាវមួយនេះបានផ្តល់សារៈសំខាន់ជាច្រើនដូចជា៖

- **សារៈសំខាន់សម្រាប់សង្គម៖** សម្រាប់ទុកជាឯកសារដល់អ្នកសិក្សាជំនាន់ក្រោយៗ ដើម្បីជាឯកសារជំនួយនៃការសិក្សាស្រាវជ្រាវ បង្កើនចំណេះដឹងដល់អ្នកអានបានយល់ពីប្រព័ន្ធគ្រប់គ្រងពីការរៀបចំ ក៏ដូចជា តួនាទីភារកិច្ចរបស់ រួមទាំងការប្រព្រឹត្តទៅរបស់រដ្ឋបាលឃុំ សង្កាត់ ជាពិសេសក្នុងសង្កាត់សាក់សំពៅ។
- **សារៈសំខាន់សម្រាប់រាជរដ្ឋាភិបាល៖** ងាយស្រួលក្នុងការកែលម្អ កំណែរទម្រង់បន្ថែមលើការរៀបចំគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។
- **សារៈសំខាន់សម្រាប់ប្រជាពលរដ្ឋ៖** ធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើនអំពីការផ្តល់សេវាសាធារណៈ និងអាចប្រើប្រាស់សេវាសាធារណៈកាន់តែល្អប្រសើរ។
- **សារៈសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្ទាល់៖** បានពង្រឹង និងពង្រីកចំណេះដឹងបន្ថែមតាមរយៈការស្រាវជ្រាវ ប្រមូលផ្តុំនូវឯកសារជាច្រើនដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ជាពិសេសក្នុងសង្កាត់សាក់សំពៅ កាន់តែច្បាស់លាស់។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

កិច្ចការស្រាវជ្រាវមួយនេះ គឺក្រុមរបស់អាត្មាភាពបានរៀបចំឡើងតាមរយៈការប្រមូលទិន្នន័យ ដែលបានចុះស្រាវជ្រាវពីសង្កាត់សាក់សំពៅដោយផ្ទាល់ ដែលផ្តោតសំខាន់ទៅលើការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ និងមានទិន្នន័យចម្រុងៗជាច្រើនទៀតដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងឯកសារនៅបណ្ណាល័យមួយចំនួនដែលទាក់ទងទៅនឹងប្រធានបទ ឯកសារពីសាស្ត្រាចារ្យដឹកនាំ ឯកសារដែលធ្លាប់បានសិក្សាពីសាស្ត្រាចារ្យពីមុនៗកន្លងមក និងឯកសារខ្លះទៀតដែលក្រុមអាត្មាភាពបានធ្វើការស្រាវជ្រាវតាមប្រព័ន្ធគេហទំព័រផ្សេងៗ ដើម្បីបានឯកសារបន្ថែមក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់អាត្មាភាពទាំងពីរអង្គ។

## ៧.រចនាសម្ព័ន្ធនៃសារណា

ចំពោះរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានចែកចេញជា ១កថាខណ្ឌ និង៣ជំពូកគឺ៖

**សេចក្តីផ្តើម៖** និយាយអំពី សេចក្តីផ្តើមដែលបរិយាយអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី១៖** រំលឹកទ្រឹស្តី បរិយាយអំពី និយមន័យ និងពាក្យគន្លឹះ ប្រព័ន្ធគ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា និងគោលដៅនៃការផ្តល់សេវាសាធារណៈ។

**ជំពូកទី២៖** ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បរិយាយអំពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច កិច្ចការរដ្ឋបាល លិខិតរដ្ឋបាល របៀបបែបបទការងារ ការគ្រប់គ្រងឯកសារ ការគ្រប់គ្រងសម្ភារបរិក្ខារ គន្លឹះក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចប្រជុំ ទំនាក់ទំនងអន្តររដ្ឋបាល។

**ជំពូកទី៣៖** ពិភាក្សាអំពីដំណើរការគ្រប់គ្រងរដ្ឋបាលសង្កាត់សាក់សំពៅ បរិយាយអំពីស្ថានភាពទូទៅ លទ្ធផលដែលសម្រេចបាន(២០២១-២០២៣) បញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១
# ទ្រឹស្តីទូទៅស្តីពីការគ្រប់គ្រងរដ្ឋបាល
# ថ្នាក់ក្រោមជាតិ

# ជំពូកទី១
# ទ្រឹស្តីទូទៅស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១.១.និយមន័យ និងពាក្យគន្លឹះ

មុននឹងឈានដល់ការបកស្រាយទៅលើប្រធានបទដែលនិយាយអំពី "ការគ្រប់គ្រងរដ្ឋរដ្ឋបាលសង្កាត់សាក់សំពៅ" ជាដំបូង យើងត្រូវធ្វើការសិក្សាស្វែងយល់នូវនិយមន័យរបស់ពាក្យ គន្លឹះនៃប្រធានបទជាមុនសិន ដើម្បីងាយយល់ពីអត្ថន័យខ្លឹមសាររបស់ប្រធានបទទាំងមូល។

### ១.១.១.និយមន័យគ្រប់គ្រង

គ្រប់គ្រង (កិរិយាសព្ទ) ពាក្យនេះបានមកពីពាក្យថា គ្របគ្រង

គ្រប (កិរិយាសព្ទ)=បិទខ្ទប់ពីលើ ឧទាហរណ៍ៈ គ្របឆ្នាំងឱ្យជិតទៅ គ្របពាងឱ្យជិតទៅ

គ្រប (នាមសព្ទ )=ប្រដាប់សម្រាប់បិទខ្ទប់ពីលើ ឧទាហរណ៍ គ្របពាង, គ្របបាត្រ

គ្រង (កិរិយាសព្ទ)= ចាំថែរក្សា, រក្សាជាជំនួស ឧទាហរណ៍ៈ គ្រងរាជ, គ្រងងារ

គ្រង (សង្ឃសព្ទ)= ស្លៀកដណ្តប់ត្រៃចីវរ ឧទាហរណ៍ៈ លោកសង្ឃគ្រងចីវរ

គ្របគ្រង ឬគ្រប់គ្រង មានន័យថា បីបាច់, ថែរក្សា, ថែទាំដោយទទួលរងបន្ទុក រងខុសត្រូវលើខ្លួន។[1]

ដូច្នេះ ពាក្យថាគ្រប់គ្រងនេះ យើងអាចឱ្យនិយមន័យជារួមថា គឺជាដំណើរការនៃការអនុវត្ត ចាត់ចែង និង គ្រប់គ្រងការងារ ដើម្បីសម្រេចនូវគោលដៅរបស់អង្គភាព ឬស្ថាប័នណាមួយ ដោយមានទំនួលខុសត្រូវខ្ពស់ ដើម្បីធ្វើឱ្យការងារនោះមានប្រសិទ្ធភាពល្អប្រសើរទៅតាមការរំពឹងទុក។

### ១.១.២. និយមន័យរដ្ឋបាល

ពាក្យថា "រដ្ឋបាល" ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើន ប៉ុន្តែនៅក្នុងទីនេះយើងសូមលើកយក អត្ថន័យសំខាន់ៗ បី មកបង្ហាញគឺៈ

**ក. អត្ថន័យអក្សរសាស្ត្រ**

រដ្ឋបាល មកពីពាក្យថា រដ្ឋ+បាល

រដ្ឋ (ជាពាក្យបាលី) មានន័យថា ដែន ប្រទេស អ្នកនៅដែន រាស្ត្រ ប្រជាជន។[2]

ឧទាហណ៍ៈ រដ្ឋធម្មនុញ្ញរដ្ឋការ រដ្ឋកិច្ច រដ្ឋាភិបាល ជាដើម។ល។

---

[1] សម្តេចព្រះសង្ឃរាជជួនណាត,*វចនានុក្រមខ្មែរ* (ភ្នំពេញៈពុទ្ធសាសនបណ្ឌិត្យ ,១៩៦៧), ១៥០។

[2] សម្តេចព្រះសង្ឃរាជជួនណាត,*វចនានុក្រមខ្មែរ* (ភ្នំពេញៈពុទ្ធសាសនបណ្ឌិត្យ ,១៩៦៧), ៩៧៥។

បាល (ជាពាក្យបាលី) មានន័យថា ការថែរក្សា ការគ្រប់គ្រង។ សរុបសេចក្តីមក រដ្ឋបាលមានន័យថា អ្នករក្សាដែន ឬប្រទេស។ ឧទាហរណ៍ៈ ក្រសួង រាជការកាន់កាប់កិច្ចការក្នុងប្រទេសជាគូគ្នានឹងតុលាការ មន្ត្រី ខាងរដ្ឋបាល, ក្របខ័ណ្ឌខាងរដ្ឋបាល។

**ខ. អត្ថន័យទូលាយតាមបែបបច្ចេកទេស**

រដ្ឋបាលមានន័យពីរ ដែលអាចប្រើបានទាំងវិស័យសាធារណៈ និងវិស័យឯកជន។

តាមអត្ថន័យទី១ «រដ្ឋបាល» សំដៅដល់ «សកម្មភាព» ឧទាហរណ៍ៈ កិច្ចការរបស់ក្រុមហ៊ុនកាត់ដេរ (វិស័យឯកជន), កិច្ចការរបស់ក្រសួងទេសចរណ៍ (វិស័យសាធារណៈ)។ [3]

តាមអត្ថន័យទី២ «រដ្ឋបាល» សំដៅដល់ «អង្គការ» ឧទាហរណ៍ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាហារ៉ែណនីហរ័ណ (វិស័យឯកជន), ក្រសួងទេសចរណ៍ (វិស័យសាធារណៈ)។[3]

**គ. អត្ថន័យចង្អៀតតាមបែបបច្ចេកទេស**

ពាក្យ «រដ្ឋបាល» សំដៅដល់ «រដ្ឋបាលសាធារណៈ» ។ យើងអាចប្រើប្រាស់ពាក្យថា «រដ្ឋការ» ឬ «រាជការ» ដែលមិននាំឱ្យមានការភ័ន្តច្រឡំជាមួយនឹងពាក្យ «រដ្ឋបាល» ក្នុងវិស័យឯកជន។ រាជការ សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពនីមួយៗរបស់រដ្ឋដែលមានមន្ត្រីរាជការស្ថិតក្នុងក្របខ័ណ្ឌរដ្ឋ បម្រើការងាររដ្ឋ មានមុខតំណែងតួនាទី និងទទួលប្រាក់បៀវត្សពីរដ្ឋ។ សរុបសេចក្តីមក រដ្ឋបាលមានន័យថា ការគ្រប់គ្រងរដ្ឋមួយដែលអាជ្ញាធរធ្វើការរៀបចំគ្រប់គ្រងចាត់ចែង ដើម្បីបម្រើរាស្ត្រប្រជាឱ្យបានកាន់តែល្អប្រសើរឡើង សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅ ឆ្ពោះទៅកាន់ការកាត់បន្ថយភាពក្រីក្រ។

**១.១.៣.និយមន័យរដ្ឋបាលសាធារណៈ**

ចំណែកឯពាក្យ **រដ្ឋបាលសាធារណៈ** មានន័យដូចខាងក្រោម៖

– ការឱ្យនិយមន័យទៅលើពាក្យ **រដ្ឋបាលសាធារណៈ** មានច្រើន និងមានលក្ខណៈស្មុគស្មាញដោយផ្អែកទៅប្រព័ន្ធលើពិភពលោកយើងនេះ ជាពិសេសនៅក្នុងការគ្រប់គ្រងរដ្ឋបាលនៃប្រព័ន្ធច្បាប់ Common Law និងCivil Law។ ទស្សនៈវិទូខាងច្បាប់មួយចំនួនបាននិយមន័យខុសប្លែកៗពីគ្នាដូចជា៖

- លោក រ៉ូល ហ្គូសមេន (Raul Guzment)យល់ថា ទីណាមានរដ្ឋាភិបាលទីនោះត្រូវមានរដ្ឋបាលសាធារណៈ មានន័យថារដ្ឋបាលសាធារណៈ គឺជាកិច្ចសហប្រតិបត្តិការរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលដើម្បីសម្រេចបានគោលដៅអ្វីមួយក្នុងការបម្រើផលប្រយោជន៍សាធារណៈ។

[3] បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ*,(បោះពុម្ពលើកទី៤៖បណ្ណាគារ អង្គរ,២០០៦), ១១។

- លោក រ៉ូប៊ីត ព្រីសធូស (Robert Presthus) យល់ថា រដ្ឋបាលសាធារណៈ គឺជាទិដ្ឋភាពនៃ ការគ្រប់គ្រង ដែលធ្វើឡើងដោយភ្នាក់ងារផ្លូវការរបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់។ លើសពីនេះទៅទៀត កាលណាគេ និយាយពីពាក្យ រដ្ឋបាលសាធារណៈ គឺចង់និយាយសំដៅទៅលើរដ្ឋបាល ឬរាជការ។

– បើផ្អែកតាមការឱ្យនិយមន័យ នៃរដ្ឋបាលសាធារណៈនៅក្នុងនីតិរដ្ឋបាលវិញវាមានន័យពីរយ៉ាងគឺៈ ទីមួយ តាមមុខងារ ឬសកម្មភាព និងទីពីរន័យតាមអង្គការ។ ន័យទាំងពីរនេះអាចប្រើបានទាំងវិស័យ ឯកជន និង វិស័យសាធារណៈ។ ឧទាហរណ៍ កិច្ចការរដ្ឋបាលក្រុមហ៊ុនម៉ាស៊ីនកិនស្រូវ (វិស័យឯកជន) កិច្ចការរដ្ឋបាល របស់ក្រសួងពាណិជ្ជកម្ម (វិស័យសាធារណៈ)។ មុខងាររដ្ឋបាលសំដៅទៅលើការបម្រើ ដែលមានប្រភពដើម ចេញពីភាសាឡាតាំង Minister មានន័យថា បាវបម្រើ។ មុខងាររដ្ឋបាលកាលពីសម័យចក្រភពរ៉ូម៉ាំង ជា មុខងារអនុវត្តច្បាប់ (នីតិប្រតិបត្តិ)។ នាពេលបច្ចុប្បន្ននេះរដ្ឋបាលសាធារណៈ លែងមានមុខងារនៅក្នុងការធ្វើ សេចក្តីសម្រេចផ្សេងៗ។

តាមន័យមុខងាររដ្ឋបាលសាធារណៈ គឺជាសកម្មភាពក្នុងការបំពេញសេចក្តីត្រូវការរបស់សមូហភាព ឬផល ប្រយោជន៍រួមលើកលែងតែសកម្មភាពរបស់នីតិប្បញ្ញត្តិ និងតុលាការដែលមានរបបគតិយុត្តផ្ទាល់ខ្លួន។[4]

រីឯតាមន័យអង្គការវិញ រដ្ឋបាលសាធារណៈ គឺជាសកម្មភាពរបស់អង្គការ ដែលមានតួនាទីបម្រើផល ប្រយោជន៍ទូទៅទោះបីជាអង្គការនោះមានលក្ខន្តិកៈបែបណាក៏ដោយ(អង្គការមានលក្ខន្តិកៈខុសគ្នា) ឧទាហរណ៍ បុគ្គលសាធារណៈ (រដ្ឋ គ្រឹះស្ថានសាធារណៈ...) បុគ្គលឯកជន ក្រុមហ៊ុន សហគមន៍អង្គការ...) និងគណៈវិជ្ជា ជីវៈ (គណៈមេធាវី...)។

ម្យ៉ាងវិញទៀត គេបានឱ្យនិយមន័យរដ្ឋបាលសាធារណៈ ដោយផ្អែកទៅលើនិយមន័យបែបនយោបាយ តាមច្បាប់ តាមការគ្រប់គ្រង និងតាមអាជីព។

- តាមបែបច្បាប់ រដ្ឋបាលសាធារណៈជាច្បាប់ដែលកំពុងចូលជាធរមាន (កំពុងអនុវត្ត)
- តាមការគ្រប់គ្រង រដ្ឋបាលសាធារណៈជាសិល្បៈនៃការគ្រប់គ្រងនៅក្នុងរដ្ឋាភិបាល ។
- ចំណែកឯតាមន័យអាជីពវិញ រដ្ឋបាលសាធារណៈ ជាប្រភេទនៃអាជីពមួយ។
- តាមបែបនយោបាយ រដ្ឋបាលសាធារណៈ គឺជាជំហាននៃការធ្វើគោលនយោបាយសាធារណៈ។

[4] ក្រសួងមហាផ្ទៃ,*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ*,ឆ្នាំ២០១៧។

## ១.២.ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា

### ១.២.១.ប្រវត្តិអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

តាមការសិក្សាស្រាវជ្រាវ ប្រទេសកម្ពុជាមានប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានជាយូរណាស់មកហើយ។ ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននេះ មានការប្រែប្រួលពីរបបនយោបាយមួយទៅរបបនយោបាយមួយទៀត ផ្អែកទៅតាមស្ថានភាពនយោបាយ ប្រជាសាស្ត្រ ភូមិសាស្ត្រ សេដ្ឋកិច្ច និងសង្គមនៅក្នុងសម័យកាលនីមួយៗ។

**ក. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាមុនឆ្នាំ១៩០៨**

មុនឆ្នាំ១៩០៨ កម្ពុជាត្រូវបានបែងចែកជាតំបន់គ្រប់គ្រងដោយស្តេចត្រាញ់ដែលជាអ្នកមានមុខមាត់មានកិត្តិយសនៅក្នុងព្រះរាជវាំង។ តំបន់ទាំងនេះ មានខេត្តចំណុះដែលគ្រប់គ្រងដោយ ចៅហ្វាយស្រុក ឬអភិបាលដែលត្រូវបានតែងតាំង។ ចៅហ្វាយស្រុកមានអ្នកនៅក្រោមបង្គាប់ដែលជាភ្នាក់ងារប្រតិបត្តិដូចជា balat, snàng, kralapéas។ អ្នកទាំងនេះស្នាក់នៅ និងធ្វើការជាមួយចៅហ្វាយស្រុក និងជាអ្នកពាំនាំនូវបទបញ្ជា ឬនាំយកនូវការបង្គាប់បញ្ជារបស់ចៅហ្វាយស្រុកទៅឱ្យមេស្រុក។ មេស្រុក ត្រូវបានចាត់ទុកជាអ្នកគ្រប់គ្រងភូមិ និងជាអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយអភិបាលដើម្បីប្រមូលពន្ធ និងទទួលខុសត្រូវនៅតាមកន្លែងនីមួយៗនៅក្នុងស្រុក ឬខេត្តដែលខ្លួនគ្រប់គ្រង។ ការអនុវត្តការងាររបស់មេស្រុកពុំមានវិធានរដ្ឋបាលកំណត់ច្បាស់លាស់ទេ។ មេស្រុកភាគច្រើនមិនចេះអក្សរ មិនមានឥទ្ធិពល និងគ្មានអំណាច ហើយការចូលបំពេញការងាររបស់អ្នកទាំងនោះ គឺតាមរយៈទំនាក់ទំនងជាមួយស្តេចត្រាញ់ ឬចៅហ្វាយស្រុក។ នៅពេលនោះ ភូមិមិនមានបុគ្គលភាពគតិយុត្ត និងមិនមានទ្រព្យសម្បត្តិអ្វីទាំងអស់។ ភូមិ គឺជាតំបន់ដែលកើតឡើងពីការប្រមូលផ្តុំនូវតំបន់តូចៗដាក់បញ្ចូលគ្នា។ កិច្ចការរដ្ឋបាលសាធារណៈទាំងឡាយគឺធ្វើផ្ទាល់ជាមួយប្រជាជននៅក្នុងភូមិហើយប្រជាពលរដ្ឋមិនមានតំណាងស្របច្បាប់ដើម្បីការពារផលប្រយោជន៍របស់ខ្លួនឡើយ។[5]

**ខ.អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩០៨ ដល់ឆ្នាំ១៩៥៥**

ការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្មី បានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩០៨ តាមរយៈការដាក់ឱ្យប្រើនូវក្រឹត្យច្បាប់ស្តីពីការរៀបចំរដ្ឋបាលឃុំ ដែលចូលជាធរមាននៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ១៩០៨។ ក្រឹត្យនេះបានលុបចោលនូវរបៀបគ្រប់គ្រងដែនដីដោយស្តេចត្រាញ់ ហើយបានរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងតាមឃុំវិញ។ ផ្អែកតាមស្មារតីក្រឹត្យនេះ ទឹកដីកម្ពុជាចែកចេញជាខេត្ត ស្រុក ឃុំ និង ភូមិ។ តាមរយៈការរៀបចំថ្មីនេះ អភិបាលដែលពីមុនហៅថា “ចៅហ្វាយស្រុក” បានក្លាយទៅជា “ចៅហ្វាយខេត្ត” ហើយ “មេស្រុក” បានក្លាយជា “មេឃុំ”។ ទន្ទឹមនេះក្រឹត្យនេះបានតម្រូវឱ្យមេឃុំត្រូវធ្វើការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយប្រជាជននៅក្នុងឃុំដើម្បី

[5] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ* ,ឆ្នាំ២០១៨។

បំពេញតួនាទីនៅក្នុងឃុំតាមរយៈមុខងារ និងធនធានដែលផ្តល់ឱ្យដោយក្រឹត្យនេះ។ គួរកត់សម្គាល់ថា មុនឆ្នាំ ១៩០៨ ឃុំពុំទាន់មាននៅឡើយទេ គឺមានតែថ្នាក់ខេត្ត ស្រុក និងភូមិប៉ុណ្ណោះ។

ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩០៨ មានភាពខ្វះចន្លោះជាច្រើននៅពេលអនុវត្តជាក់ស្តែង ជាពិសេសការរៀបចំប្រព័ន្ធគ្រប់គ្រងនៅក្នុងក្រឹត្យនេះ មិនអាចធ្វើឱ្យក្រុមប្រឹក្សាឃុំបំពេញតួនាទីប្រកបដោយប្រសិទ្ធភាពបានឡើយ ដោយសារចំនួនដ៏ច្រើនលើសលប់នៃក្រុមប្រឹក្សាឃុំ។ នៅក្នុងឃុំខ្លះចំនួនក្រុមប្រឹក្សាជាប់ឆ្នោតបានកើនដល់១៥០រូប។ ម្យ៉ាងទៀត ការការពារផលប្រយោជន៍សមូហភាព ឬការអភិវឌ្ឍនៅមូលដ្ឋានមិនអាចធ្វើទៅបានប្រសើរឡើយ ដោយសារហិរញ្ញវត្ថុឃុំមិនមានគ្រប់គ្រាន់។

នៅក្នុងឆ្នាំ១៩១៩ ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩០៨ ត្រូវបានកែសម្រួលឡើងវិញតាមរយៈ ការបំពេញបន្ថែម និងកែលម្អនូវភាពខ្វះចន្លោះដែលមានកន្លងមក។ ក្រឹត្យច្បាប់គ្រប់គ្រងឃុំកែសម្រួលនេះបានបញ្ជាក់កាន់តែច្បាស់អំពីមុខងារ និងសមត្ថកិច្ចរបស់ឃុំ ព្រមទាំងប្រព័ន្ធត្រួតពិនិត្យអំពីការអនុវត្តមុខងារ និងសមត្ថកិច្ចរបស់ឃុំ ដោយចៅហ្វាយខេត្ត និងប្រជាជននៅក្នុងឃុំ។ ទន្ទឹមនេះ ក៏បង្កើតឱ្យមានថវិកាឃុំដែលតាមរយៈថវិកាឃុំនេះ មេឃុំអាចធ្វើការជ្រើសរើសបុគ្គលិកមកជួយធ្វើការ ឬបង្ហាត់បង្រៀនអំពីការងារ ដូចជាស្មៀន និងគ្រូបង្រៀនជាដើម ដើម្បីអាចធានាបាននូវដំណើរការជាប្រក្រតីនៃកិច្ចការរដ្ឋបាលរបស់ឃុំ។ ចាប់ពីពេលនោះមក មេឃុំមានតួនាទីជាអ្នកធានាចាត់ចែងកាន់កាប់បញ្ជីរដ្ឋបាល និងថែរក្សាឯកសារ លិខិតស្នាមផ្សេងៗរបស់ឃុំ ដោយមានបុគ្គលិកជាប់កិច្ចសន្យាជួយការងារទូទៅ។ មុខងារពាក់ព័ន្ធនឹងវិស័យអប់រំសាធារណៈត្រូវបានប្រគល់ឱ្យឃុំជាអ្នកគ្រប់គ្រង ដោយប្រើប្រាស់ថវិកា និងប្រភពហិរញ្ញវត្ថុផ្សេងៗរបស់ឃុំ ដែលក្នុងនោះឃុំអាចធ្វើការតែងតាំងគ្រូបង្រៀនក៏ដូចការសាងសង់សាលារៀនបន្ថែម។ ជារួម ការកែសម្រួលនេះបានធ្វើឱ្យប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលឃុំមានលក្ខណៈប្រសើរជាងមុន។

ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩១៩នេះ បានកំណត់ច្បាស់អំពីកិច្ចការរបស់ឃុំ។ ក្រឹត្យនេះ បែងចែកជា០៨ជំពូក។ ក្នុងនោះ ០៣ជំពូកដំបូង បញ្ញត្តិអំពីវិធានដែលពាក់ព័ន្ធនឹងដែនដី និងរដ្ឋបាល។ ជាពិសេស មាត្រា១០ កំណត់អំពីការរៀបចំឱ្យមានក្រុមប្រឹក្សាឃុំដែលចំនួនក្រុមប្រឹក្សាឃុំ តំណាងឱ្យប្រជាជនត្រូវសមាមាត្រទៅនឹងចំនួន ភូមិ។ ចំនួនក្រុមប្រឹក្សាឃុំត្រូវបានកំណត់ចាប់ពី០៨រូប ទៅ ១៦រូប អាស្រ័យទៅតាមទំហំនៃឃុំ។ ចំនួនមេឃុំរង ឬជំទប់ ត្រូវបានបង្កើនសម្រាប់ឃុំដែលមានភូមិច្រើនជាង១៨សំដៅជួយសម្រួលដល់ការបំពេញការងាររបស់មេឃុំ ដែលឃុំមួយចំនួនអាចមានជំទប់០២រូប ដើម្បីជួយមេឃុំ។ ទន្ទឹមនេះ ក៏បានរៀបចំឱ្យមានមេភូមិ ដើម្បីជួយដល់អាជ្ញាធរប្រតិបត្តិ ក៏ដូចការបង្កើននូវមធ្យោបាយក្នុងការធ្វើសកម្មភាព។ ជំពូកទី០៤ និងជំពូកទី០៥ ចែងអំពីតួនាទី ភារកិច្ច កាតព្វកិច្ច និងអត្ថប្រយោជន៍សម្រាប់អាជ្ញាធរឃុំ និងបញ្ជាក់អំពីកាតព្វកិច្ចរបស់ប្រជាជននៅក្នុងឃុំ និងផលប្រយោជន៍ដែលប្រជាជនអាចទទួលបាន។ មាត្រា៣២ បានបញ្ញត្តិអំពី ការផ្តល់សិទ្ធិឱ្យឃុំធ្វើការ

ជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា។ ជំពូកទី០៦ ចែងពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ ទាំងចលនវត្ថុ អចលនវត្ថុរបស់ឃុំ ព្រមទាំងការគ្រប់គ្រងប្រភពចំណូល។ ជំពូកទី០៧ និងទី០៨ បញ្ញត្តិអំពីការរៀបចំថវិកាឃុំដោយមានការចូលរួមពីឃុំ។ ទន្ទឹមនេះ វិធាននៃការរៀបចំ ការប្រើប្រាស់ និងការត្រួតពិនិត្យថវិកា គឺមានភាពងាយស្រួល សាមញ្ញ នៅក្នុងគោលគំនិតនៃវិមជ្ឈការ ដែលធ្វើឱ្យមានភាពងាយស្រួលដល់ប្រជាជននិងអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ប្រតិបត្តិការថវិកាឃុំ។ ក្រឹត្យច្បាប់គ្រប់គ្រងឃុំកែសម្រួលនេះ ត្រូវបានចូលជាធរមាននៅថ្ងៃ ទី២៤ ខែកញ្ញា ឆ្នាំ១៩១៩ និងដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩២០។

ម្យ៉ាងទៀត ដើរទន្ទឹមការរៀបចំប្រព័ន្ធយុត្តិធម៌ និង កំណែទម្រង់រដ្ឋបាលសាធារណៈដែលបានចូលជាធរមាននៅឆ្នាំ១៩២៣ ក្រឹត្យច្បាប់គ្រប់គ្រងឃុំត្រូវបានកែសម្រួលឡើងវិញក្នុងឆ្នាំ១៩២៥ ហើយបានចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩២៦។ ក្រឹត្យច្បាប់ឆ្នាំ១៩២៦ បានបញ្ជាក់កាន់តែច្បាស់ អំពីការជ្រើសរើសក្រុមប្រឹក្សាឃុំ មេឃុំ ការចូលកាន់តំណែង ប្រព័ន្ធគ្រប់គ្រង និងរបៀបរបបការងារ នៅរដ្ឋបាលឃុំ ការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិឃុំ ព្រមទាំងការងារយុត្តាធិការរបស់ឃុំ។ នៅក្នុង សម័យនោះ ក្រុមប្រឹក្សាឃុំហៅថា ក្រុមជំនុំឃុំ។ មេឃុំ គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តសេចក្តី សម្រេចរបស់ក្រុមជំនុំឃុំ ដោយមានជំទប់ដែលជ្រើសរើសចេញពីក្រុមជំនុំឃុំ ជាអ្នកជួយការងារដល់មេឃុំ។ នៅពេលនោះ មេឃុំមានអាណត្តិការងារ០៤ឆ្នាំ។ ការរៀបចំថ្មីនេះមានលក្ខណៈ ស្រដៀង គ្នាទៅនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងឃុំបច្ចុប្បន្នដែរ។

ជារួម ការរៀបចំប្រព័ន្ធថ្មីនេះបានធ្វើឱ្យឃុំក្លាយជាថ្នាក់រដ្ឋបាលមួយជាក់លាក់ក្នុងប្រព័ន្ធរដ្ឋបាលនៅកម្ពុជា។ តាមរយៈក្រឹត្យច្បាប់ឆ្នាំ១៩២៦ បានផ្តល់នូវសិទ្ធិអំណាច និងធនធានកាន់តែច្រើនដល់ឃុំ ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ដើរទន្ទឹមនឹងការយកចិត្តទុកដាក់ពីរដ្ឋបាលកណ្តាលក្នុងការពង្រឹង និងលើកស្ទួយការទទួលខុសត្រូវរបស់ឃុំផង។

ប៉ុន្តែចាប់ពីឆ្នាំ១៩៤៣មក ប្រឈមមុខនឹងសង្គ្រាមឈ្លានពានការបោះឆ្នោតនៅឃុំត្រូវបានផ្អាកជាបន្តបន្ទាប់ និងត្រូវបានលុបចោលទាំងស្រុងចាប់ពីឆ្នាំ១៩៤៨។ ពេលនោះ មេឃុំ និងជំទប់ឃុំ ត្រូវតែងតាំងដោយអភិបាលខេត្ត ដោយមានការយល់ព្រមពីរ៉េស៊ីដង់។

### គ. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៩

ក្រោយផ្អាកការបោះឆ្នោតនៅថ្នាក់ឃុំប្រមាណ១០ឆ្នាំ មានកិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យមានការបោះឆ្នោតនៅថ្នាក់ឃុំឡើងវិញ។ នៅឆ្នាំ១៩៥៥ មានសារាចរណែនាំមួយដែលណែនាំឱ្យរៀបចំ ការបោះឆ្នោតមេឃុំឡើងវិញ ប៉ុន្តែនៅក្នុងការអនុវត្តពុំសូវទទួលបានលទ្ធផលឡើយគឺមានលក្ខណៈគ្រាន់តែជាការបង្គ្រប់កិច្ចតាមច្បាប់ប៉ុណ្ណោះ ដោយសារតែប្រជាពលរដ្ឋពុំសូវសកម្មក្នុងការចូលរួម និងពុំមានជំនឿទៅលើសមត្ថភាពដឹកនាំរបស់មេឃុំ។

បន្ទាប់មក នៅក្នុងឆ្នាំ១៩៥៩ មានព្រះរាជក្រមមួយទៀតដែលតម្រូវឱ្យមានការបោះឆ្នោត ជ្រើសរើសក្រុមជំនុំឃុំ ហើយបានផ្តល់ឱ្យឃុំនូវឋានៈជានីតិបុគ្គល ដូចក្នុងឆ្នាំ១៩២៦។ ក្រុមជំនុំឃុំ មានអាណត្តិរយៈពេល០៤ឆ្នាំ។ ផ្អែកតាមក្រមនេះ មេឃុំ និងជំទប់ត្រូវជ្រើសរើសពីក្នុងក្រុមជំនុំឃុំ ដែលជាប់ឆ្នោត ដោយសំឡេងភាគច្រើន។ ចៅហ្វាយខេត្ត គឺជាអ្នកចេញដីកាខេត្តប្រកាសសុពលភាព ហើយតែងតាំងមេឃុំ និងក្រុមជំនុំឃុំ។ ទន្ទឹមនេះក្រឹត្យនេះក៏ផ្តល់អំណាចដល់ចៅហ្វាយខេត្តក្នុងការប្រកាសមោឃភាពលិខិតបទដ្ឋានទាំងឡាយរបស់ឃុំ ដែលមានលក្ខណៈអនីត្យានុកូលភាពផងដែរ។ ប៉ុន្តែមិនដល់រយៈពេលបីខែផង ព្រះរាជក្រមនេះត្រូវបានដាក់ព្យួរតាមរយៈការធ្វើប្រជាមតិ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ហើយមេឃុំ ចៅសង្កាត់ និងជំទប់ត្រូវតែងតាំងតាមរយៈដីកាខេត្ត តាមសំណើរបស់អភិបាលស្រុក។

គួរកត់សម្គាល់ថា បន្ទាប់ពីការធ្វើសមាជជាតិលើកទី២០ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៦៥ ពាក្យ សង្កាត់ត្រូវបានចាប់ផ្តើមប្រើប្រាស់សម្រាប់ឃុំនៅក្នុងទីក្រុង។ ក្នុងពេលជាមួយគ្នានោះពាក្យ ចៅហ្វាយខេត្ត ក្រុង ស្រុកក៏ត្រូវផ្លាស់ប្តូរដោយប្រើជំនួសវិញនូវពាក្យ អភិបាល ។

នៅក្នុងរបបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ទោះបីរដ្ឋធម្មនុញ្ញនាសម័យនោះព្យាយាម ធ្វើវិមជ្ឈការនៅគ្រប់ថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិក៏ដោយ ប៉ុន្តែដោយសារតែសង្គ្រាមស៊ីវិល ការបោះឆ្នោតគ្រប់ថ្នាក់នៅមូលដ្ឋានមិនអាចដំណើរការបានឡើយ ហើយមេឃុំនៅតែបន្តតែងតាំងដោយ អភិបាលខេត្ត។

ដោយឡែក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រដ្ឋធម្មនុញ្ញនៃរបបនេះមានតែ ២១មាត្រាប៉ុណ្ណោះ ដែលខ្លឹមសារភាគច្រើនផ្តោតទៅលើអំណាច "យោធា" និង "អង្គការ"។ មាត្រា៩ នៃរដ្ឋធម្មនុញ្ញនេះបានបញ្ញត្តិអំពីរបបដឹកនាំ និងធ្វើការងារជា "របបសមូហភាពដឹកនាំ និងធ្វើការងារ"។ ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែងរបបនេះមិនបានអនុវត្តតាមរដ្ឋធម្មនុញ្ញ ឬច្បាប់អ្វីទាំងអស់។ ក្នុងរបបនេះ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល សេដ្ឋកិច្ច និងសង្គមត្រូវបានបំផ្លាញចោលទាំងស្រុងហើយប្រជាពលរដ្ឋនៅទូទាំងប្រទេសត្រូវបានជម្លៀសទៅធ្វើស្រែចម្ការនៅតាមតំបន់ជនបទ និងរស់នៅប្រមូលផ្តុំ របៀបជា "សហករណ៍" ក្រោមការដឹកនាំ និងបញ្ជាផ្តាច់ការពី "អង្គការ" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាបាត់បង់អាយុជីវិតអស់រាប់លាននាក់ ក្នុងរយៈពេលតែប្រមាណជាងបីឆ្នាំប៉ុណ្ណោះ។ ទន្ទឹមនេះ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងប្រទេសត្រូវបានបំផ្លាញចោលទាំងស្រុង។

### ឃ. អភិបាលកិច្ចមូលដ្ឋាននៅកម្ពុជាចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣

បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យនាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមលើគ្រប់វិស័យ រួមទាំងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលផងត្រូវបានស្តារ និងកសាងឡើងវិញពីលេខសូន្យ។

មកទល់ចុងឆ្នាំ១៩៧៩ មានក្រសួងស្ថាប័នចំនួន១២ ត្រូវបានបង្កើតឡើង និងមានខេត្តចំនួន១៨ និងក្រុង០២ ត្រូវបានរៀបចំចំណុះក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។

នៅថ្ងៃទី ០១ ខែឧសភា ឆ្នាំ១៩៨១ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានធ្វើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដោយមានប្រជាជនចំនួន ៣.៤១៧.៣៣៩នាក់ (៩៧,៨២%) បានចេញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចំនួន១១៧រូប ក្នុងចំណោមបេក្ខជនឈរឈ្មោះបោះឆ្នោត១៤៨រូប។ ក្នុងចំណោមបេក្ខជនជាប់ឆ្នោតទាំង ១១៧រូប មានស្ត្រីចំនួន ២១រូប។ រដ្ឋសភាបានបើក សម័យប្រជុំលើកទី១ ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ ដោយបានបោះឆ្នោតជ្រើសតាំង សម្តេច ជា ស៊ីម ជាប្រធានរដ្ឋសភា។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចូលជាធរមាន។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ បានកំណត់ដែនដីរដ្ឋបាលនៅកម្ពុជាដូចខាងក្រោម៖

- ដែនដីនៃប្រទេសកម្ពុជាចែកជាខេត្ត និងក្រុង។
- ខេត្តចែកជា ស្រុក។ ស្រុកចែកជា ឃុំ។
- ក្រុងចែកជា សង្កាត់។

ដែនដីរដ្ឋបាលនីមួយៗខាងលើ គ្រប់គ្រងដោយអង្គការរដ្ឋអំណាចដែលមានឈ្មោះថា "គណៈកម្មាធិការប្រជាជនបដិវត្តន៍មូលដ្ឋាន"។ សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ឃុំ សង្កាត់ ត្រូវជ្រើសតាំងឡើងដោយប្រជាជននៅក្នុងឃុំ សង្កាត់សាមី តាមរយៈការបោះឆ្នោតជាសកលដោយស្មើភាពដោយចំពោះ និងតាមវិធីជ្រើសរើសសន្លឹកឆ្នោតជាសម្ងាត់។ តំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍ ឃុំ ជាអ្នកបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក។ តំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក ជាអ្នកបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្ត។ ចំណែកតំណាងគណៈកម្មាធិការប្រជាជនបដិវត្តន៍សង្កាត់ជាអ្នកបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ក្រុង។ គណៈកម្មាធិការប្រជាជនបដិវត្តន៍ខេត្ត ក្រុង មានអាណត្តិការងារ០៥ឆ្នាំ។ ចំណែកគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្រុក សង្កាត់ ឃុំ មានអាណត្តិការងារ០៣ឆ្នាំ។

នៅដើមឆ្នាំ១៩៨១ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រជាជនបដិវត្តន៍ ឃុំសង្កាត់បានប្រមាណ៨៥% នៃឃុំសង្កាត់ទូទាំងប្រទេស ដើម្បីពង្រឹង និងលើកកម្ពស់ការទទួលខុសត្រូវរបស់ឃុំសង្កាត់ដែលជាថ្នាក់រដ្ឋបាលចុងក្រោយនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋ។

ក្រោយមក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានធ្វើវិសោធនកម្មដោយបានកែប្រែឈ្មោះប្រទេសមកជា រដ្ឋកម្ពុជាវិញ ក្នុងគោលដៅធ្វើការផ្សះផ្សារ បង្រួបបង្រួមជាតិពី

គ្រប់និន្នាការនយោបាយ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជាឱ្យស្របជាមួយនឹងការវិវត្ត ប្រែប្រួលនៃសភាពការណ៍នយោបាយ សង្គម សេដ្ឋកិច្ចនៅកម្ពុជាក្នុងតំបន់ និងនៅលើពិភពលោកនាពេលនោះ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ បានធ្វើការកែសម្រួលការបែងចែកទឹកដីដូចខាងក្រោម៖

- ដែនដីនៃប្រទេសកម្ពុជាចែកជាខេត្ត និងក្រុង។
- ខេត្តបែងចែកជាទីរួមខេត្ត និងស្រុក។ ទីរួមខេត្តបែងចែកជាសង្កាត់។ ស្រុកបែងចែក ជាឃុំ។
- ក្រុងបែងចែកជាខណ្ឌ និងស្រុកជាយក្រុង។ ខណ្ឌបែងចែកជា សង្កាត់។ ស្រុកជាយក្រុងបែងចែកជាឃុំ ដូចស្រុកចំណុះខេត្ត។

ចំពោះរចនាសម្ព័ន្ធគ្រប់គ្រង និងអាណត្តិការងារនៅតាមដែនដីរដ្ឋបាលនីមួយៗ មានលក្ខណៈ ប្រហាក់ប្រហែលគ្នាទៅនឹងការរៀបចំតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ដែរ ដោយគ្រាន់តែប្តូរឈ្មោះពីគណៈ កម្មាធិការប្រជាជនបដិវត្តន៍ មកជា គណៈកម្មាធិការប្រជាជនវិញ។

**ង. អភិបាលកិច្ចមូលដ្ឋានក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣**

សង្គ្រាមស៊ីវិលដែលបានអូសបន្លាយប្រមាណបីទសវត្សរ៍ មិនត្រឹមតែបានបន្ទុចបង្អាក់ការអភិវឌ្ឍនៅកម្ពុជា លើគ្រប់វិស័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនូវរចនាសម្ព័ន្ធ ប្រព័ន្ធនយោបាយ រដ្ឋបាល សង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៩។ ក្រោយឆ្នាំ១៩៧៩ សង្គ្រាមស៊ីវិលនៅតែបន្តកើតមាននៅតាមតំបន់មួយចំនួនក្នុងប្រទេស។ ទោះយ៉ាងនេះក្តី រដ្ឋាភិបាលកម្ពុជានាពេលនោះបានខិតខំរិះរកគ្រប់មធ្យោបាយដើម្បីស្តារ និងអភិវឌ្ឍប្រទេសជាតិឡើងវិញលើគ្រប់វិស័យ ក្នុងនោះរួមទាំងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមានសមត្ថភាពក្នុងការថែរក្សាសន្តិសុខសុវត្ថិភាពតាមមូលដ្ឋានទប់ទល់ការប៉ុនប៉ង វិលត្រឡប់មកកាន់កាប់អំណាចឡើងវិញនូវរបបខ្មែរក្រហមផង និងម្ចាស់ការដោះស្រាយតម្រូវការជីវភាពរបស់ប្រជាជនតាមមូលដ្ឋានរៀងៗខ្លួនក្នុងពេលដែលកម្ពុជាត្រូវទទួលរងការហ៊ុំព័ទ្ធពីខាងក្រៅ។

ក្នុងគោលបំណងធ្វើការផ្សះផ្សាបង្រួបបង្រួមជាតិ បញ្ចប់សង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ដើម្បីនាំមកនូវសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី សំដៅធ្វើការកសាងជាតិឡើងវិញលើគ្រប់វិស័យ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានសម្រេចចិត្តធ្វើការចរចាសម្របសម្រួលជាមួយភាគីជម្លោះនានាក្នុងសង្គ្រាមស៊ីវិលនៅកម្ពុជា រហូតសម្រេចបាន "កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស" ស្តីពីដំណោះស្រាយនយោបាយនៅកម្ពុជានាថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១។

ផ្អែកលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅខែ ឧសភា ឆ្នាំ១៩៩៣ កម្ពុជាបានធ្វើការបោះឆ្នោតដោយផ្ទាល់ជ្រើសរើសតំណាងរាស្ត្រតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាលើកដំបូង បន្ទាប់

ពីជម្លោះផ្ទៃក្នុង និងសង្គ្រាមស៊ីវិលដែលអូសបន្លាយជិត០៣ទសវត្សរ៍។ ការបោះឆ្នោតនេះ ត្រូវបានរៀបចំឡើងក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិ និងមានការចូលរួម ពីគណបក្សនយោបាយចំនួន២០។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលត្រូវបានតាក់តែងរៀបចំជាថ្មីបានកំណត់ថា កម្ពុជាជាប្រទេសប្រកាន់យករបបគ្រប់គ្រងតាមបែបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញតាមលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងសេដ្ឋកិច្ចទីផ្សារសេរី។

រដ្ឋធម្មនុញ្ញនេះបានបែងចែកដែនដីរដ្ឋបាល ដូចខាងក្រោម៖

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជាខេត្ត និងក្រុង
- ខេត្តចែកជា ស្រុក។ ស្រុកចែកជា ឃុំ។
- ក្រុងចែកជា ខណ្ឌ។ ខណ្ឌចែកជា សង្កាត់។

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ មានបញ្ហាប្រឈមនានាជាច្រើនដែលត្រូវដោះស្រាយក្នុងការរៀបចំប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងប្រទេសឡើងវិញ។ ក្នុងនោះបញ្ហាដំបូងបំផុត គឺការសម្របសម្រួលខាងនយោបាយ ដើម្បីបង្កើតរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី១ នៃរដ្ឋសភាដែលត្រូវការសំឡេងគាំទ្រ ២/៣ ពីរដ្ឋសភា។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិចបានព្រមព្រៀងគ្នារៀបចំរាជរដ្ឋាភិបាលចម្រុះដែលមានសហនាយករដ្ឋមន្ត្រី និងមានក្រសួងសំខាន់ៗចំនួន០៣ ដែលដឹកនាំដោយសហរដ្ឋមន្ត្រី រួមមានទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ។ ក្រសួង ស្ថាប័នក្រៅពីនេះក៏ត្រូវបានបែងចែកគ្នាគ្រប់គ្រងក្នុងរាជរដ្ឋាភិបាលចម្រុះផងដែរ។ ទន្ទឹមនេះ កងទ័ព នគរបាល មន្ត្រីរដ្ឋបាលស៊ីវិលពីភាគីគណបក្សហ្វ៊ុនស៊ិនប៉ិចដែលមានសំឡេងភាគច្រើនក្នុងរដ្ឋសភា និងភាគីគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាដែលមានអាសនៈលំដាប់ទី៣ក្នុងរដ្ឋសភាក៏ត្រូវបានធ្វើសមាហរណកម្មជាមួយភាគីអតីតរដ្ឋកម្ពុជា ដឹកនាំដោយគណបក្សប្រជាជន កម្ពុជា ជាភាគីដែលមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងគ្របដណ្តប់ទឹកដីប្រមាណ ៩០% ឱ្យទៅជាកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីរដ្ឋបាលស៊ីវិលតែមួយក្រោមដំបូលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣តែមួយ។

ដោយឡែកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឡើងវិញ និងធ្វើការបែងចែកមុខតំណែងអភិបាល អភិបាលរងខេត្ត ក្រុង ក្នុងចំណោមគណបក្ស នយោបាយក្នុងរាជរដ្ឋាភិបាលចម្រុះ ក្នុងនោះមានរាជធានីភ្នំពេញ និងខេត្តចំនួន១០ គណបក្សហ្វ៊ុន ស៊ិនប៉ិចទទួលមុខតំណែងជាអភិបាល និងខេត្តចំនួន១០ទៀត គណបក្សប្រជាជនកម្ពុជាទទួលមុខ តំណែងជាអភិបាល។ ការបែងចែកមុខតំណែងអភិបាល អភិបាលរងក្នុងចំណោមគណបក្ស នយោបាយ ក្នុងរាជរដ្ឋាភិបាលចម្រុះនេះ ត្រូវបានបញ្ចប់នៅចុងអាណត្តិទី២

និងដើមអាណត្តិទី៣ នៃរដ្ឋសភា ដោយ គណបក្សប្រជាជនកម្ពុជាដែលជាគណបក្សទទួលបានសំឡេងភាគច្រើននៅក្នុងរដ្ឋសភា ជាអ្នកទទួល បានមុខតំណែងអភិបាលរាជធានី ខេត្តទាំងអស់។

ចំពោះថ្នាក់ស្រុក ខណ្ឌ ឃុំ សង្កាត់ ក៏បានធ្វើការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ប៉ុន្តែក្នុងអាណត្តិទី១ និងដើមអាណត្តិទី២នៃរាជរដ្ឋាភិបាលចម្រុះ មិនមានការចុះសម្រុងគ្នាក្នុងការសម្របសម្រួលខាងនយោបាយដើម្បីបែងចែកអំណាចនៅថ្នាក់រដ្ឋបាលទាំងនេះឡើយ។ តាមរយៈការរៀបចំឡើងវិញនេះបានធ្វើឱ្យរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ មានលក្ខណៈជាការគ្រប់គ្រងបែបមជ្ឈការវិញ។ តួនាទី មុខងារ អំណាច ធនធាន ទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលបានផ្តល់យ៉ាងក្រាស់ក្រែល។

មុនឆ្នាំ ១៩៩៣ ដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជារដ្ឋបាលប្រកបដោយថាមភាពគ្រប់វិស័យនៅមូលដ្ឋានត្រូវបានដកហូតមកក្រោមការគ្រប់គ្រងរបស់ថ្នាក់ជាតិ តាមប្រព័ន្ធខ្សែបណ្តោយវិញ ។ សាលាខេត្ត សាលាក្រុង ត្រូវស្ថិតនៅជាខ្សែបណ្តោយរបស់ក្រសួងមហាផ្ទៃ។ សាលាស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបានចាត់ទុកជាសាខា ឬអង្គភាពមួយរបស់សាលាខេត្ត ឬសាលាក្រុងសាមី។ តាមប្រព័ន្ធនេះ ទំនាក់ទំនងរវាងថ្នាក់ជាតិជាមួយថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតែជាមួយខេត្ត ក្រុងតែប៉ុណ្ណោះ។ នៅពេលនោះ រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិមានស្ថានភាពដូចជារដ្ឋបាលចាំផ្ទះតែប៉ុណ្ណោះ។ រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិ ទទួលបានតែប្រាក់បៀវត្សរ៍មន្ត្រី បុគ្គលិកបម្រើការងារតាមសាលាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងប្រាក់ចំណាយរដ្ឋបាលប្រចាំថ្ងៃតិចតួចដែលស្ថិតក្នុងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។ អាស្រ័យ ដោយតម្រូវការនៃការបែងចែកអំណាចក្នុងក្រសួងមហាផ្ទៃ និងតម្រូវការនៃការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ មុនពេលមានច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ក្នុងអាណត្តិនៃរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី១ នៃរដ្ឋសភា (ក្រសួងមហាផ្ទៃ ត្រូវបានបង្កើតឡើងដោយការច្របាច់បញ្ចូលគ្នារវាងក្រសួងមហាផ្ទៃ និងក្រសួងសន្តិសុខជាតិ តាមព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ)។ ផ្អែកលើអនុក្រឹត្យខាងលើនេះ ក្រសួងមហាផ្ទៃបានចេញប្រកាសលេខ០៣១ ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្តក្រុង។

ស្របពេលដែលរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី១ នៃរដ្ឋសភា ត្រូវរ៉ាប់រងដោះស្រាយបញ្ហាប្រឈមនានាជាច្រើនដែលបន្សល់ទុកដោយសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ភាគីកម្ពុជាប្រជាធិបតេយ្យដែលជាភាគីហត្ថលេខាមួយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមិនបានអនុវត្តកិច្ចព្រមព្រៀងនេះ និងមិនបានចូលរួមបោះឆ្នោតជាតិនាឆ្នាំ១៩៩៣ឡើយ។ ភាគីនេះ បន្តធ្វើសកម្មភាពប្រដាប់អាវុធប្រឆាំង

រាជរដ្ឋាភិបាលស្របច្បាប់ដែលកើតចេញពីការបោះឆ្នោតដើម្បីការពារទឹកដីមួយផ្នែកតូចដែលគេបាន និងកំពុងគ្រប់គ្រងនាពេលនោះ និងប៉ុនប៉ងពង្រីកតំបន់ត្រួតត្រាសំដៅឈានទៅគ្រប់គ្រងប្រទេសឡើងវិញ។

ដើម្បីបញ្ចប់សង្គ្រាម នាំមកនូវសន្តិភាពជូនប្រទេសជាតិ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាពេលនោះ ជានាយករដ្ឋមន្ត្រីទី២ បានផ្តួចផ្តើម និងដាក់ចេញនូវនយោបាយ "ឈ្នះ-ឈ្នះ" ដោយចាប់ផ្តើមពីភូមិសាស្ត្រឱរ៉ាល់ បន្តភ្ជាប់ទៅម៉ាឡៃ ប៉ៃលិន សំឡូត កំរៀង សំពៅលូន ភ្នំព្រឹក និងចុងក្រោយទៅអន្លង់វែង ដោយបានធ្វើសមាហរណកម្មទាំងស្រុងនូវកម្លាំងកម្ពុជាប្រជាធិបតេយ្យនាចុងឆ្នាំ១៩៩៨។ ចាប់ពីពេលនោះមកប្រទេសជាតិមានសន្តិភាពពេញលេញ មានការឯកភាពជាតិ ឯកភាពទឹកដី ដែលត្រូវបានគ្រប់គ្រងក្រោមដំបូលរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ តែមួយ។

ក្នុងស្ថានភាពដ៏អំណោយផលនេះ កម្ពុជាមានការតាំងចិត្តខាងនយោបាយយ៉ាងមុតមាំ ដើម្បីរៀបចំចាត់ចែងបោះឆ្នោតជាតិលើកទី២ដោយខ្លួនផ្ទាល់។ ផ្អែកលើការតាំងចិត្តនេះ ច្បាប់បោះឆ្នោតជាតិត្រូវបានរៀបចំតាក់តែងឡើងដោយមន្ត្រីកម្ពុជា ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុមួយផ្នែកពីសហគមន៍អន្តរជាតិ។ ក្រោមច្បាប់បោះឆ្នោតជាតិនេះ ស្ថាប័នឯករាជ្យមួយត្រូវបានបង្កើតឡើងសម្រាប់ចាត់ចែង រៀបចំការបោះឆ្នោត គឺគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប។

ការបោះឆ្នោតជាតិលើកទី២ បានប្រព្រឹត្តទៅតាមអាណត្តិ ដែលកំណត់ប្រកបដោយជោគជ័យនាខែកក្កដា ឆ្នាំ១៩៩៨។ រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី២ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រត្រីកោណសម្រាប់ជារបៀបវារៈកំណែទម្រង់ការគ្រប់គ្រងប្រទេសជាតិ។

ទោះបីយ៉ាងនេះក្តី គណបក្សក្នុងរាជរដ្ឋាភិបាលចម្រុះនៅតែទាមទារបែងចែកអំណាចនៅ រដ្ឋបាលស្រុក ឃុំ សង្កាត់ និងនៅតាមភូមិនានាទូទាំងប្រទេស។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ គណបក្សប្រជាជនកម្ពុជាបានផ្តួចផ្តើមឱ្យមានការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ដើម្បីប្រកួតប្រជែង ការគ្រប់គ្រងឃុំ សង្កាត់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ គំនិតផ្តួចផ្តើម នេះត្រូវបានទទួលយក និងគាំទ្រដោយគណបក្សហ្វ៊ុនស៊ិនប៉ិច។

ផ្អែកលើគំនិតផ្តួចផ្តើមនេះ ការសម្របសម្រួលខាងនយោបាយ ដើម្បីរៀបចំក្របខ័ណ្ឌគោល នយោបាយសម្រាប់ការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រដ្ឋបាលនេះ ត្រូវបានរៀបចំឡើងនាឆ្នាំ១៩៩៩ និងឈានទៅរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័ត នាខែមករា ឆ្នាំ២០០១។

នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស ចំនួន ១ ៦២១ ឃុំ សង្កាត់ត្រូវបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស។ ចាប់ពីពេលនោះមក កំណែទម្រង់

វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់។ សមិទ្ធផល នៃកំណែទម្រង់ដែលសម្រេចបាននៅថ្នាក់ឃុំ សង្កាត់បានជំរុញ និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ដើម្បីពង្រីកដំណើរការកំណែទម្រង់នេះដល់គ្រប់ថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំ ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥ សម្រាប់ជាមូលដ្ឋានតាក់តែងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយការបោះឆ្នោតនៅថ្នាក់រដ្ឋបាលទាំងនេះត្រូវបានរៀបចំឡើងនាឆ្នាំ២០០៩។

ផ្អែកលើតម្រូវការនៃការកែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីរៀបចំឡើងវិញនូវដែនដីរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានីភ្នំពេញ និងខេត្ត។
- រាជធានីភ្នំពេញចែកជា ខណ្ឌ។ ខណ្ឌចែកជា សង្កាត់។
- ខេត្តចែកជា ក្រុង និងស្រុក។ ក្រុងចែកជា សង្កាត់។ ស្រុកចែកជា ឃុំ និងជា សង្កាត់។

ការរៀបចំដែនដីតាមការបែងចែកនេះ គឺសំដៅរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឱ្យបានជាក់លាក់រវាងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ដែលបានអនុវត្តរហូតមកទល់សព្វថ្ងៃ។

### ១.២.២. វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

#### ក. ចរន្តនៃអភិបាលកិច្ចមូលដ្ឋាន

ការធ្វើកំណែទម្រង់វិមជ្ឈការនៅកម្ពុជាពុំមែនជាយុទ្ធសាស្ត្រ ឬជាមធ្យោបាយពិសេសដោយឡែកសម្រាប់តែនៅកម្ពុជានោះឡើយ។ ចាប់តាំងពីចុងទសវត្សរ៍ទី៩០ វិមជ្ឈការបានក្លាយជាប្រធានបទ និងជាមធ្យោបាយដ៏មានប្រជាប្រិយភាព ដែលត្រូវបានយកទៅអនុវត្តនៅក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតាម បណ្តាប្រទេសនានាជាច្រើននៅលើពិភពលោក រាប់ចាប់តាំងពីតំបន់អាស៊ី អឺរ៉ុប និងអាមេរិកជាដើម។

ទោះជាយ៉ាងនេះក្តី ប្រទេសនីមួយៗអនុវត្តវិមជ្ឈការដោយមានមូលហេតុផ្សេងៗគ្នា ផ្អែកទៅតាមកត្តានយោបាយ ភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីជាដើម។ នៅអឺរ៉ុបខាងកើត និងអតីតសហភាពសូវៀត វិមជ្ឈការគឺជាផ្នែកមួយនៃការផ្លាស់ប្តូរនយោបាយ និងសេដ្ឋកិច្ចដែលកើតឡើងបន្ទាប់ពីការដួលរលំនៃការគ្រប់គ្រងតាមបែបមជ្ឈការយ៉ាងតឹងរ៉ឹងរបស់សហភាពសូវៀត។ នៅអាហ្វ្រិចខាងត្បូង និងស្រីលង្កា វិមជ្ឈការគឺជាយុទ្ធសាស្ត្រ ដើម្បីបន្ធូរបន្ថយបញ្ហាខ្វែងគំនិតគ្នា ក៏ដូចជាជម្លោះក្នុងចំណោមជនជាតិ ឬតំបន់។ យុទ្ធសាស្ត្រនេះក៏ត្រូវបានអនុវត្តនៅឥណ្ឌូនេស៊ី ដោយសារឥណ្ឌូនេស៊ីជាប្រទេសពោរពេញទៅដោយប្រជុំកោះមានទំហំធំប្រជាជនច្រើន និងសំបូរទៅដោយជនជាតិផ្សេងៗ។[6]

---

[6] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ* ,ឆ្នាំ២០១៨។

ក្រៅពីមូលហេតុខាងលើ ជាទូទៅវិមជ្ឈការត្រូវបានគេមើលឃើញថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហាភាពក្រីក្រ វិសមភាពយេនឌ័រ បញ្ហាបរិស្ថាន និងការលើកកម្ពស់ ការថែទាំសុខភាព ការអប់រំ និងការទទួលបានបច្ចេកវិទ្យា។ ទន្ទឹមនេះ វិមជ្ឈការមិនត្រឹមតែជះឥទ្ធិពលដល់រដ្ឋាភិបាល និងការផ្តល់សេវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាលក្ខខណ្ឌចាំបាច់ក្នុងការទាក់ទាញ អង្គការ សហគមន៍ អ្នកពាក់ព័ន្ធក្នុងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងប្រជាពលរដ្ឋថែមទៀតផង។

### ខ. វិមជ្ឈការជាអ្វី?

ក្នុងក្របខ័ណ្ឌទូទៅ វិមជ្ឈការត្រូវបានគេឱ្យនិយមន័យថា ជាដំណើរការមួយដែលសិទ្ធិ អំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈ ត្រូវបានផ្ទេរពីរដ្ឋាភិបាលកណ្តាលទៅឱ្យរដ្ឋាភិបាលមូលដ្ឋាន។ វិមជ្ឈការមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងគោលគំនិតស្តីពី "Subsidiarity" ដែលគោលគំនិតនេះបានកំណត់ថា "រាល់មុខងារត្រូវផ្ទេរទៅឱ្យថ្នាក់ទាបបំផុតណាដែលមានសមត្ថភាពអាចបំពេញមុខងារនោះបាន"។ កម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ (UNDP) បានឱ្យនិយមន័យ នៃ"អភិបាលកិច្ចតាមបែបវិមជ្ឈការ" ថា "ជាការរៀបចំឡើងវិញនូវសមត្ថកិច្ចដើម្បីឱ្យមានប្រព័ន្ធមួយដែលមានការសហការទទួលខុសត្រូវរវាងស្ថាប័នអភិបាលកិច្ចនៅថ្នាក់កណ្តាល ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានដោយឈរលើគោលការណ៍នៃ Subsidiarity ដែលកត្តានេះនឹងនាំមកនូវការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ចដើរទន្ទឹមនឹងការកើនឡើងនូវសិទ្ធិអំណាច និងលទ្ធភាពនៅថ្នាក់ក្រោមជាតិ"។

### គ. អត្ថន័យនៃវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

នៅកម្ពុជា គោលបំណងជាយុទ្ធសាស្ត្រនៅក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានកំណត់នៅក្នុង ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចខាងក្រោម៖

- ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្សនៅកម្ពុជាឱ្យចាក់ឫសរឹងមាំចាប់ពីមូលដ្ឋានមក និង
- ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការចូលរួមកាត់បន្ថយភាពក្រីក្រ។

ក្នុងបរិបទរបស់ប្រទេសកម្ពុជា ពាក្យ វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**វិមជ្ឈការ** គឺជាការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានលើបញ្ហាទាំងនេះ។ ក្នុងន័យនេះ រាល់កិច្ចការនានាដែលបានផ្ទេរវិមជ្ឈការទៅឱ្យក្រុមប្រឹក្សា ក្រុមប្រឹក្សាមានឆន្ទានុសិទ្ធិពេញលេញ ក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការទាំងនោះនៅមូលដ្ឋានរបស់ខ្លួន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏ជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តកិច្ចការទាំងនោះផងដែរ។

**វិសហមជ្ឈការ** គឺជាការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិ អំណាច និង ធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របទៅ តាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ ករណីនេះ ក្រុមប្រឹក្សាអនុវត្តកិច្ចការទាំងនោះតាមការណែនាំ ឬចង្អុល បង្ហាញពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ហើយការទទួលខុសត្រូវចុងក្រោយចំពោះការអនុវត្តកិច្ចការទាំងនេះ នៅតែជារបស់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មដដែល។

ការរៀបចំក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាសម្រាប់គាំទ្រដល់ការអនុវត្តកំណែ ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាត្រូវរៀបចំឡើងក្នុងស្មារតីនៃនិយមន័យ "វិមជ្ឈការ" និង"វិសហមជ្ឈការ" ដូចបានកំណត់ខាងលើនេះ។

### ១.២.២. ក្របខ័ណ្ឌគោលនយោបាយសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ធ្វើការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិចាប់តាំងពីក្រោយ ការបោះឆ្នោតជាតិឆ្នាំ១៩៩៣មក។ ជាពិសេសក្រោយពីប្រទេសជាតិមានសន្តិភាព ការឯកភាពជាតិ ឯកភាពទឹកដី តាមរយៈការអនុវត្តដោយជោគជ័យនូវនយោបាយ "ឈ្នះ-ឈ្នះ"។ រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើការកែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដោយធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សា សង្កាត់នៅទូទាំងប្រទេសនាឆ្នាំ២០០២។ បន្ទាប់មកនៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានបន្តពង្រឹង ពង្រីកការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហសមជ្ឈការនៅថ្នាក់ដទៃទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាម រយៈការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេស។ រាជរដ្ឋាភិបាល បានអនុវត្តកំណែទម្រង់នេះដោយមានការប្រុងប្រយ័ត្នខ្ពស់ និងធ្វើឡើងជាជំហានៗ តាមរយៈការធ្វើបណ្តើរ ដកបទពិសោធន៍បណ្តើរ និងពង្រឹងពង្រីកបណ្តើរ។

នៅក្នុងការអនុវត្តជាជំហានៗនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជាបាន តាក់តែងនូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាជាច្រើន ដែលក្នុងនោះរួមមានក្របខ័ណ្ឌគោល នយោបាយ និងក្របខ័ណ្ឌច្បាប់សំខាន់ៗ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីមួយ ទីពីរ ទីបី និងទីបួន
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

ទន្ទឹមនឹងការដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំនូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលការអនុវត្តកម្មវិធីជាតិនេះ ត្រូវបានចែកចេញជាបីដំណាក់កាលតាមរយៈការរៀបចំឱ្យមាន ផែនការអនុវត្តន៍លម្អិតតាមដំណាក់កាលនីមួយៗ។ រហូតមកទល់ពេលនេះផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី១ (ផអ៣ទី១៖ ២០១១-២០១៤) និងដំណាក់កាលទី២ (ផអ៣ទី២៖ ២០១៥-២០១៧) បានបញ្ចប់ ហើយបច្ចុប្បន្នកំពុងបន្តអនុវត្តផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី៣ (ផអ៣ទី៣) ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធីជាតិ។

**ក. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣**

ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ ទី៤ និងទី៥ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣។ នៅក្នុងឯកសារយុទ្ធសាស្ត្រទាំងបី អភិបាលកិច្ចល្អ ត្រូវបានចាត់ទុកជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងជាបុរេលក្ខខណ្ឌដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌សង្គម។ ដើម្បីសម្រេចបាននូវគោលដៅនៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ធ្វើកំណែទម្រង់លើវិស័យចំនួនបួនរួមមាន៖

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងនោះរួមទាំងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

កំណែទម្រង់ទាំងបួននេះ ត្រូវបានពង្រឹង ពង្រីក និងយកចិត្តទុកដាក់អនុវត្តកាន់តែស៊ីជម្រៅពីដំណាក់កាលមួយទៅដំណាក់កាលមួយ។ ជាពិសេស ពាក់ព័ន្ធកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាកំណែទម្រង់ដ៏មានសារៈសំខាន់បំផុតក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព មានការចូលរួម គណនេយ្យភាព សមធម៌ និងបរិយាប័ន្ន។

**ខ. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ នៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងគោលបំណងកំណត់អំពី៖

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅនៃយុទ្ធសាស្រ្តជាតិក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ក្របខ័ណ្ឌយុទ្ធសាស្រ្តនេះរៀបចំឡើងដោយឈរលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០១។ ផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្រ្តនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើនៅក្នុងឆ្នាំ២០០៨។

ក្នុងការដាក់ឱ្យដំណើរការនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមស្មារតីនៃច្បាប់រៀបចំអង្គការខាងលើបានតម្រូវឱ្យដាក់ចេញនូវព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀតជាច្រើនដើម្បីធានាឱ្យប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានអាចដំណើរការទៅបានប្រកបដោយភាពរលូន មានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

### ១.២.៣. គោលការណ៍នៃការរៀបចំអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

មាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា “រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ”។ មាត្រានេះបានផ្តល់នូវគោលការណ៍សំខាន់០២ ក្នុងការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ទីមួយគឺការរៀបចំរដ្ឋបាលឯកភាព និងទីពីរគឺការធានាបាននូវចីរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅថ្នាក់រដ្ឋបាលទាំងនេះ រួមទាំងរដ្ឋបាលឃុំ សង្កាត់។

ការរៀបចំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជារដ្ឋបាលឯកភាព មានន័យថា ក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលទាំងនេះត្រូវម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធានដែលបានមកពីការផ្ទេរពីថ្នាក់ជាតិទៅឱ្យក្រុមប្រឹក្សា ឬបានមកពីប្រភពនៅមូលដ្ឋាន ឬប្រភពផ្សេងៗទៀត ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួលប្រកបដោយ ប្រសិទ្ធភាពនូវសកម្មភាពនៃការ ផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំង

ការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលសំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ គោលការណ៍ដែលតម្រូវឱ្យរៀបចំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជារដ្ឋបាលឯកភាព គឺដោយសារមុនឆ្នាំ២០០៩ (មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) មុខងារ ធនធាន សមត្ថកិច្ច និងការទទួលខុសត្រូវនៅថ្នាក់រដ្ឋបាលទាំងនេះត្រូវគ្រប់គ្រងតាមខ្សែបណ្តោយតាមវិស័យនានា ដែលប្រព័ន្ធគ្រប់គ្រងនេះតម្រូវឱ្យមន្ទីរ អង្គភាពជំនាញនានាធ្វើគណនេយ្យភាពតាមឋានានុក្រមទៅក្រសួង ស្ថាប័នរបស់ខ្លួន។ ដោយឡែក គោលការណ៍នៃការរៀបចំរដ្ឋបាលឯកភាព គឺសំដៅធានាឱ្យមានការសម្របសម្រួលរវាងខ្សែបណ្តោយ(ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពខ្សែ បណ្តោយ) ជាមួយខ្សែទទឹង (ក្រុមប្រឹក្សាដែលជាប់ឆ្នោត និងគណៈអភិបាលដែលតែងតាំងដោយរាជរដ្ឋាភិបាល) ដើម្បីកែលម្អខ្សែគណនេយ្យភាពសំដៅរួមគ្នាឆ្លើយតបតម្រូវការជាអាទិភាព របស់ប្រជាពលរដ្ឋនៅ មូលដ្ឋាន។

ចំពោះការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គឺជាការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈឆ្លើយតបទៅនឹងសមាសធាតុទាំង០៨ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដូចដែលបានកំណត់ នៅក្នុងមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនោះរួមមាន៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភសិទ្ធិអំណាច។

ការដាក់បញ្ចូលក្នុងក្របខ័ណ្ឌច្បាប់នូវគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មិនសំដៅតែទៅលើរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប៉ុណ្ណោះទេ ប៉ុន្តែគោលការណ៍នេះគ្របដណ្តប់ទាំងថ្នាក់ឃុំ សង្កាត់ផងដែរ។ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានក្រុមប្រឹក្សាដែលបានបង្កើតឡើងតាមការបោះឆ្នោតអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលទាំងនេះ។ រាជរដ្ឋាភិបាលនៅរក្សាសិទ្ធិអំណាចក្នុងការតែងតាំងគណៈអភិបាលដើម្បីអនុវត្តសេចក្តីសម្រេច ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សានៅតាមថ្នាក់

រដ្ឋបាលទាំងនេះ។ ប្រព័ន្ធនេះបានតម្រូវឱ្យរៀបចំឡើងវិញនូវខ្សែគណនេយ្យភាពផ្ទៃក្នុង (ក្រុមប្រឹក្សា និងគណៈអភិបាល) ខ្សែគណនេយ្យភាព និងទំនាក់ទំនងក្នុងចំណោមថ្នាក់រដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ (ទំនាក់ទំនង និងគណនេយ្យភាពរវាងខេត្ត ស្រុក ក្រុង ឃុំ សង្កាត់ និងរវាងរាជធានី ខណ្ឌ សង្កាត់) ទំនាក់ទំនង និងគណនេយ្យភាពរវាងថ្នាក់រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ និងទំនាក់ទំនង និងគណនេយ្យភាពរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដូច្នេះគោលការណ៍ទាំង០៨ខាងលើ គឺជាការកំណត់អំពីមូលដ្ឋានគ្រឹះដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ បែបបទ នីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទំនាក់ទំនង និងគណនេយ្យភាពថ្មីដែលត្រូវបានរៀបចំឡើងដូចបានគូសបញ្ជាក់ខាងលើ។ ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធថ្នាក់ក្រោមជាតិដែលត្រូវរៀបចំឡើងត្រូវធានាឱ្យមានសង្គតិភាពជាមួយគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ខ្លឹមសារសំខាន់ៗនៃគោលការណ៍ទាំង០៨ មានដូចខាងក្រោម៖

**ទី១. ភាពជាតំណាងសាធារណៈ**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស គឺជាការផ្តល់ភាពជាតំណាងសាធារណៈដល់ក្រុមប្រឹក្សាជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើសកម្មភាពនានា ក្នុងនាមផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួនដោយមិនមានការរើសអើងខាងនយោបាយ ពណ៌សម្បុរ ជំនឿ សាសនា ជនជាតិ និងទ្រព្យធននោះឡើយ។

**ទី២. ស្វ័យភាពរបស់មូលដ្ឋាន**

ស្វ័យភាពមូលដ្ឋាន មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នៅមូលដ្ឋានរបស់ខ្លួន។

**ទី៣. ការពិគ្រោះយោបល់ និងការចូលរួម**

ការពិគ្រោះយោបល់ និងការចូលរួម គឺជាកិច្ចដំណើរការដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិស្វែងយល់អំពីបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់សហគមន៍ផ្សេងៗគ្នាក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីរដ្ឋបាលថ្នាក់ក្រោមជាតិដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការដែលមាន លក្ខណៈផ្សេងៗគ្នានៅមូលដ្ឋាន (ឧទាហរណ៍ តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ជរា ជនជាតិ ជនក្រីក្រ...ជាដើម) ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន សំដៅឆ្លើយតបបានកាន់តែប្រសើរទៅនឹងផលប្រយោជន៍ និងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៤. ការឆ្លើយតប និងគណនេយ្យភាព**

ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត ។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

**ទី៥. ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន**

គឺជាកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយ សន្តិភាព សុវត្ថិភាព និងសុខុមាលភាព តាមរយៈការលើកកម្ពស់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងលើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តម្រូវការរបស់ប្រជាពលរដ្ឋ មានលក្ខណៈផ្សេងៗគ្នាទៅតាមសហគមន៍ និងក្រុមប្រជាពលរដ្ឋដែលមានដូចជាយុវជន ស្ត្រី កុមារ ជនពិការ ចាស់ជរា ជនជាតិដើមភាគតិច ក្រុមជនក្រីក្រជាដើម ហេតុនេះក្រុមប្រឹក្សាត្រូវខិតខំស្វែង យល់ឱ្យបានគ្រប់ជ្រុងជ្រោយពីតម្រូវការផ្សេងៗគ្នារបស់អ្នកទាំងនោះ តាមរយៈការលើកកម្ពស់ការ ពិគ្រោះយោបល់ និងការចូលរួម។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវខិតខំប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

**ទី៦. ការលើកស្ទួយសមធម៌**

ជាគោលការណ៍ ទន្ទឹមនឹងការលើកកម្ពស់ការឆ្លើយតបគណនេយ្យភាព និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវខិតខំលើកស្ទួយសមធម៌សង្គមក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។

ការលើកស្ទួយសមធម៌សង្គម គឺជាកិច្ចដំណើរការដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រឹងប្រែងធានាឱ្យមានការពិគ្រោះយោបល់ ការចូលរួមកាន់តែស៊ីជម្រៅជាមួយក្រុមផ្សេងៗគ្នា ដូចជា ស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ សហគមន៍ក្រីក្រ ជនជាតិភាគតិច ។ល។ សំដៅធ្វើការផ្តល់សេវា និងការអភិវឌ្ឍ ឆ្លើយតបតម្រូវការចំពោះក្រុមជនទាំងនោះ។ ក្នុងន័យនេះ ការផ្តល់សេវា និងការអភិវឌ្ឍត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ក្រុមជនខាងលើនេះ ដើម្បីឱ្យក្រុមជនទាំងនេះ ទទួលបាននូវឱកាសកាន់តែច្រើន អត្ថប្រយោជន៍កាន់តែច្រើន ពីការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៧. តម្លាភាព និងសុចរិតភាព**

តម្លាភាព និងសុចរិតភាព គឺជាគោលការណ៍ស្នូលនៃអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធានារៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ជាស្ថាប័នប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ជាក្រឹត្យក្រម

តម្លាភាព និងសុចរិតភាពមិនអាចកើតឡើងដោយឯកឯងបានឡើយ។ តម្លាភាព និងសុចរិតភាពទាមទារត្រូវរៀបចំឱ្យមានរចនា សម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីច្បាស់លាស់ សម្រាប់ស្ថាប័ននីមួយៗ ហើយថ្នាក់ដឹកនាំនៃស្ថាប័ននោះត្រូវមានការប្តេជ្ញាចិត្តក្នុងការកសាងស្ថាប័នរបស់ខ្លួនប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សាគណៈអភិបាលត្រូវមានការប្តេជ្ញាចិត្តកសាងរដ្ឋបាលរបស់ខ្លួនឱ្យក្លាយជារដ្ឋបាល ដែលមានលក្ខណៈបើកចំហ មានតម្លាភាពដោយត្រូវធានាឱ្យបានថា សមាជិកក្រុមប្រឹក្សាគ្រប់ៗរូប អភិបាល អភិបាលរង មន្ត្រី បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយតម្លាភាព និងត្រូវប្រកាន់យកគោលការណ៍សុចរិតភាព ក្នុងការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ការប្រជុំគណៈអភិបាល ការកសាងរបៀបធ្វើការជាក្រុមក្នុងក្រុមប្រឹក្សាគណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរបស់ខ្លួន ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យការងារផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធសវនកម្មផ្ទៃក្នុង ផ្ទៃក្រៅ និងប្រព័ន្ធនីតិវិធីនានាជាច្រើនដែលបានដាក់ឱ្យប្រើប្រាស់កន្លងមកនេះ គឺមានគោលបំណងគាំទ្រដល់ការលើកកម្ពស់តម្លាភាព និងសុចរិតភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ទី៨. វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច គឺជាកាតព្វកិច្ចរបស់ស្ថាប័ន សាធារណៈគ្រប់ថ្នាក់ ផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ៗរូប សំដៅកសាងសង្គម មួយប្រកបដោយភាពស្អាតស្អំ និងយុត្តិធម៌ ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គមប្រកបដោយចីរភាព និងសមធម៌។

ព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនា ខែមេសា ឆ្នាំ២០១០។ លើមូលដ្ឋាននៃច្បាប់នេះ កម្ពុជាកំពុងចាត់វិធានការតាមគ្រប់រូបភាពដើម្បីប្រយុទ្ធប្រឆាំង អំពើពុករលួយក្នុងសង្គមទាំងមូល។

រដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ ជារដ្ឋបាលដែលកើតចេញពីការបោះឆ្នោត ត្រូវមាន គណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ហេតុនេះ រដ្ឋបាលនីមួយៗត្រូវដាក់ចេញ នូវវិធានការប្រកបដោយប្រសិទ្ធភាព និងមានភាពសក្តិសិទ្ធិ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមគ្រប់រូបភាពក្នុងស្ថាប័នរបស់ខ្លួន។ ទន្ទឹមនឹងការដាក់ចេញនូវវិធានប្រយុទ្ធប្រឆាំងអំពើពុករលួយ នៅក្នុងស្ថាប័នរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ត្រូវសហការចូលរួមក្នុងការប្រយុទ្ធប្រឆាំង អំពើពុករលួយដែលកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។ វិធានការទាំងនេះ ត្រូវធានាឱ្យមានការចូលរួមពីផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋទាំងមូលផងដែរ។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក៏ត្រូវចាត់វិធានការចំពោះសកម្មភាពរំលោភអំណាច ដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មាត្រា៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត

ក្រុង ស្រុក ខណ្ឌ បានគូសបញ្ជាក់យ៉ាងច្បាស់អំពីនិយមន័យ និងសកម្មភាពនានាដែលកំណត់ថាជាការរំលោភអំណាច ហើយច្បាប់ក៏បានចង្អុលបង្ហាញនូវវិធានសម្រាប់ដោះស្រាយ ក្នុងករណីមានសកម្មភាព រំលោភអំណាចកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។

សរុបមកវិញ គោលការណ៍ទាំង០៨នេះមានទំនាក់ទំនងផ្សារភ្ជាប់គ្នា និងជះឥទ្ធិពលឱ្យគ្នា ទៅវិញទៅមក។ ភាពទន់ខ្សោយក្នុងការអនុវត្តសមាសធាតុណាមួយ ឬមួយចំនួន ឬការខកខាន មិនបានដាក់បញ្ចូលនូវសមាសធាតុណាមួយ ឬមួយចំនួនក្នុងកិច្ចដំណើរការនៃកំណែទម្រង់នឹងជះឥទ្ធិពលមិនល្អដល់សមាសធាតុផ្សេងៗទៀត ហើយធ្វើឱ្យប៉ះពាល់ដល់ចីរភាពនៃដំណើរការកំណែទម្រង់ទាំងមូល។

### ១.២.៤. ការរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

#### ក. ការរៀបចំប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅក្នុងឆ្នាំ២០០២ និងឆ្នាំ២០០៩ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលឃុំ សង្កាត់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

បច្ចុប្បន្ន ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជាពីរប្រភេទ គឺ៖

- ប្រព័ន្ធរដ្ឋបាលខេត្ត ដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ និង
- ប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ដែលរួមមាន ប្រព័ន្ធ០២ថ្នាក់ និងប្រព័ន្ធ០៣ថ្នាក់
  - ប្រព័ន្ធ០២ថ្នាក់៖ ស្រុក-ឃុំ និងក្រុង-សង្កាត់
  - ប្រព័ន្ធ០៣ថ្នាក់៖ រាជធានី-ខណ្ឌ-សង្កាត់

តើរដ្ឋបាលខេត្ត និងរដ្ឋបាលមូលដ្ឋានមានលក្ខណៈខុសគ្នាដូចម្តេច?

រដ្ឋបាលខេត្ត ប្រទេសភាគច្រើនហៅថា "រដ្ឋបាលតំបន់" មានមុខងារសំខាន់ៗ០៣ គឺ៖

**១.** អនុវត្តមុខងារជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិក្នុងការគាំទ្រ និងសម្របសម្រួលរដ្ឋបាលមូលដ្ឋានក្នុងដែនដីរបស់ខ្លួន ទាំងរដ្ឋបាលទីប្រជុំជន(ក្រុង) និងជនបទ (ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក)។ **(តាមប្រព័ន្ធវិសហមជ្ឈការ)**

**២.** អនុវត្តមុខងាររបស់ថ្នាក់ជាតិ ដែលថ្នាក់ជាតិធ្វើប្រតិភូកម្មពិសេសមុខងារពាក់ព័ន្ធសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ យុត្តិធម៌សង្គម ឬមុខងារពាក់ព័ន្ធការអភិវឌ្ឍ ការផ្តល់ សេវាសង្គម ដែលថ្នាក់ជាតិមិនទាន់ប្រគល់ឱ្យពេញលេញ។ **(តាមប្រព័ន្ធវិសហមជ្ឈការ)**

៣. អនុវត្តមុខងារក្នុងការផ្តល់សេវា និងការអភិវឌ្ឍ ដែលមានផលប៉ះពាល់ក្នុងក្របខ័ណ្ឌ ខេត្តទាំងមូល ហើយដែលមិនអាចរ៉ាប់រងអនុវត្តបានដោយរដ្ឋបាលមូលដ្ឋាន។ **(តាមប្រព័ន្ធវិមជ្ឈការ)**

រដ្ឋបាលមូលដ្ឋាន គឺជារដ្ឋបាលដែលនៅកៀក ឬនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋដែលមាន លទ្ធភាព សមត្ថភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍបានឆាប់រហ័សជាងថ្នាក់ជាតិ មានប្រសិទ្ធភាព និងមានភាពឆ្លើយតបជាងថ្នាក់ជាតិ ចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានខុសៗគ្នា។ ជាគោលការណ៍ និងជាបទពិសោធន៍អន្តរជាតិ ថ្នាក់ជាតិតែងតែផ្ទេរមុខងារ ទាំងមុខងារតាមប្រព័ន្ធ វិមជ្ឈការ(ការប្រគល់) និងមុខងារតាមប្រព័ន្ធវិសហមជ្ឈការ (ការធ្វើប្រតិភូកម្ម) កាន់តែច្រើនឡើងៗ ឱ្យទៅរដ្ឋបាលមូលដ្ឋាន ដើម្បីបង្ខិតសេវា និងការអភិវឌ្ឍឱ្យកៀកជិតនឹងប្រជាជន ពីព្រោះតម្រូវការក្នុង ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនមានការកើនឡើងជារៀងរាល់ថ្ងៃ។

ទន្ទឹមនេះ ការរៀបចំឡើងវិញនេះ គឺជាតម្រូវការចាំបាច់ក្នុងការរៀបចំឱ្យមានប្រព័ន្ធអភិបាលកិច្ចសម្រាប់តំបន់ទីប្រជុំជន និងតំបន់ជនបទ ដែលតម្រូវឱ្យមានការកំណត់មុខងារក្នុងការផ្តល់សេវា និងការអភិវឌ្ឍរវាងទីក្រុង និងជនបទ មិនដូចគ្នាឡើយ។

ចាប់ពីឆ្នាំ១៩៩០ អត្រានៃនគរូបនីយកម្ម(ទីក្រុង/ទីប្រជុំជន) មានការកើនឡើងយ៉ាងខ្លាំង។ មានការធ្វើចំណាត់ថ្នាក់នគរូបនីយកម្មចំនួន០២លើក (នៅឆ្នាំ២០០៤ និងនៅឆ្នាំ២០១១) ដោយក្រសួងផែនការ។ ចំណាត់ថ្នាក់ចុងក្រោយបង្អស់បានរកឃើញថាប្រជាជនរស់នៅតំបន់ទីប្រជុំជន បានកើនឡើងពី១៩,៥% ដល់២៧%។

បើយើងពិនិត្យមើលដង់ស៊ីតេរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមប្រភេទនៃរដ្ឋបាលនីមួយៗ យើងសង្កេតឃើញថា មានភាពខុសគ្នាខ្លាំងរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ ប្រជាពលរដ្ឋភាគច្រើនបានប្រមូលផ្តុំមករស់នៅរាជធានីភ្នំពេញ ដែលធ្វើឱ្យដង់ស៊ីតេប្រជាពលរដ្ឋនៅរាជធានី ភ្នំពេញកើនឡើងជាច្រើនដងបើប្រៀបធៀបទៅនឹងដង់ស៊ីតេប្រជាពលរដ្ឋនៅតាមខេត្ត។ ដោយឡែក ដង់ស៊ីតេមធ្យមរវាងក្រុង និងស្រុកខុសគ្នាប្រមាណ០២ដង។ ខាងក្រោមនេះ ជាតួលេខមធ្យមភាគ ដែលឆ្លុះបញ្ចាំងអំពីលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រនៃដែនដីរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

**ខ. ឋានៈផ្លូវច្បាប់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

មាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់ឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ រួមមានដែនដី និងប្រជាពលរដ្ឋនៅក្នុងដែនដីនោះ និងមានក្រុមប្រឹក្សាមួយជាតំណាង ដែលកើតឡើងពីការបោះឆ្នោតជ្រើសរើស ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ការផ្តល់ភាពជានីតិបុគ្គល ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺក្នុងគោលបំណងផ្តល់សិទ្ធិអំណាច មុខងារ ធនធាន និងទ្រព្យសម្បត្តិឱ្យដល់ក្រុមប្រឹក្សា ដើម្បី ក្រុមប្រឹក្សាអាចគ្រប់គ្រងចាត់ចែងកិច្ចការនានានៅមូលដ្ឋាន សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព ប្រសិទ្ធភាព សមធម៌ និងបរិយាប័ន្ន។

**គ. រចនាសម្ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានអនុវត្តបានតម្រូវឱ្យក្រុមប្រឹក្សានីមួយៗ រៀបចំឱ្យមានអង្គភាពមួយចំនួន នៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន ដើម្បីក្រុមប្រឹក្សាអាចបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពតាមច្បាប់ និងលិខិតបទដ្ឋានកំណត់។

### ១.២.២.ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ទិសដៅវិមជ្ឈការ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺ៖

- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមកាន់តែទូលំទូលាយនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅលើជីវភាពរស់នៅ និងអនាគតរបស់ខ្លួន
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ
- ធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋានផងដែរ។

### ១.២.៣.តួនាទី មុខងារ និងអំណាច

ផ្អែកទៅតាមបញ្ញត្តិនៅក្នុងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឱ្យនូវតួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងព្រមទាំងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។[7] រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធានដែលប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមួយមូលដ្ឋាននៅក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។

**ក.តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានតួនាទីគោលពីរប្រភេទគឺ តួនាទីបម្រើកិច្ចការមូលដ្ឋាន និងតួនាទីជា

[7] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

ភ្នាក់ងារតំណាងរដ្ឋ។[8] ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋានរដ្ឋបាលឃុំ សង្កាត់មានដូចខាងក្រោម៖

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យដំណើរការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ប្រជុំកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ សម្របសម្រួលទស្សនប្រជាពលរដ្ឋ
- ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក
- បំពេញកិច្ចការទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**ក្នុងតួនាទីជាអ្នកតំណាងរដ្ឋ:** រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយជាសម្ភារៈ និងថវិកាសម្រាប់អនុវត្ត។ ឧទាហរណ៍ៈ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតជាដើម។

**ខ.អំណាចរបស់រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់ មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

**អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់:** ស្តែងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានានៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។[9] ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះ។

**អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់:** មានន័យថារដ្ឋបាលឃុំ សង្កាត់ មានសិទ្ធិអនុវត្តសេចក្តីសម្រេច របស់ខ្លួននៅក្នុងក្របខ័ណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ រដ្ឋបាលឃុំ សង្កាត់ អាចធ្វើសកម្មភាពតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យតែប៉ុណ្ណោះ មានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើផ្ទុយនឹងគោលការណ៍ និងបញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

---

[8] មាត្រា៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

[9] មាត្រា៤៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

**គ.ព្រំដែន និអំណាច**

រដ្ឋបាល ឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ។ នេះមានន័យថា រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយទៅនឹងគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានានោះឡើយ។

រដ្ឋបាលឃុំ សង្កាត់មិនមានសិទ្ធិអំណាចសម្រេចទៅលើវិស័យមួយចំនួនរួមមានដូចជាៈ

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងៗទៀតដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ។

**១.៣.គោលដៅនៃការផ្តល់សេវាសាធារណៈ**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈគឺដើម្បី "បំរើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង"។

ដើម្បីធ្វើឱ្យដំណើរការនៃការផ្តល់សេវាសាធារណៈ ប្រព្រឹត្តទៅកាន់តែប្រសើរឡើង មានប្រសិទ្ធភាព តម្លាភាព ទទួលខុសត្រូវខ្ពស់ និងគុណភាពសាធារណៈ នោះរាជរដ្ឋា ភិបាលនឹងលើកទឹកចិត្តប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់ដែលប្រើប្រាស់សេវា ឱ្យចូលរួម ផ្តល់អនុសាសន៍លើបញ្ហានានាដែលកើត បញ្ចេញមតិយោបល់ ផ្តល់អនុសាសន៍លើបញ្ហានានាដែលកើតចេញពីការទទួល និងការប្រើប្រាស់សេវា ព្រមទាំងសេវាបែបបទណាដែលពួកគេចង់បាន។

រាជរដ្ឋាភិបាលរក្សាសិទ្ធក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ និងការទទួលខុសត្រូវប្រកបដោយភាពវៃឆ្លាតចំពោះការធានាសេវាសាធារណៈ មានគុណភាពជូនដល់ប្រជាពលរដ្ឋ អ្នកប្រើប្រាស់នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាដែលប្រាថ្នាចង់បាន ក៏ប៉ុន្តែការផ្គត់ផ្គង់ និងការបំរើសេវាសាធារណៈ គឺមិនមែនសុទ្ធតែធ្វើឡើងដោយរដ្ឋបាលសាធារណៈ និងភ្នាក់ងាររបស់រដ្ឋឡើយ។

# ជំពូកទី២

# ដំណើរការនៃការគ្រប់គ្រង

# រដ្ឋបាលឃុំ សង្កាត់

# ជំពូកទី ២
# ដំណើរការនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ២.១.រចនាសម្ព័ន្ធ

ជំពូកទី៣ (មាត្រា២៥ ដល់ មាត្រា៤០) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់អំពីការរៀបចំរចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់ដែលតម្រូវឱ្យមានអង្គធ្វើសេចក្តីសម្រេចចិត្តជាក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ឬហៅថាអង្គប្រតិបត្តិ ដែលរួមមាន មេឃុំ ចៅសង្កាត់ ជំទប់ទី១ ចៅសង្កាត់រងទី១ ជំទប់ទី២ ចៅសង្កាត់រងទី២ គណៈកម្មាធិការក្រុមប្រឹក្សា ស្មៀន និងថ្នាក់ដឹកនាំភូមិ។

ក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ និងមានស្វ័យភាពក្នុងការដឹកនាំ ការចាត់ចែងកិច្ចការនានាក្នុងការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានសំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកពី០៥ ទៅ ១១រូប ផ្អែកតាមភូមិសាស្ត្រ និងចំនួនប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នីមួយៗ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ។

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមាន ក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។ ក្នុងដំណាក់កាលអន្តរកាល ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុត អាណត្តិមានភារកិច្ចត្រឹមតែសម្រួលកិច្ចការប្រចាំថ្ងៃប៉ុណ្ណោះ។[10]

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន០១រូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។[11] ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ចៅសង្កាត់។ ឃុំ សង្កាត់នីមួយៗមានមេឃុំ ចៅសង្កាត់ម្នាក់។ មេឃុំ ចៅសង្កាត់មានជំនួយការ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។

ជាមួយនេះ ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបជា ស្មៀនឃុំ សង្កាត់។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមាន មេភូមិ និងជំនួយការភូមិសម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាក៏អាចធ្វើការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋ ដើម្បីជួយដល់កិច្ចការរបស់ខ្លួនផងដែរ។[12]

[10] មាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

[11] មាត្រា១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

[12] ក្រសួងមហាផ្ទៃ,ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០២២។

## ២.២.តួនាទី ភារកិច្ច

### ២.២.១.ក្រុមប្រឹក្សាឃុំ សង្កាត់

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន ស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។[13]

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសម្រួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

### ២.២.២ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័ប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវតាមវិធាន និងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។

### ២.២.៣.សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

#### ក. តួនាទីបម្រើកិច្ចការមូលដ្ឋាន

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើតផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

[13] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, ឆ្នាំ២០១៥។

- បំពេញភារកិច្ចជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។[14]

**ខ. តួនាទីភ្នាក់ងារតំណាងរដ្ឋ**

- ក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។[15]

### ២.២.៤. មេឃុំ ចៅសង្កាត់

- មានសិទ្ធិចុះហត្ថលេខាលើដីកា និងសេចក្តីសម្រេចរបស់ឃុំ សង្កាត់របស់ខ្លួន
- មានសិទ្ធិតែងតាំងគណៈកម្មាធិការជំនួយការនានាតាមការចាំបាច់ ដើម្បីផ្តល់យោបល់ឱ្យខ្លួន
- មានសិទ្ធិចុះហត្ថលេខាលើលិខិតស្នើសុំសេវារដ្ឋបាលនៅឃុំ សង្កាត់របស់ខ្លួន
- ធានាថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកា ហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទីនិងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានានុក្រមពេលខ្លួនអវត្តមាន
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ។

### ២.២.៥. ជំទប់ទី១ ចៅសង្កាត់រងទី១

- ទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន
- នៅពេលទទួលស្តីទី មិនអាចផ្ទេរទៅឱ្យជំទប់ទី២ ចៅសង្កាត់រងទី២បានឡើយ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

### ២.២.៦. ជំទប់ទី២ ចៅសង្កាត់រងទី២

- ជួយមេឃុំ ចៅសង្កាត់លើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់រងទី១អវត្តមាន
- នៅពេលទទួលស្តីទី មិនអាចផ្ទេរបន្តបានឡើយ

[14] មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

[15] មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

– បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

**២.២.៧. ស្មៀន**

បុគ្គលិកក្របខ័ណ្ឌនៅរដ្ឋបាលឃុំ សង្កាត់មានតែម្នាក់គត់គឺ ស្មៀនឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ ជាបុគ្គលិកស្ថិតនៅក្នុងក្របខ័ណ្ឌរដ្ឋបាលស៊ីវិលរបស់ក្រសួងមហាផ្ទៃ និងត្រូវបានតែងតាំងដោយរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ដើម្បីទៅបំពេញការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឋានៈជាស្មៀនឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់មានតួនាទី ភារកិច្ច ដូចខាងក្រោម៖

– ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងគណៈកម្មាធិការនានាបំពេញតួនាទី និងមុខងារ ស្របទៅតាមតម្រូវការផ្នែកច្បាប់
– បំពេញការងាររដ្ឋបាល
– ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ស្របទៅនឹងលក្ខខណ្ឌច្បាប់
– ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងការអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់
– ចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការ លើកលែងតែបានទទួលការអនុញ្ញាតឱ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
– ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឱ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹងសេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំសង្កាត់ និងមេឃុំចៅសង្កាត់ សម្រាប់ឱ្យសាធារណជនទូទៅបានដឹងនូវព័ត៌មានទាំងនោះ។[16]

**២.២.៨.បុគ្គលិកឃុំ សង្កាត់**

មាត្រា២៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែងថា "ឃុំសង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិបន្ទាប់" ។[17]

បែបបទនៃការជ្រើសរើសបុគ្គលិកឃុំ សង្កាត់ មានបរិយាយនៅក្នុងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ។

[16] ក្រសួងមហាផ្ទៃ,ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០២២។
[17] មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

### ២.២.៩.មេភូមិ និងជំនួយការភូមិ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សម្រាប់ភូមិនីមួយៗចំណុះឱ្យឃុំ សង្កាត់របស់ខ្លួន ។ មេភូមិនេះមិនមែនជាបុគ្គលិកជាប់កិច្ចសន្យា ឬមន្ត្រីរាជការនៅក្នុងក្របខណ្ឌមុខងារសាធារណៈនោះទេ។ ផ្ទុយទៅវិញ ការរៀបចំឱ្យមានមេភូមិសម្រាប់ឃុំ សង្កាត់នីមួយៗនេះ គឺដើម្បីជាសេនាធិការឱ្យរដ្ឋបាលឃុំ សង្កាត់នៅក្នុងការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពនៃសេវា ។

មេភូមិនេះ ត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានភូមិមួយរូប សមាជិកភូមិមួយរូបជាជំនួយការ ។ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។ មុខតំណែងនេះទាំងនេះត្រូវបានបន្តការងាររហូតដល់មានការតែងតាំងថ្មី។ ខាងក្រោមនេះ ជាតួនាទី ភារកិច្ចរបស់មេភូមិ និងជំនួយការភូមិ៖

**ក. មេភូមិ**

- បង្កើនការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ចូលរួមកិច្ចប្រជុំក្នុងគណកម្មាធិការនានារបស់ឃុំ សង្កាត់ ដើម្បីផ្តល់យោបល់អំពីកិច្ចដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួននៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ
- ផ្តល់យោបល់ដល់គណៈកម្មាធិការភូមិ អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការភូមិ អំពីរបៀបបង្កើន និងកសាងសមត្ថភាពនៃធនធានរបស់ភូមិ
- ផ្តល់យោបល់ដល់គណៈកម្មាធិការផែនការអភិវឌ្ឍន៍ និងថវិកាអំពី៖
  - តម្រូវការ និងអាទិភាពរបស់ភូមិដើម្បីបញ្ចូលក្នុងថវិកា និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
  - អនុវត្តថវិកា និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
  - ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តថវិកា និងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធនឹងភូមិ ដើម្បីបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ពិគ្រោះយ៉ាងទៀងទាត់ជាមួយប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន
- ដោះស្រាយបញ្ហាដែលជាផលប្រយោជន៍រួមជាមួយភូមិក្បែរគ្នា
- ចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់។

**បញ្ជាក់៖**

- មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ។
- មេភូមិពុំមានសិទ្ធិអំណាចសម្រេចបញ្ហាណាមួយ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាមប្រកាសរបស់ក្រសួងមហាផ្ទៃបានឡើយ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់មិនមានអំណាចផ្ទេរដល់បុគ្គល ឬគណៈកម្មាធិការណាមួយនៅក្នុងភូមិបានឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**ខ. ជំនួយការភូមិ**

- អនុប្រធានភូមិ ទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមាន ដោយមានមូលហេតុច្បាស់លាស់ ដូចជាមានជំងឺ ឬមានបេសកកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពី១ថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិត្រូវទទួលជួយមេភូមិលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់ ។
- សមាជិកភូមិ ទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារស្ថិតិ ការចុះបញ្ជីប្រជាពលរដ្ឋ និងការរក្សាទុកឯកសារនានារបស់ភូមិ ។

**បញ្ជាក់៖** ក្រៅពីការងារខាងលើនេះមេភូមិអាចធ្វើការបែងចែក ឬប្រគល់ភារកិច្ចដល់អនុប្រធានភូមិ និងសមាជិកភូមិតាមការចាំបាច់ និងធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់សាមី ។

## ២.៣. កិច្ចការរដ្ឋបាល

### ២.៣.១. លិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធាន បទប្បញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តន៍កិច្ចការនានា។[18]

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ រួមមានដីកា និងសេចក្តីសម្រេច។

### ២.៣.២. ដីកា

ដីកាឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលកំណត់នូវបទប្បញ្ញត្តិទាំងឡាយ ដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើងសំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ដោយស្មើភាព មិនរើសអើង និង

[18] ក្រសួងមហាផ្ទៃ,ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០២២។

សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។

ដីកាឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមការសម្រេចរបស់អង្គប្រជុំ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។

ឧទាហរណ៍៖

- ដីកាស្តីពីការថែរក្សាបរិស្ថាន និងអនាម័យ
- ដីកាស្តីពីការរក្សាសណ្តាប់ធ្នាប់សាធារណៈ
- ដីកាស្តីពីការទប់ស្កាត់ និងលុបបំបាត់ល្បែងស៊ីសង។

**ក. ការរៀបចំ និងអនុម័តដីកា**

ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំ និងអនុម័តដីកាតាមនីតិវិធី ដូចខាងក្រោម៖

- ការរៀបចំសេចក្តីព្រាងដីកា៖ មេឃុំ ចៅសង្កាត់ ត្រូវរៀបចំក្រុមការងារមួយដែលមាន សមាជិកយ៉ាងតិច៣រូប (អាចជាប្រជាពលរដ្ឋ ឬជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬអ្នកពាក់ព័ន្ធនានា)ដើម្បីរៀបចំសេចក្តីព្រាងដីកាដាក់ជូនអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងអនុម័ត
- ការពិនិត្យសេចក្តីព្រាងដីកា៖ ក្រោយរៀបចំសេចក្តីព្រាងដីការួច មេឃុំ ចៅសង្កាត់ត្រូវ រៀបចំការប្រជុំក្រុមប្រឹក្សា ដើម្បីពិនិត្យ និងឯកភាពសម្រាប់ធ្វើការផ្សព្វផ្សាយ និងពិគ្រោះ យោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ៖ ការផ្សព្វផ្សាយ និងពិគ្រោះយោបល់មានរយៈពេលយ៉ាងតិច១៥ថ្ងៃ(ថ្ងៃធ្វើការ)។ មេឃុំ ចៅសង្កាត់ និងក្រុមការងារត្រូវតែ ពិចារណានូវយោបល់របស់ប្រជាពលរដ្ឋដែលបានស្នើឡើង ដើម្បីកែសម្រួលសេចក្តីព្រាង ដីកានោះ។ ករណីមេឃុំ ចៅសង្កាត់មិនដាក់បញ្ចូលយោបល់ដែលបានស្នើឡើងដោយ ប្រជាពលរដ្ឋទៅក្នុងសេចក្តីព្រាងដីកា មេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ជូនកិច្ចប្រជុំ ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការជូនដំណឹងទៅប្រជាពលរដ្ឋដោយបញ្ជាក់ពីហេតុផលដែលមិនទទួលយក
- ការអនុម័តដីកា៖ បន្ទាប់ពីបានពិចារណា និងកែសម្រួលសេចក្តីព្រាងដីកាទៅតាមមតិ យោបល់របស់ប្រជាពលរដ្ឋរួចហើយ មេឃុំ ចៅសង្កាត់ត្រូវរៀបចំ និងដាក់ជូនអង្គប្រជុំ ក្រុមប្រឹក្សា ដើម្បីពិភាក្សា និងពិនិត្យអនុម័តទៅលើដីកានោះ។ ការអនុម័តអាចយកជាបានការត្រូវមានសំឡេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងមូលគាំទ្រ។

ខ. ការផ្សព្វផ្សាយ

រាល់ដីកាដែលបានអនុម័តដោយក្រុមប្រឹក្សា និងបានចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់រួច ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈភ្លាម និងឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាពលរដ្ឋយល់ជ្រួតជ្រាប និងចូលរួមអនុវត្ត។

ការផ្សព្វផ្សាយនេះ ត្រូវអនុវត្តដូចខាងក្រោម៖

- បិទផ្សាយលើក្តារខៀនព័ត៌មាននៅសាលាឃុំ សង្កាត់ ឬទីកន្លែងសាធារណៈនៅក្នុងឃុំ សង្កាត់
- ផ្សព្វផ្សាយដល់គ្រប់មេភូមិទាំងអស់នៅក្នុងឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ
- តាមប្រព័ន្ធឧឃោសនសព្ទ ឬតាមមធ្យោបាយផ្សេងៗទៀត។

### ២.៣.៣. សេចក្តីសម្រេច

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើតការតែងតាំង ការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ សេចក្តីសម្រេចមាន លក្ខណៈប្រហាក់ប្រហែលនឹងដីកាឃុំ សង្កាត់ដែរ ប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗ ទៀតក្នុងឃុំ សង្កាត់។ សេចក្តីសម្រេចឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ។

សេចក្តីសម្រេចឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។ ក្នុងករណីប្រធានសក្តិ និងបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន មេឃុំ ចៅសង្កាត់អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនេះ នឹង ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំបន្ទាប់ ដើម្បីពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវតាមច្បាប់។

**ឧទាហរណ៍៖**

- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការលទ្ធកម្ម
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង។

## ២.៤. លិខិតរដ្ឋបាល

### ២.៤.១. និយមន័យ

លិខិតរដ្ឋបាល គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាព និងបុគ្គលនានា ក្នុង គោលបំណងជូន

ព័ត៌មាន ណែនាំ អញ្ជើញ រាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំងបុគ្គលណាមួយឱ្យទៅបំពេញបេសកកម្ម។

### ២.៤.២. ប្រភេទលិខិតរដ្ឋបាល

លិខិតរដ្ឋបាលឃុំ សង្កាត់ដែលប្រើប្រាស់ជាផ្លូវការ រួមមាន (១)លិខិតស្នើ (២)សេចក្ដីជូន ដំណឹង ឬលិខិតជូនដំណឹង (៣) លិខិតអញ្ជើញ (៤) លិខិតបញ្ជាបេសកកម្ម (៥) របាយការណ៍ (៦)កំណត់ហេតុ (៧) លិខិតផ្ទេរសិទ្ធិ និង (៨)ដីកាអម។

លិខិតស្នើ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីបង្ហាញពីគោលបំណង និង មូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គល សាធារណៈ ឯកជន ក្រសួង ស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ។

សេចក្ដីជូនដំណឹង ឬលិខិតជូនដំណឹង គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការ ទំនាក់ទំនងជាមួយបុគ្គលក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលមានខ្លឹមសារជាការឆ្លើយបំភ្លឺ ចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើ ឬជាការជូនដំណឹងឱ្យសាធារណជនបាន ដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ។

លិខិតអញ្ជើញ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនឹងបុគ្គល ឬអង្គភាពទាំងនោះ ដោយមានបញ្ជាក់ឈ្មោះ និងឋានៈ(អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំ ឬប្រារព្ធពិធី កាលបរិច្ឆេទកម្មវិធី ឬរបៀប វារៈប្រជុំ(និងអាចមានឯកសារដែលពាក់ព័ន្ធនឹងការប្រជុំភ្ជាប់ជាមួយ)។

លិខិតបញ្ជាបេសកកម្ម គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ឱ្យចូលរួមក្នុងសកម្មភាពនានានៅក្រៅឃុំ សង្កាត់។ លិខិតនេះមាន ភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។ ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទ សម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និងហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងឮអំពីការចេញដំណើរ និងការមកដល់ពី កន្លែងមួយទៅកន្លែងមួយទៀត។ នៅពេលត្រឡប់មកវិញត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជ្រាបអំពីលទ្ធផល ឬបញ្ហា សំខាន់ៗដែលខ្លួនបានទៅចូលរួម។

របាយការណ៍ គឺជាសេចក្ដីរាយការណ៍អំពីសកម្មភាព ដំណើរការ និងលទ្ធផលការងាររបស់ ឃុំ សង្កាត់ ឬបុគ្គលិកណាម្នាក់ ឬក្រុមដែលរដ្ឋបាលឃុំ សង្កាត់បានបំពេញ ឬឃុំ សង្កាត់ បានចាត់តាំងឱ្យទៅបំពេញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ។ ទម្រង់របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ

សង្កាត់ត្រូវអនុវត្តតាមសេចក្តី ណែនាំលេខ០៣៥ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រៅពីទម្រង់របាយការណ៍ ប្រចាំខែ និងទម្រង់របាយការណ៍ប្រចាំឆ្នាំខាងលើនេះឃុំ សង្កាត់អាចបង្កើត និងប្រើប្រាស់ទម្រង់របាយការណ៍ផ្សេងទៀតសម្រាប់ប្រើប្រាស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។

កំណត់ហេតុ គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងការឯកភាពលើសកម្មភាពដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

លិខិតផ្ទេរសិទ្ធិ គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយល័ក្ខណ៍អក្សរ ប្រគល់សិទ្ធិឱ្យជំទប់ចៅសង្កាត់រង តាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទីក្នុងអំឡុងពេលដែលមេឃុំ ចៅសង្កាត់ អវត្តមាន

ដីកាអម គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងផ្ញើអមភ្ជាប់ជាមួយសំណុំ លិខិត ដែលត្រូវផ្ញើចេញទៅឱ្យអង្គភាព ក្រសួង ស្ថាប័នណាមួយដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត (ឯកសារ) លើដីកាអមនោះ។ ឃុំ សង្កាត់ប្រើដីកាអម ដើម្បីជៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ។

## ២.៥. របៀបបែបបទការងារ

### ២.៥.១. ការចរាចរលិខិត

ស្មៀនឃុំ សង្កាត់ ជាអ្នកធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់។ ហេតុនេះ រាល់លិខិតរដ្ឋបាលទាំងអស់ពាក់ព័ន្ធនឹងឃុំ សង្កាត់ ចាំបាច់ត្រូវចូល និងចេញតាមរយៈស្មៀន លើកលែងតែមានការកំណត់ដោយឡែក។

ពាក់ព័ន្ធនឹងការងាររបៀបនេះមានការងារសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ចរាចរលិខិតចូល និងលិខិតចេញ
- បោះត្រា ចុះលេខ និងចុះកាលបរិច្ឆេទលិខិតចូល និងលិខិតចេញ
- កត់ត្រាចូលសៀវភៅលិខិតចូល និងសៀវភៅលិខិតចេញ
- រក្សាទុកលិខិតចូល និងលិខិតចេញ
- រក្សាទុក និងគ្រប់គ្រងត្រា សៀវភៅលិខិតចូល និងសៀវភៅលិខិតចេញ។

### ២.៥.២. ការតាក់តែងលិខិត

- **ការរៀបចំសេចក្តីព្រាងលិខិត៖** សំដៅដល់បុគ្គលិកទទួលបន្ទុកត្រូវផ្តួចផ្តើមរៀបចំសេចក្តីព្រាងលិខិតទៅតាមទម្រង់ដែលបានកំណត់ដោយបរិយាយខ្លឹមសារលិខិតឱ្យបានច្បាស់លាស់ និងមានអត្ថន័យគ្រប់គ្រាន់។

- **ការត្រួតពិនិត្យដោយស្មៀន៖** សំដៅដល់បុគ្គលិកទទួលបន្ទុក ត្រូវដាក់ជូនស្មៀននូវសេចក្តីព្រាងលិខិតរបស់ខ្លួនដើម្បីត្រួតពិនិត្យ។ ស្មៀន គឺជាអ្នកទទួលខុសត្រូវត្រួតពិនិត្យនូវរាល់លិខិតទាំងអស់ ដើម្បីធានាភាពត្រឹមត្រូវនូវទម្រង់ ខ្លឹមសារ នីត្យានុកូលភាព អក្ខរាវិរុទ្ធ និងភាពមានរបៀបរៀបរយនៃលិខិតមុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច
- **ការចុះហត្ថលេខាសង្ខេប៖** មុនដាក់ជូនហត្ថលេខីចុះហត្ថលេខា លិខិតត្រូវចុះហត្ថលេខី សង្ខេបដោយហត្ថលេខាសង្ខេប ដែលមានភារកិច្ចតាមលំដាប់លំដោយ
- **ការចុះហត្ថលេខា៖** បន្ទាប់ពីបានចុះហត្ថលេខាសង្ខេបរួច ត្រូវបញ្ជូនលិខិតទៅហត្ថលេខីដែលត្រូវចុះហត្ថលេខាលើលិខិតនោះ។

### ២.៥.៣. ការគ្រប់គ្រង និងការប្រើប្រាស់ត្រា

**ក. ការគ្រប់គ្រងត្រា**

ស្មៀនឃុំ សង្កាត់មានភារកិច្ចក្នុងការថែរក្សាប្រើប្រាស់ និងទុកដាក់ត្រាឱ្យបានត្រឹមត្រូវ។ ក្នុងថ្ងៃធ្វើការករណីស្មៀនឃុំ សង្កាត់មានបេសកកម្មចេញក្រៅសាលាឃុំ សង្កាត់ ត្រូវយកត្រាទៅទុកផ្ញើនឹងមេឃុំ ចៅសង្កាត់ ដោយមិនត្រូវយកត្រាជាប់ជាមួយខ្លួនឡើយ។

**ខ. ការប្រើប្រាស់ត្រា**

ត្រូវបោះត្រាមូលរបស់ឃុំ សង្កាត់ និងត្រាឈ្មោះហត្ថលេខី បន្ទាប់ពីមេឃុំ ចៅសង្កាត់ (ឬអ្នកទទួលសិទ្ធិ) បានចុះហត្ថលេខារួចត្រាមូលរបស់ឃុំ សង្កាត់ ត្រូវបោះនៅប៉ែកខាងឆ្វេងជាន់ពីលើហត្ថលេខាប្រហែលមួយភាគបី។ ត្រាមូលមិនត្រូវបោះជាន់ពីលើពេញហត្ថលេខាទេ ព្រោះដើម្បីបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ច ធ្វើកោសល្យវិច្ឆ័យក្នុងករណីមានការសង្ស័យ លើការក្លែងបន្លំហត្ថលេខាត្រាឈ្មោះហត្ថលេខី ត្រូវបោះនៅខាងក្រោមហត្ថលេខា នៅផៀងខាងស្តាំ។ ត្រាឈ្មោះ មិនត្រូវបោះជាន់ពីលើត្រាមូលនោះទេត្រាមូលរបស់ឃុំ សង្កាត់ និងត្រាឈ្មោះរបស់ហត្ថលេខីត្រូវប្រើទឹកល័ក្ខពណ៌ក្រហម។

## ២.៦. ការគ្រប់គ្រងឯកសារ

យោងតាមអនុក្រឹត្យលេខ២២ អនក្រ.បកស្តីពីការផ្ទេរមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា៩ ចែងថា៖

- ឃុំ សង្កាត់ គឺជាម្ចាស់លើរាល់លិខិត និងឯកសារដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ និងជាម្ចាស់កម្មសិទ្ធិលើតែមប្រិ៍ត្រាឃុំ សង្កាត់ ព្រមទាំងឧបករណ៍ផ្សេងៗទៀតទាំងអស់របស់ឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាមតែមប្រិ៍ត្រាឱ្យបានត្រឹមត្រូវ និងគង់វង្ស។

### ២.៦.១. និយមន័យ

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទាំងឡាយតាមប្រព័ន្ធមួយមាន សណ្តាប់ធ្នាប់ និងសុវត្ថិភាព។

### ២.៦.២. ផលប្រយោជន៍នៃការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារនឹងផ្តល់នូវផលប្រយោជន៍មួយចំនួនដូចជា៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច
- ជួយបន្តនិរន្តរភាពព័ត៌មាន នៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញ
- ផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តិការណ៍ដែលកើតរួចមកហើយ
- បង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។

### ២.៦.៣. ប្រភេទឯកសារ

ជាទូទៅ ឯកសារឃុំ សង្កាត់ មាន២ប្រភេទ គឺឯកសារផ្ទៃក្នុង និងឯកសារសាធារណៈ។

ឯកសារផ្ទៃក្នុង គឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់តែ ផ្ទៃក្នុងរបស់រដ្ឋបាលឃុំ សង្កាត់ និងបុគ្គលពាក់ព័ន្ធផ្ទាល់ប៉ុណ្ណោះ។

**ឧទាហរណ៍៖**

- របាយការណ៍ស៊ើបអង្កេត
- ឯកសារអត្រានុកូលដ្ឋាន...។

ឯកសារសាធារណៈ គឺជាឯកសារទាំងឡាយណាដែលត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយសម្រាប់សាធារណជនទូទៅ។

ឧទាហរណ៍៖

- ផែនការអភិវឌ្ឍន៍
- កម្មវិធីវិនិយោគបីឆ្នាំរំកិល
- របាយការណ៍ហិរញ្ញវត្ថុ...។

ឯកសារសាធារណៈរបស់ឃុំ សង្កាត់ អាចត្រូវបានប្រើប្រាស់ពីគ្រប់សាធារណជនទូទៅ ដែលមានបំណងចង់សិក្សាឈ្វេងយល់មានដូចជា ក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ ប្រជាពលរដ្ឋ គណៈកម្មាធិការ និងគណៈកម្មការនានា មន្ត្រីស្ថាប័នជំនាញនានា អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា អ្នកទទួលការ និងសិស្ស និស្សិត។ល។ ប៉ុន្តែឯកសារមួយចំនួនក៏ពុំអនុញ្ញាតផ្តល់ជូន សាធារណជនបានដែរដូចជា

ឯកសារផ្ទៃក្នុងដែលត្រូវបានកំណត់អ្នកប្រើប្រាស់ មានតែក្រុមប្រឹក្សា ស្មៀនឃុំ សង្កាត់ និងបុគ្គលិកដែលបាន ទទួលការអនុញ្ញាតពីមេឃុំ ចៅសង្កាត់ប៉ុណ្ណោះដែលអាចប្រើប្រាស់ ឯកសារផ្ទៃក្នុងនេះបាន ដូចជា ឯកសារពាក់ព័ន្ធទៅនឹងការដកហូត ការតែងតាំង និងការដាក់វិន័យ បុគ្គលណាម្នាក់។

### ២.៦.៤. បច្ចេកទេសក្នុងការគ្រប់គ្រងឯកសារ

បច្ចេកទេសនានាក្នុងការគ្រប់គ្រងឯកសារ រួមមានដូចខាងក្រោម៖

- ការគ្រប់គ្រងឯកសារតាមកាលប្បវត្តិ គឺជាការៀបចំទុកដាក់ និងថែរក្សាឯកសារនានា ទៅតាមលំដាប់លំដោយកាលបរិច្ឆេទនៃការដាក់ចេញនូវឯកសារ
- ការគ្រប់គ្រងឯកសារតាមប្រភេទ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារនានាទៅតាមប្រភេទ និងអនុប្រភេទនៃឯកសារនីមួយៗនោះ
- ការគ្រប់គ្រងឯកសារតាមឈ្មោះ គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារនានា ទៅតាមឈ្មោះរបស់បុគ្គល ឬឈ្មោះរបស់អង្គភាព
- ការគ្រប់គ្រងឯកសារតាមអក្ខរក្រម គឺជាការរៀបចំទុកដាក់ និងថែរក្សាឯកសារទៅតាម លំដាប់លំដោយនៃព្យញ្ជនៈ “ក ខ គ ឃ ង ជ...”។

### ២.៦.៥. ការរក្សាទុកឯកសារ

បច្ចុប្បន្ននេះ ឃុំ សង្កាត់មានឯកសារច្រើន។ ដូច្នេះ ឃុំ សង្កាត់ត្រូវការប្រព័ន្ធមួយដើម្បីទុកដាក់ និងថែរក្សាឯកសារទាំងនោះឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

ការរក្សាទុកឯកសារត្រូវបានបែងចែកជាពីរគឺ ៖

- ឯកសារអេឡិចត្រូនិច គឺជាឯកសារដែលអាចរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិច ឬប្រព័ន្ធកុំព្យូទ័រ
- ឯកសារ បោះពុម្ព គឺជាឯកសារដែលបានបោះពុម្ពនៅលើក្រដាស។

ការគ្រប់គ្រងឯកសារនីមួយៗតែងតែធ្វើឡើងក្នុងទម្រង់ជាឯកសារអេឡិចត្រូនិច និងទម្រង់ជា ឯកសារបោះពុម្ពដោយប្រើប្រាស់បច្ចេកទេសគ្រប់គ្រងឯកសារនានាបញ្ចូលគ្នា និងរក្សាទុកឯកសារទាំងនោះនៅច្រើនកន្លែង និងទៅតាម ឈ្មោះបុគ្គលិក អក្ខរក្រម និងកាលប្បវត្តិ ចំពោះឯកសារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក ប្រភេទឯកសារ និងកាលប្បវត្តិ ចំពោះឯកសារទាំងអស់ លើកលែងតែឯកសារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក។

## ២.៧. ការគ្រប់គ្រងសម្ភារបរិក្ខារ

សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ គឺជាសម្ភារបរិក្ខារទាំងឡាយណាដែលឃុំ សង្កាត់មានពីមុនមក បានទិញ និងបានទទួលពីម្ចាស់អំណោយនានា ដូចជា តុ កៅអី កុំព្យូទ័រ ម៉ូតូ...។

ស្មៀន គឺជាអ្នកទទួលខុសត្រូវក្នុងការចុះបញ្ជីនូវគ្រប់សម្ភារបរិក្ខារទាំងអស់របស់ឃុំ សង្កាត់។ គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកឱ្យបានល្អ ប្រកបដោយ សុវត្ថិភាព និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ គ្រប់សម្ភារបរិក្ខាររបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើ ឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

## ២.៨. គន្លឹះក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចប្រជុំ

ដើម្បីធានាឱ្យកិច្ចប្រជុំមានប្រសិទ្ធភាព និងដំណើរការទៅដោយរលូន ប្រធានអង្គប្រជុំត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម៖

- កំណត់វិន័យ ដូចជាហាមជជែកគ្នា និងបិទសំឡេងទូរស័ព្ទជាដើម
- ពន្យល់ឱ្យបានច្បាស់លាស់ពីគោលបំណងនៃកិច្ចប្រជុំ
- គ្រប់គ្រងការពិភាក្សាកុំឱ្យចាកប្រធានបទ
- ខិតខំបំផុសគំនិត និងជំរុញឱ្យសមាជិកអង្គប្រជុំគ្រប់រូបចូលរួមមតិយោបល់ ជៀសវៀង បរិយាកាសនៃការពិភាក្សាដែលគ្របដណ្តប់ដោយអ្នកចូលរួមមួយចំនួនតូច
- គ្រប់គ្រងពេលវេលានៃការពិភាក្សាលើរបៀបវារៈនីមួយៗតាមពេលវេលាដែលបានកំណត់
- ចុងក្រោយត្រូវធ្វើការបូកសរុបឡើងវិញអំពីចំណុចសំខាន់ៗដែលជាលទ្ធផលនៃកិច្ចប្រជុំ។ ទន្ទឹមនេះ ប្រធានអង្គប្រជុំ ត្រូវបន្តតាមដានការអនុវត្តសេចក្តីសម្រេចរបស់អង្គប្រជុំ ដើម្បីធានាថារាល់សេចក្តីសម្រេច ដែលបានអនុម័តត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

## ២.៩.គណនេយ្យភាព

ការផ្តល់ភាពជាតំណាងសាធារណៈ ដល់ក្រុមប្រឹក្សាតាមរយៈការបោះឆ្នោតដោយផ្ទាល់ដោយប្រជាពលរដ្ឋធ្វើឱ្យផ្លាស់ប្តូរខ្សែគណនេយ្យភាពក្នុងការបំពេញការងារនៅរដ្ឋបាលឃុំ សង្កាត់ ។ ក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការនានា ក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលឃុំ សង្កាត់ត្រូវមានទំនាក់ទំនងគណនេយ្យភាពបីប្រភេទដូចខាក្រោម៖

- គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ជាគណនេយ្យភាពពីលើចុះក្រោម ។ រដ្ឋបាលឃុំ សង្កាត់ត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាពាក់ព័ន្ធការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅក្នុងមូលដ្ឋានរបស់ខ្លួន ។ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាតំណាងឱ្យសម្លេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន និងជាអ្នកដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ ។ ក្នុងន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ចាំបាច់ត្រូវគិតគូរ និងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការធ្វើសេចក្តីសម្រេចនានា ពាក់ព័ន្ធ

នឹងការប្រើប្រាស់ធនធានមានកម្រិតរបស់ខ្លួន ដើម្បីធានាឱ្យការសម្រេចរបស់ក្រុមប្រឹក្សាអាចឆ្លើយតបបានជាអតិបរមាទៅនឹងសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋទូទៅ នៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយ តម្លាភាព សមធម៌ និងបរិយាបន្ន ។

- គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ជាគណនេយ្យភាពពីក្រោមទៅលើ ។ រដ្ឋបាលឃុំ សង្កាត់មានតួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ ទោះជារដ្ឋបាលឃុំ សង្កាត់ត្រូវបានផ្តល់នូវស្វ័យភាព និងសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងចាត់ចែងធនធានរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនយ៉ាងណាក្តីក៏រដ្ឋបាលឃុំ សង្កាត់ពុំមានអធិបតេយ្យភាពដោយឡែកនៅក្រៅការគ្រប់គ្រងនៃច្បាប់ និងលិខិតបទដ្ឋាននានារបស់រដ្ឋនោះឡើយ។ ក្នុងន័យនេះរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នថ្នាក់ជាតិនឹងធ្វើការត្រួតពិនិត្យនីត្យានុកូលភាពលើការអនុវត្តការងាររបស់រដ្ឋបាលឃុំ សង្កាត់តាមរយៈរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធានារាល់សេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។
- គណនេយ្យភាពផ្ទៃក្នុង ជាគណនេយ្យភាពតាមឋានានុក្រមនៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន ។ មេឃុំ ចៅសង្កាត់ត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយក្រុមប្រឹក្សា ក្នុងនាមជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការណែនាំនានាដែលទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់ ។ គណៈកម្មាធិការនានាត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយមេឃុំ ចៅសង្កាត់។ ស្មៀនឃុំ សង្កាត់ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះមេឃុំ ចៅសង្កាត់។បុគ្គលិកឃុំ សង្កាត់ដទៃទៀតត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះមេឃុំ ចៅសង្កាត់ ។

## ២.១០. ទំនាក់ទំនងអន្តររដ្ឋបាល

ទំនាក់ទំនងអន្តររដ្ឋបាលរបស់ថ្នាក់ក្រោមជាតិ សំដៅដល់ទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា ឬទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័ន ឬទីភ្នាក់ងាររបស់រដ្ឋ។ ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ ជាគោលការណ៍ ក្រុមប្រឹក្សាឃុំ សង្កាត់មានទំនាក់ទំនង បីប្រភេទគឺទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេង ទំនាក់ទំនងជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ឬទីភ្នាក់ងាររបស់រដ្ឋ។ ទន្ទឹមនេះ ទំនាក់ទំនង អន្តររដ្ឋបាលរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចធ្វើឡើងតាមរយៈការតាមដាន ការត្រួតពិនិត្យ និងការធ្វើ អន្តរាគមន៍ពីក្រសួង ស្ថាប័នមានសមត្ថកិច្ចឬរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមការកំណត់ ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផងដែរ។

### ២.១០.១. ទំនាក់ទំនងជាមួយក្រុមប្រឹក្សាប្រភេទដូចគ្នា

ទំនាក់ទំនងជាមួយក្រុមប្រឹក្សាប្រភេទដូចគ្នាសំដៅដល់ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានដូចខាងក្រោមៈ

- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការប្រាស្រ័យទាក់ទង ចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នានានៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នានា ដើម្បីជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក សំដៅលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព។ ក្នុងការធ្វើ កិច្ចសហប្រតិបត្តិការនេះ ត្រូវអនុវត្តតាមកិច្ចព្រមព្រៀង ឬតាមការចាត់ចែងរួមគ្នា
- ក្រុមប្រឹក្សាឃុំ សង្កាត់អាចផ្តល់យោបល់ និងផ្តល់សេវាគាំទ្រផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងៗទៀតទៅតាមការស្នើសុំ។[19]

### ២.១០.២.ទំនាក់ទំនងជាមួយក្រុមប្រឹក្សាផ្សេងគ្នា

ទំនាក់ទំនងជាមួយក្រុមប្រឹក្សាប្រភេទផ្សេងគ្នាសំដៅដល់ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានដូចខាងក្រោមៈ

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គបោះឆ្នោតនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើការប្រាស្រ័យទាក់ទងចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ ជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ របស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ស្នើសុំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការឆ្លើយតប ទៅនឹងតម្រូវការប្រជាពលរដ្ឋ ជាពិសេសតម្រូវការនានាដែលរដ្ឋបាលឃុំ សង្កាត់ពុំអាច មានលទ្ធភាពឆ្លើយតបបានក្នុងក្របខ័ណ្ឌសិទ្ធិអំណាច មុខងារ និងធនធានរបស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើកិច្ចសហការជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីជួយឧបត្ថម្ភ គាំទ្រគ្នាទៅវិញទៅមក សំដៅលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍ មូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព
- ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបាននូវចំណូលចែករំលែកជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទៅតាម ការស្នើសុំ

[19] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១។

- ក្រុមប្រឹក្សាឃុំ សង្កាត់ចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ក្រុមប្រឹក្សាឃុំ សង្កាត់ស្នើសុំការគាំទ្រផ្នែករដ្ឋបាល បច្ចេកទេស និងធនធានពីក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អភិបាលរាជធានី ខេត្តត្រូវសម្របសម្រួលរវាងឃុំ សង្កាត់ពីរ ឬច្រើនអំពីបញ្ហាណាមួយ ដែលមានភាពប្រទាញប្រទង់គ្នា ឬមានជម្លោះជាមួយគ្នា ហើយដែលឃុំ សង្កាត់ទាំងនោះ មិនអាចដោះស្រាយបាន
- ក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈមេឃុំ ចៅសង្កាត់ ដាក់ជូនអភិបាលរាជធានី ខេត្ត និង ក្រុង ស្រុកនូវដីកា និងសេចក្តីសម្រេចរបស់ខ្លួន ដើម្បីស្នើសុំពិនិត្យនីត្យានុកូលភាព៖
    - ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក ដាក់ជូនអភិបាលស្រុក
    - ចំពោះក្រុមប្រឹក្សាសង្កាត់ក្នុងក្រុង ដាក់ជូនអភិបាលក្រុង
    - ចំពោះក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានី ដាក់ជូនអភិបាលរាជធានី
- សម្រាប់ដីកាបទបញ្ជាផ្ទៃ ក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈមេឃុំ ចៅសង្កាត់ ដាក់ជូន អភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យនីត្យានុកូលភាព។ សម្រាប់ព័ត៌មានលម្អិតពាក់ព័ន្ធ ការរៀបចំដីការបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ សូមមើលជំពូកទី៣។[20]

### ២.១០.៣. ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ និងភ្នាក់ងាររបស់រដ្ឋ

ក្រៅពីទំនាក់ទំនងអន្តររដ្ឋបាលជាមួយក្រុមប្រឹក្សាប្រភេទដូចគ្នា និងប្រភេទផ្សេងគ្នា ក្រុមប្រឹក្សាឃុំ សង្កាត់មានទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ ភ្នាក់ងាររបស់រដ្ឋ មានដូចខាងក្រោម៖

- ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើទំនាក់ទំនងជាផ្លូវការជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរ និងភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានា តាមរយៈអភិបាលរាជធានី ខេត្ត
- ក្រសួង ស្ថាប័ននានា អាជ្ញាធរ និងភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និងអន្តរជាតិនានា អាចធ្វើទំនាក់ទំនង និងកិច្ចសហការដោយផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់តាមការចាំបាច់ ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលរាជធានី ខេត្ត
- ក្រសួង ស្ថាប័ន អាជ្ញាធរ និងភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលមានតួនាទីក្នុងការគាំទ្រ ការអភិវឌ្ឍសមត្ថភាព និងបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធានាប្រសិទ្ធភាព នៃការបម្រើសេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការអនុវត្តមុខងារនានា

[20] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ឆ្នាំ២០០៨ ។

- អភិបាលរាជធានី ខេត្តត្រូវសហការ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ឬភ្នាក់ងារពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលមានភាពប្រទាញប្រទង់គ្នា ឬមានជម្លោះពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មអំណាចរបស់រដ្ឋចំពោះឃុំ សង្កាត់ ឬសេចក្តីសម្រេច ឬសកម្មភាព របស់ក្រសួង ស្ថាប័ន ឬភ្នាក់ងារទាំងនោះ។[21]

[21] អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់, ឆ្នាំ ២០០២។

# ជំពូកទី៣

# ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃ រដ្ឋបាលសង្កាត់ សាក់សំពៅ

# ជំពូកទី៣

# ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃរដ្ឋបាលសង្កាត់ សាក់សំពៅ

## ៣.១.ស្ថានភាពទូទៅ

### ៣.១.១.ទីតាំងភូមិសាស្ត្រ

សង្កាត់សាក់សំពៅ ជាសង្កាត់មួយក្នុងចំណោមសង្កាត់ចំនួន១២ ក្នុងរដ្ឋបាលខណ្ឌដង្កោ នៃរាជធានីភ្នំពេញ ដែលមានទំហំ ៧.៥ គីឡូម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹងសង្កាត់ព្រៃវែង,សង្កាត់ព្រៃស, សង្កាត់ពងទឹក ខាងត្បូងទល់នឹងសង្កាត់ទៀន,សង្កាត់គងនយ ខាងកើតទល់នឹងសង្កាត់ស្ពានថ្ម និងខាងលិចទល់នឹងសង្កាត់ក្រាំងពង្រ ។

**សង្កាត់សាក់សំពៅចែកចេញជា៧ភូមិ ២៤ក្រុមៈ**

- ភូមិពារាម មានប្រជាជនចំនួន៤៧គ្រួសារ ស្មើនឹង៤២៣នាក់
- ភូមិសាក់សំពៅ មានប្រជាជនចំនួន១៨៩គ្រួសារ ស្មើនឹង៨០២នាក់
- ភូមិកំរ៉ែង មានប្រជាជនចំនួន១៨៦គ្រួសារ ស្មើនឹង៧១៥នាក់
- ភូមិសំបួរ មានប្រជាជនចំនួន៥៩គ្រួសារ ស្មើនឹង២៧៤នាក់
- ភូមិក្រាំងតាផូ មានប្រជាជនចំនួន២៥៦គ្រួសារ ស្មើនឹង៩៩៤នាក់
- ភូមិខ្វិត មានប្រជាជនចំនួន៣៣៤គ្រួសារ ស្មើនឹង១៤៨១នាក់
- ភូមិពោធិ៍រលំ មានប្រជាជនចំនួន១០២គ្រួសារ ស្មើនឹង៤២៣នាក់។

### ៣.១.២.ស្ថានភាពប្រជាសាស្ត្រ

នៅក្នុងសង្កាត់សាក់សំពៅមានប្រជាជនសរុបចំនួន ៤,៨៨១នាក់ ក្នុងនោះប្រុសមានចំនួន២,៤៩០នាក់ និងស្រីមានចំនួន ២,៣៩១នាក់។ ក្នុងនោះអាយុ១៨ឆ្នាំឡើងមានចំនួន៣,៤០៥នាក់ ប្រុសមានចំនួន១,៧១៤ នាក់ និងស្រីមានចំនួន១,៧០១នាក់។

ប្រជាជនរស់នៅសង្កាត់សាក់សំពៅជាអ្នកកាន់ព្រះពុទ្ធសាសនា មានប្រពៃណីទំនៀមទំលាប់តាមរបៀបរស់នៅដូចជនជាតិខ្មែរពីបុរាណ។ មានន័យថាប្រជាជនទាំងអស់គោរពនិងរក្សានូវអត្តសញ្ញាណរបស់ខ្លួនជាខ្មែរ។ ដែលក្នុងសង្កាត់មានវត្តចំនួន២វត្ត ចំនួនព្រះសង្ឃ២៥អង្គ។

មុខរបររបស់ប្រជាជនមានដូចតទៅៈ មន្ត្រីរាជការ២០% កសិករ ៤០% កម្មករ៤០%

## ៣.២.លទ្ធផលដែលសម្រេចបាន(២០២១-២០២៣)

### ៣.២.១. ខណ្ឌនៈភាព

ផ្អែកតាមមុខងាររបស់រដ្ឋបាលសង្កាត់ក្នុងការបម្រើកិច្ចការមូលដ្ឋាន និងផែនការអភិវឌ្ឍន៍សង្កាត់រដ្ឋបាលសង្កាត់បានអនុវត្តសកម្មភាព និងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

**ក. ការផ្តល់សេវាសាធារណៈ**

**ក.១. ការងារសន្តិសុខ សណ្តាប់ធ្នាប់ ៖**

បានកសាងផែនការសកម្មភាពរបស់គណៈបញ្ជាការឯកភាពប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីការប្រើប្រាស់កម្លាំងពួនស្ទាក់ ចល័ត ល្បាត ត្រួតពិនិត្យអាវុធជាតិផ្ទុះ កម្លាំងប្រចាំការដើម្បីត្រៀម អន្តរាគមន៍នៅពេលមានសភាពការណ៍កើតឡើងជាយថាហេតុ។ ធ្វើបញ្ជីក្តាប់រាល់មុខសញ្ញាបទល្មើសចាស់ និងមុខសញ្ញាបទល្មើសដែលកំពុងស្រាវជ្រាវ មុខសញ្ញាក្រុមបងធំ ក្មេងទំនើង មុខសញ្ញាប្រើប្រាស់ សេព និងជួញដូរគ្រឿងញៀន។

- ការចូលរួមអនុវត្តគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព (២០២១-២០២៣)
  - បានផ្សព្វផ្សាយ ៣៦លើក អ្នកចូលរួម ១៥៣៣នាក់ ស្រី ១០៥១នាក់
  - បានធ្វើវេទិកាសាធារណៈ ៧លើក អ្នកចូលរួម ៣៦២២នាក់ ស្រី ២០៥១នាក់
- ការកសាងកម្លាំង
  - កម្លាំងនគរបាលចំនួន ១៩នាក់ ក្នុងនោះស្រី ០៣នាក់
  - កម្លាំងប្រជាការពារចំនួន៥៦នាក់ ថ្នាក់សង្កាត់ចំនួន ១២នាក់ ថ្នាក់ភូមិចំនួន៤៤នាក់
- សកម្មភាពបង្ក្រាបបទល្មើស (២០២១-២០២៣)
  - បទល្មើសព្រហ្មទណ្ឌបង្ក្រាបបានសរុបចំនួន ០៣ករណី ក្នុងនោះ៖ បទឧក្រិដ្ឋមានចំនួន ០២ករណី និង បទមជ្ឈឹមមានចំនួន ០១ករណី
  - បទល្មើសគ្រឿងញៀនបង្ក្រាបបាន សរុបចំនួន ០០ ករណី
  - គ្រោះថ្នាក់ចរាចរណ៍ កើតឡើង សរុបចំនួន ៥០ លើក

**ក.២.ការផ្តល់សេវារដ្ឋបាល ៖**

ដើម្បីសម្រេចគោលបំណងក្នុងការបម្រើប្រជាពលរដ្ឋ ឱ្យបានកាន់តែល្អប្រសើរឡើង ក្រុមប្រឹក្សាសង្កាត់ ស្មៀនសង្កាត់ ជំនួយការរដ្ឋបាលសង្កាត់ មន្ត្រីភូមិ ដែលជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បានយកចិត្តទុកដាក់ទៅលើ៖

- **ការផ្តល់ភាពងាយស្រួលក្នុងការទទួលយកសេវារបស់ប្រជាពលរដ្ឋ៖** តាមរយៈការផ្តល់ព័ត៌មានគ្រប់គ្រាន់ច្បាស់លាស់ និងងាយយល់ ព្រមទាំងត្រូវកាត់បន្ថយនូវការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញនានា

សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា ក្នុងការស្វែងរកសេវាដោយខ្លួនឯង និងការចំណាយបន្ថែមលើអ្នករត់ការក្រៅផ្លូវការ។លើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យប្រើប្រាស់ សេវាសាធារណៈតាមតម្រូវការរបស់ពួកគេ និងត្រូវដើរតួនាទីជាអ្នកសម្របសម្រួលក្នុងការផ្តល់ និងទទួលសេវាផងដែរ។

- **តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវា** ៖ ផ្តល់ព័ត៌មានបានទូលំទូលាយ ជាចំហដោយមិនរើសអើង និងយកចិត្តទុកដាក់ផ្តល់សេវាឱ្យបានទាន់ពេលវេលាកំណត់ និងមានគុណភាពជូនអ្នកប្រើប្រាស់ ដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនោះបានទុកលទ្ធភាពឱ្យអ្នកប្រើប្រាស់តាមដាន និងស្វែងយល់អំពីនីតិវិធីនៃការផ្តល់សេវា និងអាចធ្វើការទិតៀន តវ៉ា ឬទាមទារឱ្យមានការកែលំអលើចំណុចខ្វះខាតផ្សេងៗ តាមតម្រូវការ សំដៅលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពស្របតាមគោលការណ៍អភិបាលកិច្ចល្អ។
- **គុណភាព និងប្រសិទ្ធភាពនៃសេវា** ៖ គោរពបាននូវស្តង់ដារកំណត់ មានន័យថា អ្វីដែលបានកំណត់ជូនអ្នកប្រើប្រាស់ត្រូវតែធ្វើឲបានតាមការកំណត់នោះ ទាំងតម្លៃ ទាំងពេលវេលា និងគុណភាព។ គុណភាពនៃសេវាត្រូវបានកំណត់ផ្អែកលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា កម្រិតនៃការឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់។
- **តម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា** ៖ កន្លងមក មន្ត្រីរាជការផ្តល់សេវាក្នុងឥរិយាបថជាអ្នកគ្រប់គ្រង និងបានកំណត់ជាស្រេចនូវប្រភេទសេវា ដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់ ទោះជាសេវាមួយចំនួនអ្នកប្រើប្រាស់មិនត្រូវការក៏ដោយ។ ប៉ុន្តែក្នុងស្ថានភាពបច្ចុប្បន្ននេះ មន្ត្រីរាជការត្រូវផ្តល់សេវាក្នុងឥរិយាបថជា អ្នកផ្តល់សេវា ដោយត្រូវកំណត់ប្រភេទសេវាទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវាវិញ។

នៅក្នុងឆ្នាំ ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់សាក់សំពៅ បានខិតខំផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោម៖

| ល.រ. | បរិយាយ | ចំនួនសេវា | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| ១ | លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ | ៥៣ | ៦១ | ៤៥ | **១៥៩** |
| ២ | លិខិតបញ្ជាក់ទីលំនៅ | ៤៧ | ៣៩ | ២៥ | **១១១** |
| ៣ | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | ៩១ | ៨៣ | ១១២ | **២៨៦** |
| ៤ | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | ០៩ | ០៦ | ០៤ | **១៩** |
| ៥ | លិខិតបញ្ជាក់ទាយាទ | ០២ | ០៣ | ០៥ | **១០** |

| ល.រ. | បរិយាយ | ចំនួនសេវា | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| ៦ | លិខិតបញ្ជាក់កិរិយាមាយាទ | ០០ | ០១ | ០២ | **០៤** |
| ៧ | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | ០០ | ០៣ | ០០ | **០៣** |
| ៨ | លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ(គិតជាក្បាល) | ០ | ០ | ០ | **០** |
| ៩ | លិខិតបញ្ជាក់តបណ្តាញអគ្គិសនី | ០៣ | ០៥ | ០៣ | **១១** |
| ១០ | លិខិតបញ្ជាក់តបណ្តាញទឹកស្អាត | ០០ | ០២ | ០០ | **០២** |
| ១១ | លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ | ០ | ០ | ០១ | **០១** |
| ១២ | លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ | ០ | ០ | ០១ | **០១** |
| ១៣ | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (លិខិតដែលមិនមែនជាសមត្ថកិច្ច របស់ស្ថាប័នណាមួយ) | ១៥៣ | ១៣១ | ៩៦ | **៣៨០** |

**ក.៣. ការផ្តល់សេវាសង្គម**

សង្កាត់បានខិតខំលើកកម្ពស់អប់រំ បណ្តុះបណ្តាលដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានសង្កាត់ឱ្យមានការយល់ដឹងច្រើនពីបញ្ហាសុខភាពសាធារណៈ អនាម័យ និងវិធានការការពារមេរោគរាតត្បាតគ្រប់ប្រភេទ។ ប្រជាជនក្នុងមូលដ្ឋានបានទទួលការផ្សព្វផ្សាយពីបញ្ហានេះ និងមានការយល់ដឹងមួយចំនួនឱ្យគត់សម្គាល់ ជាពិសេសគឺបញ្ហាអប់រំ សុខភាពសាធារណៈ និងវិធានការការពារជំងឺឆ្លងផ្សេងៗ។

នៅក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់សាក់សំពៅ បានយកចិត្តទុកដាក់លើការងារសេវាសង្គម មានដូចជាការចុះសួរសុខទុក្ខប្រជាពលរដ្ឋដល់ខ្នងផ្ទះ ការធ្វើប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋមានេះជីវភាពក្រីក្រ និងងាយហានិភ័យ ការចូលរួមរំលែកទុក្ខជាមួយគ្រួសារសពប្រជាពលរដ្ឋក្នុងមូលដ្ឋាន ការចែកអំណោយ និងសម្ភារ ផ្សេងៗជូនប្រជាជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងងាយរងគ្រោះ មានដូចខាងក្រោម៖

| ល.រ. | បរិយាយ | ចំនួន | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| ១ | ចំនួនគ្រួសារទទួលអំណោយ**សម្តេចអគ្គមហាសេនាបតីសម្តេចតេជោ ហ៊ុន សែន និងសម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន** | ៧៤១ | ៧៦៤ | ៨៣៤ | **២៣៣៩** |

| ល.រ. | បរិយាយ | ចំនួន | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| ២ | ចំនួនគ្រួសារទទួលអំណោយរបស់កាកបាតក្រហមកម្ពុជា | ៧៤១ | ៧៦៤ | ៨៣៤ | **២៣៣៩** |
| ៣ | ការចុះសួរសុខទុក្ខដល់ខ្នងផ្ទះប្រជាពលរដ្ឋរបស់ក្រុមប្រឹក្សាសង្កាត់ (គ្រួសារ) | ៤២ | ៤៥ | ៤០ | **១២៧** |
| ៤ | ការចូលរួមរំលែកទុក្ខជាមួយគ្រួសារសពប្រជាពលរដ្ឋក្នុងមូលដ្ឋាន | ២៥ | ៤៩ | ១៧ | **៩១** |
| ៥ | ការចុះឈ្មោះ និងផ្តល់កាតវឹងជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ | ២០ | ៨០ | ៤០ | **១៤០** |
| ៦ | គ្រួសារក្រីក្រ និងងាយរងគ្រោះដែលសង្កាត់ចុះកំណត់អត្តសញ្ញាណ | ២៩៨ | ៣០ | ១៤០ | **៤៦៨** |
| ៧ | ការចុះសម្ភាសន៍ជនមានពិការភាព | ០ | ០ | ១៥៩ | **១៥៩** |
| ៨ | ការចុះសួរសុខទុក្ខស្ត្រី និងកុមារងាយរងគ្រោះ | ៦០ | ៦០ | ៦០ | **១៨០** |

**ក.៤. ការចុះបញ្ជីអត្រានុកូលដ្ឋាន៖**

នៅក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់សាក់សំពៅ បានខិតខំផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោម៖

| ល.រ. | បរិយាយ | ចំនួនសេវា | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| | **អត្រានុកូលដ្ឋាន** | | | | |
| ១ | សំបុត្រកំណើត | ៤៥ | ៦១ | ៧៨ | **១៨៤** |
| ២ | សេចក្តីចម្លងសំបុត្រកំណើត | ៤៥ | ៦១ | ៧៨ | **១៨៤** |
| ៣ | សំបុត្របញ្ជាក់កំណើត | ៥១ | ៥៨ | ២៦ | **១៣៥** |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៥១ | ៥៨ | ២៦ | **១៣៥** |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | ៦២ | ៧០ | ៦៨ | **២០០** |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | ៦២ | ៧០ | ៦៨ | **២០០** |

| ល.រ. | បរិយាយ | ចំនួនសៅ | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| ៧ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | 0 | 0 | 0 | **0** |
| ៨ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | 0 | 0 | 0 | **0** |
| ៩ | សំបុត្រមរណភាព | ២៥ | ៤៩ | ១៧ | **៩១** |
| ១០ | សេចក្តីចម្លងសំបុត្រមរណភាព | ២៥ | ៤៩ | ១៧ | **៩១** |
| **អត្តសញ្ញាណកម្ម** | | | | | |
| ១ | សៀវភៅស្នាក់នៅ(ក២) | ៥១ | ៤៥ | ៥២ | **១៤៨** |
| ២ | សៀវភៅគ្រួសារ(ក៤) | ២៥ | ២៩ | ៣២ | **៨៦** |
| ៣ | អត្តសញ្ញាណប័ណ្ណ | ១១៩ | ៩៥ | ២៣២ | **៤៤៦** |

### ខ. ការអភិវឌ្ឍមូលដ្ឋាន

**ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តៈ** នៅក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់សាក់សំពៅ បានអនុវត្តន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ មានដូចខាងក្រោមៈ

| ឆ្នាំ | ឈ្មោះគម្រោង | ទីតាំង(ភូមិ) | ប្រវែង | ថវិកា(រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| ២០២១ | ជួសជុលផ្លូវបេតុង | ក្រាំងតាផូ,កំរ៉ែង | ២៩១*៤ | ៩៣,000,000 | |
| ២០២២ | ជួសជុលផ្លូវបេតុង | ខ្វិត | ៤៤៧*៤ | ១០៩,000,000 | |
| ២០២៣ | ជួសជុលផ្លូវបេតុង | ខ្វិត | ៦១៧*៤ | ១៣៧,000,000 | |

### គ. ការធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋ

ក្រុមប្រឹក្សាសង្កាត់មានការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជាប្រចាំជាមួយប្រជាពលរដ្ឋរបស់ខ្លួន។ ដើម្បីធានាឱ្យមានគណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ឬគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាសង្កាត់បានរៀបចំយន្តការ និងមធ្យោបាយសមស្របនានាក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្លួនប្រកបដោយតម្លាភាព ការពិគ្រោះយោបល់ និងការទទួលបានព័ត៌មានគ្រប់គ្រាន់ ព្រមទាំងទទួលបាននូវព័ត៌មាន ឬពាក្យបណ្តឹង ត្រឡប់ពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីសេចក្តីសម្រេចរបស់ខ្លួន។

**គ.១.ការផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋ**

រដ្ឋបាលសង្កាត់សាក់សំពៅ បានរៀបចំយន្តការផ្ដល់សេវារដ្ឋបាល និងផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋបានល្អប្រសើរ និងទាន់ពេលវេលា។

**គ.២.ការទទួល និងឆ្លើយតបមតិយោបល់ ឬបណ្ដឹងតវ៉ាពីប្រជាពលរដ្ឋ**

បន្ទាប់ពីទទួលបានព័ត៌មាន សំណួរ ការស្នើសុំការបំភ្លឺ ឬការបារម្ភរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាសង្កាត់បានធ្វើការឆ្លើយតបបានយ៉ាងលឿនបំផុតតាមដែលអាចធ្វើបាន។ ការឆ្លើយតបធ្វើបានតាមរយៈ៖

- ការស្រាយបំភ្លឺ ការឆ្លើយតប ឬការបញ្ជាក់ធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ អំពីមូលហេតុនៃការសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចចិត្តនោះ ប្រកបដោយភាពសមហេតុផល និងអាចទទួលយកបានពីសំណាក់ប្រជាពលរដ្ឋ និងអ្នករងផលប៉ះពាល់។
- ការឆ្លើយតបដោយផ្ទាល់មាត់៖ ធ្វើឡើងតាមរយៈការជួបដោយផ្ទាល់ជាមួយអ្នកស្នើសុំ ឬតាមរយៈការប្រកាសផ្សព្វផ្សាយតាមមធ្យោបាយនានាដូចជា ឧគ្ឃោសនស័ព្ទ ឬវិទ្យុ និងឬតាមមធ្យោបាយសមស្របផ្សេងៗទៀត។
- ការឆ្លើយតបជាលាយលក្ខណ៍អក្សរ៖ អាចធ្វើឡើងតាមរយៈលិខិត ឬសារព័ត៌មាន សម្រាប់ឆ្លើយតបចំពោះបុគ្គល ឬក្រុមអ្នកស្នើសុំ។

**គ.៣.ការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋាន**

ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់ខិតខំសម្រុះសម្រួលដោះស្រាយវិវាទ ដូចខាងក្រោម៖

| ល.រ | ការបរិយាយ | ចំនួន | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | ចំនួនករណីទំនាស់ដែលសង្កាត់បានទទួល | ១៣ | ២៧ | ៣១ | **៧១** |
| ២ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយសង្កាត់ | ១៣ | ២៥ | ២៧ | **៦៥** |
| ៣ | ករណីដែលបានបញ្ជូនទៅសមត្ថកិច្ចបន្តឬស្ថាប័នពាក់ព័ន្ធ | ០ | ២ | ៤ | **៦** |

### ៣.២.២.បញ្ហាប្រឈម និងសំណូមពរ

ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំរបស់វិសាមញ្ញរបស់ក្រុមប្រឹក្សា អង្គប្រជុំបានលើកឡើងនូវបញ្ហាប្រឈម ឬសំណើសំណូមពរដែលពាក់ព័ន្ធនឹងប្រធានបទដែលកំណត់សរុបចំនួន០៨ ដែលក្នុងនោះរដ្ឋបាលសង្កាត់ត្រូវពិនិត្យដោះស្រាយចំនួន០៨ និងស្នើសុំអន្តរាគមន៍ដោះស្រាយដោយខណ្ឌសរុបចំនួន០៥ ដូចមានក្នុងតារាងខាងក្រោម៖

## ក. តារាងបញ្ហាប្រឈមដែលដោះស្រាយដោយរដ្ឋបាលឃុំ សង្កាត់សាមី

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | វិធានការដែលបានដាក់ចេញដោយសង្កាត់ |
|---|---|---|
| ១.រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលសង្កាត់ | | |
| - | ក្រុមប្រឹក្សាសង្កាត់ ជំនួយការរដ្ឋបាលសង្កាត់នៅមានកម្រិតពីតួនាទីភារកិច្ច និងឋានុក្រមដែលត្រូវទទួលខុសត្រូវ | បានរៀបចំសេចក្តីសម្រេចបែងចែកតួនាទី ភារកិច្ច និងការទទួលខុសត្រូវជូនដល់សមាជិកក្រុមប្រឹក្សសង្កាត់ និងជំនួយការសង្កាត់ |
| ២.មុខងាររបស់រដ្ឋបាលឃុំ សង្កាត់ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ) | | |
| - | -ក្រុមប្រឹក្សាសង្កាត់ទើបចូលថ្មីពួកគាត់ពុំសូវមានការយល់ដឹងបានច្រើនអំពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ដែលរដ្ឋាភិបាលបានផ្ទេរអោយ។<br>-សំណូមពរ ជួយបើកវគ្គបណ្តុះបណ្តាលខ្លីអំពីតួនាទីនិងភារកិច្ចដល់ពួកគាត់។ | ផ្តល់ជាឯកសារពាក់ព័ន្ធមួយចំនួនដើម្បីឱ្យបានអាន និងយល់ដឹងពីតួនាទី ភារកិច្ច |
| ៣.ធនធានមនុស្សនៅរដ្ឋបាលសង្កាត់ | | |
| - | -សមត្ថភាពបុគ្គលិកនៅមានកម្រិត<br>-សំណូមពរ បើកវគ្គបណ្តុះបណ្តាលខ្លីៗអំពីធនធានមនុស្ស។ | កន្លងមកសង្កាត់បានឱ្យជំនួយការសង្កាត់បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងអំពីការងាររដ្ឋបាល និងហិរញ្ញវត្ថុដែលរៀបចំឡើងដោយរដ្ឋបាលរាជធានីខណ្ឌ និងក្រសួង មន្ទីរនានាដែលពាក់ព័ន្ធ |
| ៤.ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ | | |
| - | -បញ្ហាប្រឈម ការចំណាយធនធានហិរញ្ញវត្ថុរបស់សង្កាត់នៅមានកំរិតមិនឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ។<br>-សាលាសង្កាត់កំពុងស្នើសុំចុះបញ្ជីតាមនីតិវិធីសុរិយោដី។<br>-សូមណូមពរ ជួយបំពេញបន្ថែមនៅធនធានហិរញ្ញវត្ថុរបស់សង្កាត់។ | សង្កាត់បានខិតខំអនុវត្តន៍ថវិកាប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល។ |

| | | |
|---|---|---|
| ៥.ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងឃុំ សង្កាត់ និងរវាងឃុំ សង្កាត់និងថ្នាក់ក្រោមជាតិ ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលឃុំ សង្កាត់ជាមួយប្រជាពលរដ្ឋ | | |
| - | -សង្កាត់បិទផ្សាយនៅរាល់ឯកសារផ្សេងៗ ដូចជា សេចក្តីជូនដំណឹង ការអភិវឌ្ឍន៍ឯកសារផ្សេងៗនៅតាមក្តាពត៌មានឬទីប្រជុំមួយចំនួនពួកគាត់ពុំសូវយកចិត្តទុកដាក់។<br>-បញ្ហាប្រឈមគឺ ពេលចុះផ្សព្វផ្សាយតាមភូមិ មិនសូវមានអ្នកចូលរួម ច្រើនតែស្ត្រីចាស់ៗដែលនៅផ្ទះទំនេរ និងមិនយកចិត្តទុកដាក់ស្តាប់។ | ក្រុមប្រឹក្សាសង្កាត់នៅតែខិតខំរៀបចំវេទិកាសាធារណៈតាមភូមិ ដើម្បីផ្សព្វផ្សាយព័ត៌មានជូនដល់ប្រជាពលរដ្ឋ |
| ៦.ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ | | |
| - | បញ្ហាប្រឈម ប្រជាពលរដ្ឋភាគច្រើនមកទទួលសេវាជាពិសេសសេវាអត្រានុកូលដ្ឋានមុនពេលផ្តិតស្នាមមេដៃ តែងតែឱ្យគាត់ពិនិត្យក្រែងមានការខុសឆ្គងកែតម្រូវភ្លាមៗ តែមួយចំនួនមិនសូវចាប់អារម្មណ៍លុះត្រាឆ្លងឆ្នាំហើយខុសមកបន្ទោសក្រុមការងារ ហើយមួយចំនួនមិនចេះថែរក្សាឯកសារផ្ទាល់ខ្លួនរបស់ពួកគាត់ទេ។<br>-បញ្ហាប្រឈម ប្រជាពលរដ្ឋមកទទួលសេវាភាគច្រើន មិនមានឯកសារគ្រប់គ្រាន់ | -រដ្ឋបាលសង្កាត់សាក់សំពៅ រៀបចំយន្តការច្រកចេញចូលតែមួយដើម្បីសេវារដ្ឋបាល និងផ្តល់ព័ត៌ពីការទទួលសេវា<br>-បានខិតខំផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋបានទាន់ពេលវេលា តាមតម្លាភាព និងអាចជឿទុកចិត្តបាន |
| ៧.ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្មមកលើរដ្ឋបាលឃុំ សង្កាត់ | | |
| - | ជារៀងរាល់ឆ្នាំរដ្ឋបាលសង្កាត់ដង្កោ បានទទួលការចុះធ្វើអធិការកិច្ច ឬសវនកម្ម ដើម្បីត្រួតពិនិត្យនិងកែលម្អការងារដែលអនុវត្តកន្លងមក និងមានឯកសារមួយចំនួននៅខ្វះខាត។ | សង្កាត់បានខិតខំកែលម្អរាល់ចំណុចខ្វះខាតដែលក្រុមការងារសវនកម្មបានណែនាំ |
| ៨.បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | |
| ១ | -ការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការបំពេញការងារនៅមានកម្រិតស្របពេលដែលតម្រូវការសេវាច្រើនឡើងៗ | រដ្ឋបាលសង្កាត់បញ្ជូនជំនួយការសង្កាត់ចូលរួមវគ្គបណ្តុះបណ្តាលផ្សេង អំពីការងារព័ត៌មានវិទ្យា ដែលរៀបចំឡើង |

| | | |
|---|---|---|
| | -សមត្ថភាពបុគ្គលិកនៅមានកម្រិតនៅឡើយ<br>-សំណូមពរ មានការបើកវគ្គបណ្តុះបណ្តាលធនធានមនុស្សបន្ថែម។ | ដោយរដ្ឋបាលរាជធានី ខណ្ឌ និងក្រសួងមន្ទីរនានាដែលពាក់ព័ន្ធ |

**ខ. បញ្ហាប្រឈមគន្លឹះ និងសំណើសំណូមពរដែលស្នើសុំអន្តរាគមន៍ដោះស្រាយដោយក្រុង ស្រុក ខណ្ឌ**

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ |
|---|---|
| **១.រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលសង្កាត់** | |
| - | ស្នើសុំលើកទឹកចិត្តមន្ត្រីជាប់កិច្ចសន្យាខណ្ឌដែលបំពេញការងារនៅសង្កាត់ និងជំនួយការហិរញ្ញវត្ថុបានក្របខណ្ឌដើម្បីនិរន្តភាពការងាររដ្ឋបាល។ |
| **២.មុខងាររបស់រដ្ឋបាលសង្កាត់ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ)** | |
| - | បញ្ហាប្រឈម ក្រុមប្រឹក្សាសង្កាត់ទើបចូលថ្មីពួកគាត់ពុំសូវមានការយល់ដឹងបានច្រើនអំពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ដែលរដ្ឋាភិបាលបានផ្ទេរអោយ។ |
| - | សំណូមពរ ជួយបើកវគ្គបណ្តុះបណ្តាលខ្លីអំពីតួនាទីនិងភារកិច្ចដល់ពួកគាត់។ |
| **៣.ធនធានមនុស្សនៅរដ្ឋបាលសង្កាត់** | |
| - | បញ្ហាប្រឈម ការយល់ដឹងរបស់មន្ត្រីសង្កាត់នៅមានកម្រិត។ |
| | សំណូមពរ បើកវគ្គបណ្តុះបណ្តាលខ្លីៗអំពីធនធានមនុស្ស។ |
| **៤.ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលសង្កាត់** | |
| - | មិនមានអ្វីគួរឱ្យកត់សម្គាល់ |
| **៥.ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងសង្កាត់ និងរវាងសង្កាត់និងថ្នាក់ក្រោមជាតិ ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលសង្កាត់ជាមួយប្រជាពលរដ្ឋ** | |
| - | មិនមានអ្វីគួរឱ្យកត់សម្គាល់ |
| **៦.ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលសង្កាត់** | |
| - | -បញ្ហាខុសឈ្មោះ ក៏ដូច ជាទិន្នន័យផ្សេងៗនៅក្នុងសំបុត្រកំណើតនិងសំបុត្របញ្ជាក់កំណើត ជាពិសេសសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ដែលធ្វើនៅក្នុងឆ្នាំយុទ្ធនាការ គឺពិបាកក្នុងការកែតម្រូវ ព្រោះត្រូវស្នើសុំដល់តុលាការហើយមានការយឺតយ៉ាវមិនអាចបំពេញតាមតម្រូវការរបស់ពួកគាត់បានទាន់ពេលវេលា។ |

| | |
|---|---|
| **៧.ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្មរដ្ឋបាលសង្កាត់** | |
| - | មិនមានអ្វីគួរឱ្យកត់សម្គាល់ |
| **៨.បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** | |
| - | -បញ្ហាប្រឈម ការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការបំពេញការងារនៅមានកម្រិត ស្របពេលដែលតម្រូវការសេវាច្រើនឡើងៗ។<br>-សមត្ថភាពបុគ្គលិកនៅមានកម្រិតនៅឡើយ |
| | សំណូមពរ មានការបើកវគ្គបណ្ដុះបណ្ដាលធនធានមនុស្ស និងព័ត៌មានវិទ្យា។ |

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «ការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ» រួចមកហើយនេះអាត្មាភាព អាចធ្វើសេចក្តីសន្និដ្ឋានបានថា សកម្មភាពការងារនៅ ក្នុងការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ពិតជាមានភាពល្អប្រសើរហើយ ដោយអនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានខិតខំរៀបចំដាក់ចេញដើម្បីធ្វើការបម្រើប្រជាពលរដ្ឋ ដែលនេះជាការបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមជនបទ ជាពិសេស គឺការអនុវត្តនូវគោលនយោបាយក្នុងការគ្រប់គ្រងនៅមូលដ្ឋានដែលជារដ្ឋបាលថ្នាក់ក្រោមជាតិមួយដ៏សំខាន់ដើម្បីជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋបានចូលរួមសកម្មភាពយ៉ាងពេញលេញនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួនដែលនេះជាដំណើរការជំរុញឱ្យមានលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនៅមូលដ្ឋាន។ ម្យ៉ាងវិញទៀត ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះ ជាមូលដ្ឋានគ្រឹះ ដើម្បីរួមចំណែកនៅក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន និងមានស្ថេរភាពផងដែរ។ ជាងនេះទៅទៀត នៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះបានឈានទៅរកការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងលើកកម្ពស់ការអភិវឌ្ឍនៅក្នុងមូលដ្ឋានដើម្បីជំរុញអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិឱ្យមានសន្ទុះ ខ្លាំងក្លារីកចម្រើនជឿនលឿនទៅមុខ។

ផ្អែកទៅតាមការសិក្សាស្រាវជ្រាវទៅលើទ្រឹស្តី និងការចុះទៅដល់ទីតាំងផ្ទាល់នៃសង្កាត់សាក់សំពៅ អាត្មាភាពសង្កេតឃើញថា មានវឌ្ឍនភាព មានការរីកចម្រើន ពោលគឺការអភិវឌ្ឍជឿនលឿនទៅមុខពីមួយអាណត្តិទៅមួយអាណត្តិគួរឱ្យកត់សម្គាល់ ដែលនេះបញ្ជាក់ឱ្យឃើញថា ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះ ពិតជាទទួលបាននូវផ្លែផ្កាល្អប្រសើរស្របតាមការចង់បានរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង នៅក្នុងសង្កាត់សាក់សំពៅយើងតាំងពីអាណត្តិទី១ រហូតមកដល់អាណត្តិទី៥នេះ បានប្រែក្លាយអភិវឌ្ឍន៍ខ្លួនយ៉ាងឆាប់រហ័សពីសង្កាត់មួយដែលមានការអភិវឌ្ឍតិចតួចទៅជាសង្កាត់ដែលមានការអភិវឌ្ឍស្ទើរគ្រប់វិស័យរួមមានដូចជា ប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ បណ្តាញអគ្គិសនី ទីផ្សារ សាលារៀនជាដើម ដែលសុទ្ធសឹងជាសរសៃឈាមនៃការអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់។

សរុបសេចក្តីមក ការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ ដែលកំពុងតែដឹកនាំដោយក្រុមប្រឹក្សាសង្កាត់នៅក្នុងអាណត្តិទី៥នេះ ពិតជាមានលក្ខណៈល្អប្រសើរដែលសម្រេចបាននូវសមិទ្ធផលនានា ជាច្រើនសម្រាប់ការអភិវឌ្ឍនៅក្នុងសង្កាត់ទាំងមូល ព្រមទាំងបានដោះស្រាយបញ្ហាការលំបាកមួយចំនួនធំទៅតាម សំណូមពររបស់ប្រជាពលរដ្ឋផងដែរ ក៏ប៉ុន្តែទន្ទឹមនឹងមានការរីកចម្រើន ក៏នៅមានចំណុចខ្វះខាតមួយចំនួនដែលសង្កាត់ត្រូវធ្វើការដោះស្រាយ និងកែលម្អដើម្បីឱ្យមានភាពល្អប្រសើរឡើងថែមទៀត ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវ និងការធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងលទ្ធផលនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "ការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ" រួចមកហើយនេះ អាត្មាភាពយល់ឃើញថា មិនទាន់មានលក្ខណៈល្អប្រសើរគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារនៅមានការខ្វះខាតចន្លោះប្រហោង ឆកល្វែងចំណុចខ្លះ ដែលរដ្ឋាភិបាលគួរយកចិត្តទុកដាក់បន្ថែមទៀត និងបំពេញនូវចំណុចខ្វះខាតទាំងនោះឱ្យបានគ្រប់ជ្រុងជ្រោយ ហើយអាត្មាភាព សូមចូលរួមចំណែកជាគំនិតមតិយោបល់ខ្លះៗនៅក្នុងការផ្តល់ជាអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលសង្កាត់ សាក់សំពៅ ដូចខាងក្រោមនេះ៖

- រាជរដ្ឋាភិបាល គួរតែបើកវគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិកឃុំ សង្កាត់ ឱ្យបានច្រើនដងដើម្បីបង្កើនសមត្ថភាពការងារ ជាពិសេស ផ្នែកបច្ចេកទេស
- រាជរដ្ឋាភិបាល គួរតែបង្កើនសមាសភាពមន្ត្រីរាជការឱ្យបានសមស្របទៅតាមទំហំឃុំ សង្កាត់ និងចំនួនប្រជាជន ដើម្បីងាយស្រួលធ្វើការបានលឿនទាន់ពេលវេលា និងតម្រូវការរបស់ប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែយកចិត្តទុកដាក់នៅក្នុងការត្រួតពិនិត្យផ្ទៃក្នុងទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ឃុំដើម្បីឱ្យមានគណនេយ្យភាព និងតម្លាភាព
- ក្រុមប្រឹក្សាឃុំ សង្កាត់ គួរតែត្រួតពិនិត្យ និងវាយតម្លៃទៅលើការបំពេញការងាររបស់បុគ្គលិកឃុំ អំពីការប្រើប្រាស់ពាក្យពេចន៍សម្តី កាយវិការ និងឥរិយាបថចំពោះប្រជាពលរដ្ឋ ដែលគាត់មកទទួលសេវា ឬសាកសួរព័ត៌មានផ្សេងៗ
- ក្រុមប្រឹក្សាឃុំ សង្កាត់ គួរតែផ្តល់សេវាជូនដល់ប្រជាពលរដ្ឋ ឱ្យកាន់តែមានភាពឆាប់រហ័ស និងទាន់ពេលវេលា នៅពេលដែលពួកគាត់មកទទួលសេវា
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយគ្មានភាពលំអៀង និងតម្លាភាព
- ក្រុមប្រឹក្សាឃុំ សង្កាត់គួរតែចុះជួបប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យបានញឹកញាប់ ដើម្បីដឹងពីសុខទុក្ខ និងតម្រូវការរបស់ប្រជាពលរដ្ឋ

បន្ថែមពីលើនេះទៀត ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន គួរតែមានការយល់ខ្លះៗដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងត្រូវចេះតាមដានការធ្វើការងាររបស់មន្ត្រីឃុំ សង្កាត់ផងដែរ។

# ឯកសារយោង

## ឯកសារគតិយុត្ត

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

២. ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

៣. ព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៤. ព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៥. ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៦. ព្រះរាជក្រមលេខ នស/រកម/១០១៧/១១២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៧. ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៨. អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និង ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់។

៩. ប្រកាសលេខ១៣២៩ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្តីពីតួនាទីភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់។

១០. ប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ។

១១. សេចក្តីណែនាំសលេខ ០៣៥ស.ណ.ន ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១២. ផែនការណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០២០ ផ.ក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ស្តីពីការចាត់តាំង អនុវត្ត«គោលនយោបាយភូមិឃុំ មានសុវត្ថិភាព»។

## ឯកសារជាសៀវភៅ និងឯកសារផ្សេងៗ


១៣. សម្ដេច ជួន ណាត វចនានុក្រមខ្មែរ ភាគ១&២ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧។

១៤. បណ្ឌិត សាយ បូរី, នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១២។

១៥. ហៀង សាង, នីតិរដ្ឋបាលទូទៅ បោះពុម្ពលើកទី៤ ឆ្នាំ២០១៧។

១៦. សៀវភៅណែនាំស្ដីពី កិច្ចការរដ្ឋបាលឃុំ សង្កាត់, ខែវិច្ឆិកា ឆ្នាំ២០០៥។

១៧. ក្រសួងមហាផ្ទៃ.«មេរៀនការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់តាមបែបវិមជ្ឈការ»ខែឧសភា ឆ្នាំ២០០៧

១៨. ក្រសួងមហាផ្ទៃ. «ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ» ខែកក្កដា ឆ្នាំ២០១៧។

១៩. ក្រសួងមហាផ្ទៃ. «អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់» ខែវិច្ឆិកា ឆ្នាំ២០០៥។

២០. ក្រសួងមហាផ្ទៃ. «អភិបាលកិច្ចល្អ» បោះពុម្ពលើកទី៤ ខែកុម្ភៈ ឆ្នាំ២០១៣។

២១. សៀវភៅណែនាំស្ដីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ដែលរៀបរៀងដោយអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ឆ្នាំ២០០៥។

២២. របាយការណ៍ស្ដីពីស្ថិតិប្រជាពលរដ្ឋប្រចាំឆ្នាំរបស់សង្កាត់ សាក់សំពៅ ចុះថ្ងៃទី២៩ខែមិថុនា ឆ្នាំ២០២៣។

២៣. របាយការណ៍ស្ដីពីលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់អំពីវឌ្ឍនភាព បញ្ហាប្រឈម ដំណោះស្រាយ និងសំណើសំណូមពរក្នុងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេល៣ឆ្នាំ (២០២១ ដល់២០២៣) របស់រដ្ឋបាលសង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

១. ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

២. អនុក្រឹត្យលេខ ២២ អ.ន.ក្រ.ប.ក ស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រាជរដ្ឋាភិបាល

៣. របាយការណ៍ស្តីពីស្ថិតិប្រជាពលរដ្ឋប្រចាំឆ្នាំរបស់សង្កាត់ សាក់សំពៅ ចុះថ្ងៃទី២៩ខែមិថុនា ឆ្នាំ ២០២៣។

៤. របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់អំពីវឌ្ឍនភាព បញ្ហាប្រឈម ដំណោះស្រាយ និងសំណើសំណូមពរក្នុងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេល៣ឆ្នាំ (២០២១ ដល់ ២០២៣) របស់រដ្ឋបាលសង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

# ១.ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ២.អនុក្រឹត្យលេខ ២២ អ.ន.ក្រ.ប.ក ស្តីពីការផ្ទេរមុខងារ
## អំណាច តួនាទី និងភារកិច្ច
## ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រាជរដ្ឋាភិបាល

## ៣.របាយការណ៍ស្តីពីស្ថិតិប្រជាពលរដ្ឋប្រចាំឆ្នាំរបស់សង្កាត់ សាក់សំពៅ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣។

ឧបសម្ព័ន្ធទី១៖ ស្ថិតិប្រជាពលរដ្ឋ

| ល.រ. | ឈ្មោះភូមិ | ចំនួនគ្រួសារ | | | ប្រជាពលរដ្ឋទូទៅ | | | | | | ប្រជាពលរដ្ឋ១៨ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | | |
| | | សរុប | អចិន្ត្រៃយ៍ | បណ្ដោះអាសន្ន | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | ក្នុង | ក្រៅ |
| ១ | គោកខ្វិតលិច | 102 | 99 | 03 | 423 | 214 | 411 | 208 | 12 | 06 | 305 | 155 | 294 | 148 | 11 | 06 | 0 | 0 |
| ២ | ខ្ទុំ | 334 | 288 | 46. | 1481 | 727 | 1358 | 673 | 123 | 54 | 963 | 459 | 848 | 409 | 115 | 50 | 03 | 07 |
| ៣ | ព្រែកតាទៀ | 256 | 177 | 79 | 994 | 497 | 734 | 374 | 260 | 125 | 677 | 334 | 491 | 242 | 186 | 92 | 0 | 01 |
| ៤ | កំពង់ទន្លេ | 186 | 136 | 50 | 715 | 336 | 559 | 270 | 156 | 66 | 539 | 270 | 395 | 213 | 144 | 57 | 0 | 01 |
| ៥ | សំបួរ | 59 | 58 | 01 | 274 | 143 | 269 | 141 | 05 | 02 | 206 | 114 | 203 | 113 | 03 | 01 | 0 | 0 |
| ៦ | សាកសំពៅ | 189 | 185 | 04 | 802 | 405 | 788 | 400 | 14 | 05 | 590 | 304 | 576 | 299 | 14 | 05 | 0 | 02 |
| ៧ | តាភាព | 47 | 46 | 01 | 192 | 69 | 190 | 69 | 02 | 0 | 135 | 65 | 133 | 65 | 02 | 0 | 0 | 0 |
| សរុប | | 1173 | 989 | 184 | 4881 | 2391 | 4300 | 2174 | 572 | 256 | 3415 | 1701 | 2940 | 1490 | 475 | 211 | 03 | 11 |

ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី២៥....ខែ[illegible]ឆ្នាំ២០២៣.

(សេចក្ដីពន្យល់៖ ធ្វើបច្ចុប្បន្នភាពតារាងស្ថិតិដោយផ្អែកតាមទិន្នន័យជាក់ស្ដែងរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ)

# របាយការណ៍

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់អំពីវឌ្ឍនភាព បញ្ហាប្រឈម

## ដំណោះស្រាយ និងសំណើសំណូមពរក្នុងអនុវត្ត

## កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេល៣ឆ្នាំ (២០២១ ដល់២០២៣)

## របស់រដ្ឋបាលសង្កាត់សាក់សំពៅ ខណ្ឌដង្កោ  រាជធានីភ្នំពេញ

នៅក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់សាក់សំពៅ បានខិតខំផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោម៖

| ល.រ. | បរិយាយ | ចំនួនសេវា | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| ១ | លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ | ៥៣ | ៦១ | ៤៥ | **១៥៩** |
| ២ | លិខិតបញ្ជាក់ទីលំនៅ | ៤៧ | ៣៩ | ២៥ | **១១១** |
| ៣ | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | ៩១ | ៨៣ | ១១២ | **២៨៦** |
| ៤ | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | ០៩ | ០៦ | ០៤ | **១៩** |
| ៥ | លិខិតបញ្ជាក់ទាយាទ | ០២ | ០៣ | ០៥ | **១០** |
| ៦ | លិខិតបញ្ជាក់កិរិយាមាយាទ | ០០ | ០១ | ០២ | **០៤** |
| ៧ | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | ០០ | ០៣ | ០០ | **០៣** |
| ៨ | លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ(គិតជាក្បាល) | ០ | ០ | ០ | **០** |
| ៩ | លិខិតបញ្ជាក់តបណ្តាញអគ្គិសនី | ០៣ | ០៥ | ០៣ | **១១** |
| ១០ | លិខិតបញ្ជាក់តបណ្តាញទឹកស្អាត | ០០ | ០២ | ០០ | **០២** |
| ១១ | លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ | ០ | ០ | ០១ | **០១** |
| ១២ | លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ | ០ | ០ | ០១ | **០១** |
| ១៣ | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត (លិខិតដែលមិនមែនជាសមត្ថកិច្ច របស់ស្ថាប័នណាមួយ) | ១៥៣ | ១៣១ | ៩៦ | **៣៨០** |

ក.៣.ការផ្តល់សេវាសង្គម ៖

| ល.រ. | បរិយាយ | ចំនួន | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| ១ | ចំនួនគ្រួសារទទួលអំណោយ**សម្តេចអគ្គមហាសេនាបតីសម្តេចតេជោ ហ៊ុន សែន និងសម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន** | ៧៤១ | ៧៦៤ | ៨៣៤ | **២៣៣៩** |
| ២ | ចំនួនគ្រួសារទទួលអំណោយរបស់កាកបាតក្រហមកម្ពុជា | ៧៤១ | ៧៦៤ | ៨៣៤ | **២៣៣៩** |
| ៣ | ការចុះសួរសុខទុក្ខដល់ខ្នងផ្ទះប្រជាពលរដ្ឋរបស់ក្រុមប្រឹក្សាសង្កាត់ (គ្រួសារ) | ៤២ | ៤៥ | ៤០ | **១២៧** |
| ៤ | ការចូលរួមរំលែកទុក្ខជាមួយគ្រួសារសពប្រជាពលរដ្ឋក្នុងមូលដ្ឋាន | ២៥ | ៤៩ | ១៧ | **៩១** |
| ៥ | ការចុះឈ្មោះ និងផ្តល់កាតវីងជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ | ២០ | ៨០ | ៤០ | **១៤០** |
| ៦ | គ្រួសារក្រីក្រ និងងាយរងគ្រោះដែលសង្កាត់ចុះកំណត់អត្តសញ្ញាណ | ២៩៨ | ៣០ | ១៤០ | **៤៦៨** |
| ៧ | ការចុះសម្ភាសន៍ជនមានពិការភាព | ០ | ០ | ១៥៩ | **១៥៩** |
| ៨ | ការចុះសួរសុខទុក្ខស្ត្រី និងកុមារងាយរងគ្រោះ | ៦០ | ៦០ | ៦០ | **១៨០** |

### ក.៤.ការចុះបញ្ជីអត្រានុកូលដ្ឋានៈ

នៅក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់សាក់សំពៅ បានខិតខំផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោមៈ

| ល.រ. | បរិយាយ | ចំនួនសេវា | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុបរួម |
| | **អត្រានុកូលដ្ឋាន** | | | | |
| ១ | សំបុត្រកំណើត | ៤៥ | ៦១ | ៧៨ | **១៨៤** |
| ២ | សេចក្តីចម្លងសំបុត្រកំណើត | ៤៥ | ៦១ | ៧៨ | **១៨៤** |
| ៣ | សំបុត្របញ្ជាក់កំណើត | ៥១ | ៥៨ | ២៦ | **១៣៥** |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ៥១ | ៥៨ | ២៦ | **១៣៥** |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | ៦២ | ៧០ | ៦៨ | **២០០** |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | ៦២ | ៧០ | ៦៨ | **២០០** |
| ៧ | សំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | ០ | ០ | ០ | **០** |
| ៨ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | ០ | ០ | ០ | **០** |
| ៩ | សំបុត្រមរណភាព | ២៥ | ៤៩ | ១៧ | **៩១** |
| ១០ | សេចក្តីចម្លងសំបុត្រមរណភាព | ២៥ | ៤៩ | ១៧ | **៩១** |
| | **អត្តសញ្ញាណកម្ម** | | | | |
| ១ | សៀវភៅស្នាក់នៅ(ក២) | ៥១ | ៤៥ | ៥២ | **១៤៨** |
| ២ | សៀវភៅគ្រួសារ(ក៤) | ២៥ | ២៩ | ៣២ | **៨៦** |
| ៣ | អត្តសញ្ញាណប័ណ្ណ | ១១៩ | ៩៥ | ២៣២ | **៤៤៦** |

ខ). ការអភិវឌ្ឍមូលដ្ឋាន

**ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តៈ** នៅក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់សាក់សំពៅ បានអនុវត្តន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ មានដូចខាងក្រោម៖

| ឆ្នាំ | ឈ្មោះគម្រោង | ទីតាំង(ភូមិ) | ប្រវែង | ថវិកា(រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| ២០២១ | ជួសជុលផ្លូវបេតុង | ក្រាំងតាផូ,កំរែង | ២៩១*៤ | ៩៣,000,000 | |
| ២០២២ | ជួសជុលផ្លូវបេតុង | ខ្វិត | ៤៤៧*៤ | ១០៩,000,000 | |
| ២០២៣ | ជួសជុលផ្លូវបេតុង | ខ្វិត | ៦១៧*៤ | ១៣៧,000,000 | |

**គ.៣.ការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋាន៖** ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ រដ្ឋបាលសង្កាត់ខិតខំសម្រុះសម្រួលដោះស្រាយវិវាទ ដូចខាងក្រោម៖

| ល.រ | ការបរិយាយ | ចំនួន | | | |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | សរុប |
| ១ | ចំនួនករណីទំនាស់ដែលសង្កាត់បានទទួល | ១៣ | ២៧ | ៣១ | **៧១** |
| ២ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយសង្កាត់ | ១៣ | ២៥ | ២៧ | **៦៥** |
| ៣ | ករណីដែលបានបញ្ជូនទៅសមត្ថកិច្ចបន្ត ឬស្ថាប័នពាក់ព័ន្ធ | ០ | ២ | ៤ | **៦** |

**បញ្ហាប្រឈម និងសំណើសំណូមពរ**

ក. តារាងបញ្ហាប្រឈមដែលដោះស្រាយដោយរដ្ឋបាលឃុំ សង្កាត់សាមី

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ | វិធានការដែលបានដាក់ចេញដោយសង្កាត់ |
|---|---|---|
| ១.រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលសង្កាត់ | | |
| - | ក្រុមប្រឹក្សាសង្កាត់ ជំនួយការរដ្ឋបាលសង្កាត់នៅមានកម្រិតពីតួនាទីភារកិច្ច និងឋានុក្រមដែលត្រូវទទួលខុសត្រូវ | បានរៀបចំសេចក្តីសម្រេចបែងចែកតួនាទី ភារកិច្ច និងការទទួលខុសត្រូវជូនដល់សមាជិកក្រុមប្រឹក្សសង្កាត់ និងជំនួយការសង្កាត់ |
| ២.មុខងាររបស់រដ្ឋបាលឃុំ សង្កាត់ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ) | | |
| - | -ក្រុមប្រឹក្សាសង្កាត់ទើបចូលថ្មីពួកគាត់ពុំសូវមានការយល់ដឹងបានច្រើនអំពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ដែលរដ្ឋាភិបាលបានផ្ទេរអោយ។<br>-សំណូមពរ ជួយបើកវគ្គបណ្តុះបណ្តាលខ្លីអំពីតួនាទីនិងភារកិច្ចដល់ពួកគាត់។ | ផ្តល់ជាឯកសារពាក់ព័ន្ធមួយចំនួនដើម្បីឱ្យបានអាន និងយល់ដឹងពីតួនាទី ភារកិច្ច |
| ៣.ធនធានមនុស្សនៅរដ្ឋបាលសង្កាត់ | | |
| - | -សមត្ថភាពបុគ្គលិកនៅមានកម្រិត<br>-សំណូមពរ បើកវគ្គបណ្តុះបណ្តាលខ្លីៗអំពីធនធានមនុស្ស។ | កន្លងមកសង្កាត់បានឱ្យជំនួយការសង្កាត់បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងអំពីការងាររដ្ឋបាល និងហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយរដ្ឋបាលរាជធានី ខណ្ឌ និងក្រសួង មន្ទីរនានាដែលពាក់ព័ន្ធ |
| ៤.ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ | | |
| - | -បញ្ហាប្រឈម ការចំណាយធនធានហិរញ្ញវត្ថុរបស់សង្កាត់នៅមានកំរិតមិនឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ។<br>-សាលាសង្កាត់កំពុងស្នើសុំចុះបញ្ជីតាមនីតិវិធីសុរិយោដី។<br>-សូមណូមពរ ជួយបំពេញបន្ថែមនៅធនធានហិរញ្ញវត្ថុរបស់សង្កាត់។ | សង្កាត់បានខិតខំអនុវត្តន៍ថវិកាប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល។ |
| ៥.ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងឃុំ សង្កាត់ និងរវាងឃុំ សង្កាត់និងថ្នាក់ក្រោមជាតិ ព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលឃុំ សង្កាត់ជាមួយប្រជាពលរដ្ឋ | | |
| - | -សង្កាត់បិទផ្សាយនៅរាល់ឯកសារផ្សេងៗ ដូចជាសេចក្តីជូនដំណឹង ការអភិវឌ្ឍន៍ឯកសារផ្សេងៗនៅតាមក្តាពត៌មានឬទីប្រជុំមួយចំនួនពួកគាត់ពុំសូវយកចិត្តទុកដាក់។ | ក្រុមប្រឹក្សាសង្កាត់នៅតែខិតខំរៀបចំវេទិកាសាធារណៈតាមភូមិ ដើម្បីផ្សព្វផ្សាយព័ត៌មានជូនដល់ប្រជាពលរដ្ឋ |

| | | |
|---|---|---|
| | -បញ្ហាប្រឈមគឺ ពេលចុះផ្សព្វផ្សាយតាមភូមិ មិនសូវមានអ្នកចូលរួម ច្រើនតែស្ត្រីចាស់ៗដែលនៅផ្ទះទំនេរ និងមិនយកចិត្តទុកដាក់ស្តាប់។ | |
| ៦.ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ | | |
| - | បញ្ហាប្រឈម ប្រជាពលរដ្ឋភាគច្រើនមកទទួលសេវា ជាពិសេសសេវាអត្រានុកូលដ្ឋានមុនពេលផ្តិតស្នាមមេដៃ តែងតែឱ្យគាត់ពិនិត្យក្រែងមានការខុសឆ្គងកែតម្រូវភ្លាមៗ តែមួយចំនួនមិនសូវចាប់អារម្មណ៍លុះត្រាឆ្លងឆ្នាំហើយខុសមកបន្ទោសក្រុមការងារ ហើយមួយចំនួនមិនចេះថែរក្សាឯកសារផ្ទាល់ខ្លួនរបស់ពួកគាត់ទេ។<br>-បញ្ហាប្រឈម ប្រជាពលរដ្ឋមកទទួលសេវាភាគច្រើន មិនមានឯកសារគ្រប់គ្រាន់ | -រដ្ឋបាលសង្កាត់សាក់សំពៅ រៀបចំយន្តការច្រកចេញចូលតែមួយដើម្បីសេវារដ្ឋបាល និងផ្តល់ព័ត៌ពីការទទួលសេវា<br>-បានខិតខំផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋបានទាន់ពេលវេលា តាមតម្លាភាព និងអាចជឿទុកចិត្តបាន |
| ៧.ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្មមកលើរដ្ឋបាលឃុំ សង្កាត់ | | |
| - | ជារៀងរាល់ឆ្នាំរដ្ឋបាលសង្កាត់ដង្កោ បានទទួលការចុះធ្វើអធិការកិច្ច ឬសវនកម្ម ដើម្បីត្រួតពិនិត្យនិងកែលម្អការងារដែលអនុវត្តកន្លងមក និងមានឯកសារមួយចំនួននៅខ្វះខាត។ | សង្កាត់បានខិតខំកែលម្អរាល់ចំណុចខ្វះខាតដែលក្រុមការងារសវនកម្មបានណែនាំ |
| ៨.បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | |
| ១ | -ការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការបំពេញការងារនៅមានកម្រិតស្របពេលដែលតម្រូវការសេវាច្រើនឡើងៗ<br>-សមត្ថភាពបុគ្គលិកនៅមានកម្រិតនៅឡើយ<br>-សំណូមពរ មានការបើកវគ្គបណ្តុះបណ្តាលធនធានមនុស្សបន្ថែម។ | រដ្ឋបាលសង្កាត់បញ្ជូនជំនួយការសង្កាត់ចូលរួមវគ្គបណ្តុះបណ្តាលផ្សេង អំពីការងារព័ត៌មានវិទ្យា ដែលរៀបចំឡើងដោយរដ្ឋបាលរាជធានីខណ្ឌ និងក្រសួង មន្ទីរនានាដែលពាក់ព័ន្ធ |

ខ. បញ្ហាប្រឈមគន្លឹះ និងសំណើសំណូមពរដែលស្នើសុំអន្តរាគមន៍ដោះស្រាយដោយក្រុង ស្រុក ខណ្ឌ

| ល.រ | បញ្ហាប្រឈម/សំណើសំណូមពរ |
|---|---|
| **១.រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងាររបស់រដ្ឋបាលសង្កាត់** | |
| | |
| - | ស្នើសុំលើកទឹកចិត្តមន្ត្រីជាប់កិច្ចសន្យាខណ្ឌដែលបំពេញការងារនៅសង្កាត់ និងជំនួយការហិរញ្ញវត្ថុបានក្របខណ្ឌដើម្បីនិរន្តភាពការងាររដ្ឋបាល។ |
| **២.មុខងាររបស់រដ្ឋបាលសង្កាត់ (មុខងារជាអាណត្តិទូទៅ និងមុខងារដែលបានផ្ទេរ)** | |
| - | បញ្ហាប្រឈម ក្រុមប្រឹក្សាសង្កាត់ទើបចូលថ្មីពួកគាត់ពុំសូវមានការយល់ដឹងបានច្រើនអំពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ដែលរដ្ឋាភិបាលបានផ្ទេរអោយ។ |
| - | សំណូមពរ ជួយបើកវគ្គបណ្តុះបណ្តាលខ្លីអំពីតួនាទីនិងភារកិច្ចដល់ពួកគាត់។ |
| **៣.ធនធានមនុស្សនៅរដ្ឋបាលសង្កាត់** | |
| - | បញ្ហាប្រឈម ការយល់ដឹងរបស់មន្ត្រីសង្កាត់នៅមានកម្រិត។ |
| | សំណូមពរ បើកវគ្គបណ្តុះបណ្តាលខ្លីៗអំពីធនធានមនុស្ស។ |
| **៤.ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលសង្កាត់** | |
| - | មិនមានអ្វីគួរឱ្យកត់សម្គាល់ |
| **៥.ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងថ្នាក់ជាតិនិងសង្កាត់ និងរវាងសង្កាត់និងថ្នាក់ក្រោមជាតិព្រមទាំងការប្រាស្រ័យទាក់ទង និងគណនេយ្យភាពរវាងរដ្ឋបាលសង្កាត់ជាមួយប្រជាពលរដ្ឋ** | |
| - | មិនមានអ្វីគួរឱ្យកត់សម្គាល់ |
| **៦.ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលសង្កាត់** | |
| - | -បញ្ហាខុសឈ្មោះ ក៏ដូច ជាទិន្នន័យផ្សេងៗនៅក្នុងសំបុត្រកំណើតនិងសំបុត្របញ្ជាក់កំណើត ជាពិសេសសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ដែលធ្វើនៅក្នុងឆ្នាំយុទ្ធនាការ គឺពិបាកក្នុងការកែតម្រូវ ព្រោះត្រូវស្នើសុំដល់តុលាការហើយមានការយឺតយ៉ាវមិនអាចបំពេញតាមតម្រូវការរបស់ពួកគាត់បានទាន់ពេលវេលា។ |
| **៧.ការគាំទ្រ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើអធិការកិច្ច ឬសវនកម្មរដ្ឋបាលសង្កាត់** | |
| - | មិនមានអ្វីគួរឱ្យកត់សម្គាល់ |
| **៨.បញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** | |
| - | -បញ្ហាប្រឈម ការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការបំពេញការងារនៅមានកម្រិតស្របពេលដែលតម្រូវការសេវាច្រើនឡើងៗ។<br>-សមត្ថភាពបុគ្គលិកនៅមានកម្រិតនៅឡើយ |
| | សំណូមពរ មានការបើកវគ្គបណ្តុះបណ្តាលធនធានមនុស្ស និងព័ត៌មានវិទ្យា។ |